01217160

E1/399.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Mar-2016, 15:55
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី៣៨០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា អេវេលីន ខាំផូស សង់ចេស

*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេ្វា ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ល សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក សេង លាង | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ហុង គីមសួន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក ចាន់ ទូយ (2-TCW-921) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរសាក្សី ÷ លោក ចាន់ ទូយ** (2-TCW-921)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............ ទំព័រ ២

សួរដោយលោក សេង លាង ផ្ដើមពី ............ ទំព័រ ៦

សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី ............ ទំព័រ ១៨

សួរដោយលោក ហុង គីមសួន ផ្ដើមពី ............ ទំព័រ ៤៤

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ............ ទំព័រ ៥២

សួរដោយលោកស្រី អង់តា ហ្គីសសេ ផ្ដើមពី ............ ទំព័រ ៦២

# **កិច្ចដំណើរការនីតិវិធី**

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-921 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខភ្នំក្រោល។

ក្រឡាបញ្ជីសវនាការលោក សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះមានរហស្សនាម 2-TCW-921 សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។

សាក្សីបានធ្វើសម្បថរួចនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ ហើយនៅថ្ងៃនេះមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-817 ។ សូមអរគុណលោកប្រធាន។

[០៩:០៦:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះខ្លាំង មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្ត បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:៣១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកឈ្មោះអី?

**លោក ចាន់ ទូយ៖**

**ឆ៖** ខ្ញុំឈ្មោះ ចាន់ ទូយ។

**ស៖** ចាន់ ទូយ អ៊ីចឹងទេ? លោកចេះអក្សរទេ ប្រកប សរសេរយ៉ាងម៉េចទៅ ឈ្មោះរបស់លោក? កុំអាលទាន់ៗ ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដោយឲ្យភ្លើងសញ្ញាក្រហមជាមុនសិនណ៎ះ!

[០៩:១០:១៣]

**លោក ចាន់ ទូយ៖**

**ឆ៖** សរសេរ "ច" ដាក់ស្រះ "ា" "ន់" អក្សរ "ទ" ដាក់ស្រះ "ូ" និង "យ"។

**ស៖** បាទ អរគុណលោក ចាន់ ទូយ។ ហើយលោកកើតនៅថ្ងៃ ខែ ឆ្នាំណា លោកចាំដែរទេ?

**ឆ៖** ថ្ងៃខែហ្នឹង ឆ្នាំកើតហ្នឹង ខ្ញុំចង់ភ្លេចៗអស់ទៅហើយឥឡូវ។

**ស៖** ឥឡូវហ្នឹងលោកអាយុប៉ុន្មានហើយ? កុំអាលទាន់ឆ្លើយតប ហើយឆ្លើយឲ្យជាក់លាក់ហាប៉ុន្មានឲ្យច្បាស់លាស់ណ៎ះ!

**ឆ៖** អាយុ៥៦ហើយ។

**ស៖** អរគុណ។ ហើយលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** នៅភូមិជីមៀត ឃុំជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃ លោករស់នៅទីកន្លែងណា?

**ឆ៖** សព្វថ្ងៃនៅភូមិជីមៀត ឃុំណងឃីលឹក ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដដែល។

**ស៖** លោកប្រកបមុខរបរអីដែរសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំធ្វើកងទ័ព។

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី? ម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកឈ្មោះ កែន ចាន់។ ម្ដាយឈ្មោះ (ប៊ុន) ខាំប៉ែង។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធឈ្មោះ ម៉ុង ផន ស្លាប់ហើយ កូននៅប្រាំពីរនាក់។

[០៩:១២:៣៧]

**ស៖** អរគុណ។ លោកចាន់ ទូយ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថាតាមសមត្ថភាពដែលលោកអាចដឹងគឺថាលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួល

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដីនេះទេ។ តើរបាយការណ៍នេះពិតជាត្រឹមត្រូវអ៊ីចឹងមែនទេ?

**ឆ៖** បាទ របាយការណ៍ខ្ញុំអត់មានពាក់ព័ន្ធនឹងជនជាប់ចោទពីរនាក់ហ្នឹងទេ។

**ស៖** ហើយលោកបានធ្វើសម្បថនៅចំពោះអ្នកតាដំបងដែក នៅពីខាងកើតសាលសវនាការរួចហើយឬនៅ មុនចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បាទខ្ញុំស្បថហើយ។

[០៩:១៣:២៧]

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ អំពីសិទ្ធិ លោក ចាន់ ទូយ ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើការអត្ថាធិប្បាយរៀបរាប់ណា ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឲ្យលោកចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកនោះនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិក្នុងឋានៈជាសាក្សីរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លោក ចាន់ ទូយ តើលោកធ្លាប់បានផ្ដល់កិច្ចសម្ភាសន៍ ឬក៏ផ្ដល់សក្ខីកម្មជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមក ហើយបើសិនបើធ្វើៗប៉ុន្មានដង? ធ្វើនៅទីកន្លែងណា ហើយធ្វើនៅពេលណា?

**ឆ៖** បាទ ខាងសម្ភាសទៅសម្ភាសខ្ញុំម្ដងនៅផ្ទះ។

**ស៖** ពីពេលណាមកដែរ លោកចងចាំដែរទេ?

**ឆ៖** តាំងពី១៩៨៩។

[០៩:១៥:៣៤]

**ស៖** ១៩៩៩។ ចុះក្រោយមកទៀត នៅក្នុងអំឡុងឆ្នាំ២០០៨ ដែលមានដែលលោកដែលបានទៅធ្វើ -- ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ បានមួយដងដែរ។

**ស៖** អ៊ីចឹងបានន័យថា លោកផ្ដល់កិច្ចសម្ភាសន៍ពីរដង មួយដងគឺធ្វើនៅឆ្នាំ១៩៩៩ ហើយមួយដងទៀត នៅឆ្នាំ២០០៨អ៊ីចឹងអ្វេស?

**ឆ៖** ចុងក្រោយហ្នឹង ខ្ញុំបាទមិនបានចំណាំច្បាស់ដែរ ឆ្នាំខែ អត់បានដឹងកត់ទុក។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល បានអាន ឬក៏បានស្ដាប់ការអាននូវកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មកាលពីពេលមុន ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ មានកន្លែងខ្លះក៏ចាំបាន កន្លែងខ្លះក៏ភ្លេចអស់ដែរ។ ចាំមិនសូវបានដែរឥឡូវ។

**ស៖** អ៊ីចឹងបានន័យថា លោកបានពិនិត្យមើល បានអានកំណត់នុ៎ងហើយ ប៉ុន្តែលោកការចងចាំរបស់លោក គឺចាំមិនអស់ទេ។ មិនអ៊ីចឹងអ្វេស កន្លែងខ្លះភ្លេច កន្លែងខ្លះ គឺនៅចងចាំ អ៊ីចឹងទេ?

**ឆ៖** បាទ។

**ស៖** ហើយពិនិត្យមើល ក្រោយពិនិត្យមើលការអាន និងអានទៅហ្នឹង តើលោក -- តាមការយល់ដឹងរបស់លោក តើលោកបានអាចបញ្ជាក់បានទេថា កំណត់ដែលលោកបានអានដើម្បីរំឭកការចងចាំនោះ វាពិតជាត្រឹមត្រូវ ឬក៏សមស្របស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្ដល់កិច្ចសម្ភាសន៍កាលពីពេលមុននេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំក៏បានកន្លែងខ្លះនោះក៏ចាំ កន្លែងខ្លះហ្នឹងក៏មិនចាំច្បាស់ដែរ កន្លែងនុ៎ង បើវាភ្លេចភ្លាំងដែរ យូរហើយ។

[០៩:១៧:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ មិនអីទេ ហើយការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា សួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខ មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

## ការតាំងសំណួរដោយសហព្រះរាជអាជ្ញា

**សួរដោយលោក សេង លាង៖**

ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញា។

**ស៖** ថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនចង់សួរឲ្យលោកសាក្សីជួយបំភ្លឺអង្គសវនាការ។ ហើយសំណួរដំបូងរបស់ខ្ញុំ ខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីឈ្មោះរបស់លោកបន្តិច ថាតើលោកឈ្មោះថា ចាន់ តូច ឬក៏ ចាន់ ទូយ?

**ប្រធានអង្គជំនុំ៖**

សាក្សី មិនបាច់ឆ្លើយតបទេ សាក្សីបានឆ្លើយច្បាស់រួចហើយ ហើយ គឺ ទូយ – "ទ" ស្រៈ "ូ" និង "យ"។

**លោក សេង លាង៖**

លោកប្រធាន នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ គេៗបាននិយាយថា គាត់ឈ្មោះ ចាន់ តូច ហើយ ចាន់ ទូយ។

**ប្រធានអង្គជំនុំ៖**

ដោយយើងបានពិនិត្យមើលនូវអត្តសញ្ញាណប័ណ្ណរបស់គាត់ អ៊ីចឹងហើយបានយើងសួរបញ្ជាក់ ហើយឲ្យគាត់ប្រកបនូវឈ្មោះរបស់គាត់ទៀត ដើម្បីផ្ទៀងផ្ទាត់។ អ៊ីចឹង គឺច្បាស់លាស់ហើយនៅចំពោះមុខអង្គជំនុំជម្រះនេះ។

[០៩:១៩:៣៨]

**លោក សេង លាង៖**

បាទ អរគុណអ៊ីចឹង។

**សួរដោយលោក សេង លាង៖**

**ស៖** លោក ចាន់ ទូយ តើលោកអាចប្រាប់បានទេថា តើលោកបានសិក្សាដល់ថ្នាក់ណាដែរ កម្រិតសិក្សារបស់លោក?

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ ខ្ញុំការសិក្សាតាំងពីសង្គមសម្ដេចនោះបានតិចតួចទេ ប៉ុន្តែកាលនោះប្រទេសកើត

សង្គ្រាមនោះ ក៏ឈប់បានរៀនសូត្រទៅ។

**ស៖** ដល់ថ្នាក់ទីប៉ុន្មានដែរ លោកអាចប្រាប់បានទេ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប។

**លោក ចាន់ ទូយ៖**

**ឆ៖** ថ្នាក់ទី១២ពីដើម ពីសង្គម។

**សួរដោយលោក សេង លាង៖**

**ស៖** បាទ អរគុណលោកសាក្សី។ លោកសាក្សី ខ្ញុំចង់ដឹងពីប្រវត្តិលោកមួយចំនួន ថាតើនៅមុនឆ្នាំ -- មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ លោករស់នៅទីណា ហើយលោកធ្វើអ្វីដែរ?

[០៩:២០:៥០]

**ឆ៖** ខ្ញុំនៅស្រុកកោះញែក។

**ស៖** ពេលនោះលោកធ្វើអ្វីដែរ?

**ឆ៖** ឆ្នាំប៉ុន្មាន?

**ស៖** មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** កាលនោះ ខ្ញុំនៅជាមួយឪពុកម្ដាយ នៅផ្ទះ។

**ស៖** ដើម្បីរំឭកការចងចាំរបស់លោក ឯកសារកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/7694, ERN ជាភាសាខ្មែរ 00236705, ERN ជាភាសាអង់គ្លេស 00242142, ERN ជាភាសាបារាំង 00276802។ សំណួរសួរថា៖ "មុនថ្ងៃ១៧ ខែមេសា តើលោកនៅទីណា ហើយធ្វើអ្វី?" ចម្លើយលោកឆ្លើយថា៖ "មុនថ្ងៃ១៧ មេសា ខ្ញុំរស់នៅពាមភូមិជីមៀត ឃុំជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគីរី។ នៅពេលនោះ មានចលនាបដិវត្តន៍កើតឡើង ខ្ញុំបានគេកៀងចូលព្រៃ ហើយខ្ញុំធ្វើជានីរសារឲ្យឈ្មោះ សារ៉ាន។ សារ៉ាន គឺជាអ្នកបញ្ជូនសារមកពីថ្នាក់លើតាមភូមិឃុំ និងកន្លែងផ្សេងៗ។" តើអ្វីដែលខ្ញុំបានអាននេះអាចរំឭកការចងចាំរបស់លោកដែរឬទេ?

[០៩:២២:៤៧]

**ឆ៖** កាលហ្នឹង កន្លែងហ្នឹងដូចអត់មានត្រូវផ្លាស់ទេ។ ខ្ញុំសូមសួរលោកបញ្ជាក់ម្ដងទៀត ព្រោះអន់ត្រចៀកដែរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ចង់ឲ្យលោកជួយបញ្ជាក់ថា តើមុនថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ហ្នឹង លោកធ្វើអ្វី?

**ឆ៖** កាលមុនហ្នឹង ខ្ញុំនៅៗជាមួយឪពុកម្ដាយនៅផ្ទះសម្បែង នៅភូមិឃុំ។

**ស៖** តើលោកធ្លាប់មានចូលរួមជាមួយចលនាបដិវត្តន៍ទេនៅពេលនោះ?

**ឆ៖** កាលនោះ ខ្ញុំអត់ដឹងអីច្បាស់លាស់ដែរ កាលនុ៎ង ព្រោះថានៅក្មេងៗនៅឡើយ។

**ស៖** បើតាមចម្លើយដែលខ្ញុំអានជម្រាបលោកអំមិញហ្នឹង គឺលោកធ្លាប់នៅការិយាល័យសហចៅក្រមស៊ើបអង្កេត លោកធ្លាប់ថា ឆ្លើយថាលោកត្រូវបានគេកៀងចូលព្រៃ ហើយធ្វើជានីរសារឲ្យឈ្មោះ សាន រ៉ា។ តើលោកចាំទេអាហ្នឹង?

**ឆ៖** បាទ ក្រោយ១៧ មេសាទេ បានធ្វើជានីរសារ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺមុនថ្ងៃ១៧ ខែមេសា ប៉ុន្តែបើសិនជាលោកមិនចាំ ក៏មិនអីដែរ។

**ឆ៖** បាទ សូមៗទោសបន្តិចហើយ ព្រោះថាខ្ញុំប្រហែលជាមានភ្លេចខ្លះ។ ខ្ញុំភ្លេចខ្លះ ឬភ្លេចមែនទែនតែម្ដង ភ្លេចចងចាំតែម្ដង វាជិត ពីក្រោម៧៥ចុះមក។ ប៉ុន្តែដូចអត់បានធ្វើអី។

[០៩:២៤:៥៩]

**ស៖** បាទ អរគុណលោក។ អ៊ីចឹងលោកអំមិញមានប្រសាសន៍ថា ក្រោយឆ្នាំ -- ថ្ងៃ១៧ មេសា ឆ្នាំ៧៥ លោកធ្វើនីរសារឲ្យឈ្មោះ សាន សារ៉ា។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** តើលោកនៅចាំបានទេថា តំបន់ដែលលោករស់នៅហ្នឹង គឺស្ថិតនៅក្នុងតំបន់ឈ្មោះអ្វីដែរ?

**ឆ៖** តំបន់នុ៎ង ពីដើមគេហៅខេត្តមណ្ឌលគិរី ដល់របប ១៧ មេសា មកហ្នឹងគេហៅថា តំបន់ ១០៥។

**ស៖** នៅក្នុងរបបខ្មែរក្រហមហ្នឹង តើលោកនៅចាំបានទេថា តើគណៈលេខាតំបន់ហ្នឹងឈ្មោះអីដែរ លោកមានចាំទេ?

**ឆ៖** បាទ ចាំ។ ឈ្មោះ ហម។

**ស៖** ចុះសមាជិកគណៈតំបន់ផ្សេងៗទៀត តើលោកមាននៅចាំទេថា មាននរណាខ្លះ ហើយឈ្មោះអី?

**ឆ៖** ខ្ញុំនៅចាំបានតែអ្នកធំៗ ដូច ហម ដូច ខាំភួន ខ្ញុំចាំបាន។ មេធំៗនុ៎ង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អំមិញលោកបានមានប្រសាសន៍អំពីឈ្មោះ ហម និងឈ្មោះ ខាំភួន ហើយបន្តិចទៀត ខ្ញុំនឹងមានសំណួរទៅលើបញ្ហានេះ។ ប៉ុន្តែងាកមកលោក សៅ រ៉ា វិញម្តង តើ សៅ រ៉ា នោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ជានរណា ហើយគាត់មានតួនាទីជាអ្វីដែរ បានជាលោកធ្វើជានីរសាររបស់គាត់?

**ឆ៖** កាលនោះ ឈ្មោះ សាន រ៉ា ហ្នឹងជាអនុស្រុកកោះញែក បានខ្ញុំធ្វើនីរសារឲ្យគាត់នុំង។

**ស៖** តើលោកចាំបានទេថា លោកធ្វើនីរសារគាត់ហ្នឹង រហូតដល់ពេលណាដែរ?

**ឆ៖** ត្រង់ហ្នឹងវាភ្លេចខ្លះ វាររអាក់រអួលកន្លែងត្រង់គេចាប់ គេចងអីត្រង់ហ្នឹង បានខ្ញុំភ្លេច ចំណាំមិនសូវយកចិត្តទុកដែរ ពេលនុំង។

**ស៖** នៅពេលដែលលោកធ្វើការងារជានីរសារឲ្យឈ្មោះ សាន រ៉ា ហ្នឹង តើ សាន រ៉ា ហ្នឹងគេឲ្យលោកធ្វើអ្វីខ្លះ?

[០៩:២៨:០៧]

**ឆ៖** គាត់ប្រើតែបោកខោអាវ ធ្វើម្ហូប ធ្វើស្ល ដាំបាយ និងជូនសំបុត្រចុះឡើងប៉ុណ្ណឹង ខ្ញុំចាំបាន។

**ស៖** លោកបានមានប្រសាសន៍ថា ការងារជានីរសាររបស់លោក គឺការងារសំខាន់មួយ គឺជូនសំបុត្រចុះឡើង។ តើលោកជូនសំបុត្រទៅកន្លែងណាខ្លះដែរ?

**ឆ៖** ជូនទៅមន្ទីរតំបន់ទាន។

**ស៖** ទៅមន្ទីរតំបន់ បញ្ជូនទៅឲ្យនរណាគេលោកនៅចាំទេ?

**ឆ៖** បញ្ជូនឲ្យ តាហម។

**ស៖** តើលោកនៅចាំបានទេថា មន្ទីរតំបន់ លេខាស្រុក -- លេខតំបន់ -- មន្ទីរតំបន់១០៥ គឺស្ថិតនៅកន្លែងណាដែរលោកចាំទេ?

**ឆ៖** បាទ ចាំ នៅភ្នំក្រោល។

**ស៖** តើលោកស្គាល់ឈ្មោះមន្ទីរនោះទេ ដែរឬទេ?

**ឆ៖** បាទ ស្គាល់នៅភ្នំក្រោល។

**ស៖** នៅម្តុំភ្នំក្រោលហ្នឹងមានមន្ទីរច្រើន អាចថាមានមន្ទីរ “ក” ប៉ុន្មានៗអីចឹង។ តើលោកអាចមានចាំបានទេថា វានៅមន្ទីរ“ក” ប៉ុន្មាន?

**ឆ៖** នៅយូរយាមកហើយ ភ្លេចខ្លះហើយកាលហ្នឹង វាដូចច្រើន “ក” ច្រើន “ខ” ពេករបស់គេហ្នឹង ភ្លេចភ្លាំងអស់ហើយ មិនចាប់អារម្មណ៍ផង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ អរគុណ។ តើក្រៅពីបញ្ជូនសំបុត្រទៅឲ្យឈ្មោះ ហម នៅតំបន់១០៥ហ្នឹង តើលោកមានធ្លាប់បញ្ជូនសំបុត្រទៅមន្ទីរសន្តិសុខណាដែរឬទេ?

**ឆ៖** អត់មានទេ មានតែមន្ទីរតំបន់ហ្នឹង។

[០៩:៣១:០០]

**ស៖** បាទ អរគុណច្រើន។ ឥឡូវខ្ញុំងាកមកនិយាយអំពីឈ្មោះ ឡាំ និងឈ្មោះ ខាំភួន ដែលលោកបាននិយាយអំមិញ។ ពាក់ព័ន្ធនឹងឈ្មោះអ្នកទាំងពីរនេះ តើលោកមានអ្វីចង់និយាយប្រាប់តុលាការអំពីការចងចាំរបស់លោកពាក់ព័ន្ធជាមួយអ្នកទាំងពីរនេះដែរទេ?

**ឆ៖** បាទ មានខ្លះៗដែរ ដែលនៅចងចាំបានខ្លះៗ។

**ស៖** សូមលោកជួយរៀបរាប់អំពីព្រឹត្តិការណ៍នានាដែលកើតឡើងទាក់ទងជាមួយនឹងឈ្មោះ ខាំ -- ឈ្មោះ ហម និងឈ្មោះ ខាំភួន នេះបន្តិចប្រាប់អង្គសវនាការផង។

**ឆ៖** បាទ ដូច ហម ជាមួយនឹង ខាំភួន ហ្នឹង, ហម ហ្នឹងជាតំណាង ដូចថា ជាប្រធានតំបន់ ហើយ ខាំភួន ហ្នឹងជាតំណាងរាស្ត្រនៅតំបន់១០៥ហ្នឹង។

**ស៖** តើនៅក្នុងអំឡុងពេលគ្រប់គ្រងរបស់ឈ្មោះ ហម ហ្នឹង តើអ្នកទាំងពីរធ្លាប់មានបញ្ហាឈ្លោះទាស់ទែងគ្នាដែរឬទេ រវាងឈ្មោះ ហម និងឈ្មោះ ខាំភួន ហ្នឹង?

**ឆ៖** បាទ ក្រោយមកហ្នឹង បានដឹងថាឈ្មោះ ហម ជាមួយ ខាំភួន ហ្នឹងមកភ្នំពេញ។ មកភ្នំពេញថា វ៉ៃគ្នាងាប់ បាញ់គ្នាងាប់។ ចំណាំបានតែប៉ុណ្ណឹង។ ដឹងគេយកទៅណា វ៉ៃមែន មិនដឹងអត់ ខ្ញុំក៏អត់ដឹងច្បាស់ដែរ។ ប៉ុន្តែយកមកភ្នំពេញនេះ ក៏បាត់ឈ្មោះរហូតទៅ ថា ឮថាវ៉ៃគ្នាងាប់ហើយ។

**ស៖** លោកមានប្រសាសន៍ថា ឈ្មោះ ហម និងឈ្មោះ ខាំភួន ហ្នឹង វ៉ៃ ឮថា គេវ៉ៃគ្នាងាប់នៅភ្នំពេញ។ តើលោកឮពីអ្នកណាគេដែរ លោកអាចប្រាប់បានទេ?

**ឆ៖** បាទ តាមការចងចាំរបស់ខ្ញុំហ្នឹង កាលហ្នឹងគេមាននីរសារដែរ។ ដល់នីរសារនោះត្រឡប់ទៅវិញ បានប្រាប់ បានដឹង។ កងការពារគេហ្នឹង ពីដើមហៅថា "នីរសារ"។

[០៩:៣៣:៤៥]

**ស៖** នីរសារហ្នឹង ជានីរសាររបស់ឈ្មោះ ហម ឬក៏ជានីរសាររបស់ឈ្មោះ ខាំភួន?

**ឆ៖** នីរសារទាំងពីរនាក់ហ្នឹង។

**ស៖** ក្រោយពីការស្លាប់ ឬក៏ការបាត់ខ្លួនរបស់អ្នកទាំងពីរនៅភ្នំពេញហ្នឹង តើនៅតំបន់១០៥

មានរឿងអីកើតឡើងទៀតដែរទេ?

**ឆ៖** បើតាមការចងចាំខ្លះៗហ្នឹង មានដល់បាត់ពីរនាក់ហ្នឹងទៅ ហើយនៅក្រោយហ្នឹង ក៏ចាប់គ្នាប្រទូស្តប្រទាំងគ្នា គគ្រឹកគគ្រេងទៅ។ ហ្នឹងឃើញនៅចងចាំបានអ៊ីចឹងខ្លះដែរ។

**ស៖** លោកនិយាយថា ក្រោយព្រឹត្តិការណ៍ពីរនាក់ហ្នឹងគឺមានការប្រទូស្តប្រទាំងចាប់។ ចុះមុនព្រឹត្តិការណ៍ពីរនាក់ហ្នឹង តើនៅតំបន់របស់លោក ៗមានធ្លាប់បានឃើញមានការចាប់មនុស្សចាប់អីដែរឬទេ?

**ឆ៖** បាទ មាន។

**ស៖** អរគុណលោក ហើយខ្ញុំនឹងសួរសំណួរពាក់ព័ន្ធនឹងបញ្ហាចាប់នេះនៅពេលក្រោយទៀត។ ឥឡូវចង់ឲ្យលោកបញ្ជាក់មកអំពីក្រោយព្រឹត្តិការណ៍ដែលកើតឡើងរវាងឈ្មោះ ហម និងឈ្មោះ ខាំភួន វិញលោកមានប្រសាសន៍ថាមានការចាប់គ្នាប្រទូស្តប្រទាំង។ តើចាប់គ្នាប្រទូស្តប្រទាំងយ៉ាងម៉េចលោកអាចជម្រាបជូនអង្គសវនាការបានទេ?

**ឆ៖** ខ្ញុំបាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៣៦:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ សំណួរដែលសួរទៅកាន់សាក្សីគឺបញ្ជាក់អត្ថន័យថា ហម ឬក៏ ខាំភួន អាចត្រូវបានចាប់ខ្លួន ឬក៏បាត់ខ្លួន។ ក៏ប៉ុន្តែសាក្សីបានឆ្លើយថា ហម គឺថាត្រូវបាន ខាំភួន សម្លាប់ចោល បាញ់សម្លាប់ចោល ប៉ុន្តែមិនដឹងច្បាស់លាស់នោះទេ ប៉ុន្តែគាត់មិនបាននិយាយអំពីការចាប់ខ្លួន ឬក៏ការបាត់ខ្លួនរបស់អ្នកទាំងពីរនេះទេ។

**លោក សេង លាង៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបថា មុននេះលោកសាក្សីគាត់បានថា អ្នកទាំងពីរទៅភ្នំពេញ ហើយទៅភ្នំពេញឮថាមានការសម្លាប់ខ្លួន ឬក៏បាត់ខ្លួនអីគាត់មិនដឹងទេ។ អ៊ីចឹងជំហររបស់លោកសាក្សីគាត់អត់ទាន់ច្បាស់ថា គាត់សម្លាប់គ្នា ឬក៏បាត់ខ្លួនតាមរបៀបណាទេ។ ដូច្នេះក៏ខ្ញុំមិនអាចនិយាយឲ្យច្បាស់ ឲ្យចំថាគាត់សម្លាប់ ឬក៏គ្នា ឬយ៉ាងណាដែរ នេះជាអ្វីដែលសាក្សីបានឆ្លើយ។ ដូច្នេះ ខ្ញុំសូមនិយាយត្រឹមថា តើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គាត់ទៅភ្នំពេញ បាត់ខ្លួន ឬក៏ស្លាប់ ខ្ញុំសូមនិយាយតែត្រឹមហ្នឹង ប៉ុន្តែមិនអាចបកឲ្យលើសពីអ្វីដែលសាក្សីបាននិយាយទេ។

**សួរដោយលោក សេង លាង៖**

**ស៖** ឥឡូវ ខ្ញុំសូមសួរសំណួរតទៅទៀតថា ក្រោយពីៗការព្រឹត្តិការណ៍របស់អ្នកទាំងពីរហ្នឹងទៅលោក -- តើលោកខ្លួនលោកផ្ទាល់មានធ្លាប់ត្រូវបានគេចាប់ខ្លួនដែរឬទេ?

[០៩:៣៨:០៥]

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ មូលហេតុហ្នឹងរូបខ្ញុំក៏គេត្រូវគេចាប់ដែរ ចាប់ទាំងអស់ ហើយតាមការខ្ញុំចងចាំមើលអាហ្នឹង ដូចថាខ្សែ តាហាម ហ្នឹងចាប់ខ្សែ តាខាំភួន អ៊ីចឹងវាដោយទាំងពូជពង្សវង្សត្រកូលសែស្រឡាយអីហ្នឹងវាចាប់គ្នារប៉ាត់រប៉ាយអ៊ីចឹងទៅតែម្តងមួយខ្សែអ៊ីចេះគេអ៊ីចឹង។ តាមខ្ញុំចងចាំបានខ្លះប៉ុណ្ណឹង។

**ស៖** ចុះក្រោយការចាប់ -- តើក្រោយពី តាហាម និង ខាំភួន អវត្តមានពីតំបន់១០៥ ទៅ តើនរណាគេឡើងកាន់ការងារជំនួស តាហាម និង ខាំភួន ហ្នឹងលោកអាចនៅចាំទេ?

**ឆ៖** ខ្ញុំនៅចាំបានខ្លះដែរ ដូច តាសារុន។

**ស៖** លោក តើ តាសារុន ហ្នឹងមានជាប់ទំនាក់ទំនងសាច់ញាតិលោហិតជាមួយនឹង ហាម ឬក៏ឈ្មោះ ខាំភួន ហ្នឹងដែរឬទេ?

**ឆ៖** តាសារុន ហ្នឹងជាប់ខ្សែជាមួយ តាហាម។ ហើយ តាសារុន ហ្នឹងបានចាប់ខ្សែ តាខាំភួន។

**ស៖** តើលោកស្គាល់ឈ្មោះមនុស្សទៀតឈ្មោះ ផាន យោន ដែរឬទេ?

**ឆ៖** បាទ ស្គាល់។

**ស៖** តើ ផាន យោន គាត់មានតួនាទីអ្វី? ហើយគាត់មានទំនាក់ទំនងសាច់ញាតិអ្វីជាមួយ ហាម និង ខាំភួន ដែរឬទេ?

**ឆ៖** បាទ ហាម -- ផាន យោន នឹងត្រូវជាប្អូនថ្លៃរបស់ ហាម ។

**ស៖** តើរវាង ហាម និង ខាំភួន នឹងមានទំនាក់ទំនងសាច់ញាតិអ្វីនឹងគ្នាដែរឬទេ?

**ឆ៖** បាទ តាហាម ជាមួយ ខាំភួន ហ្នឹងដូចសាច់ថ្លៃអ៊ីចឹងដែរ ដូចសាច់ថ្លៃ។

**ស៖** បាទ អ៊ីចឹងបានន័យថាពួកគេសុទ្ធតែជាប់សែស្រឡាយសាច់ឈាមគ្នាទាំងអស់។ អ៊ីចឹងលោកអំមិញមានប្រសាសន៍ថា ខ្សែរបស់ តាហាម បានចាប់សាច់ញាតិរបស់ ខាំភួន។ តើអ្វីដែលខ្ញុំនេះ

ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ តាមការចងចាំត្រឹមត្រូវហើយ។

**ស៖** តាមតែលោក -- តាមដែលលោកដឹង តើនៅពេលហ្នឹង តើមានការចាប់មនុស្សប្រហែលជាប៉ុន្មាននាក់ដែរ?

**ឆ៖** មួយរឹកចាប់ជាមួយខ្ញុំហ្នឹង ក្នុងចំណោមចាប់ជាមួយខ្ញុំហ្នឹង ប្រហែលជា ៨០ជាង។

**ស៖** ចុះលោកពាក់ព័ន្ធអីជាមួយនឹង ខាំភួន ដែរបានជាលោកត្រូវគេចាប់ខ្លួនដែរនៅពេលនោះ?

**ឆ៖** បាទ ខ្ញុំជានីរសាររបស់ឈ្មោះ ផាន វ៉ា នោះ វ៉ា ហ្នឹង។ ហើយ វ៉ា ហ្នឹងក៏ជាក្មួយរបស់ខាំភួន។

**ស៖** ចុះប្រពន្ធរបស់លោក មានទំនាក់ទំនងសាច់ញាតិអីជាមួយឈ្មោះ ខាំភួន ដែរឬទេ? ចុះនៅពេលដែលឃាត់ខ្លួនហ្នឹង តើលោកមានចាំបានទេ ថាអ្នកណាខ្លះត្រូវឃាត់ខ្លួនដូចជា -- តើ វ៉ា ដែលជាមួយមេរបស់លោកត្រូវ--

[០៩:៤២:៥៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមចាំបន្តិចលោក ដោយសារថាមានបញ្ហាបកប្រែបន្តិច។ អ្នកបកប្រែគឺថា មិនអាច<យល់>ចម្លើយដែលសាក្សីឆ្លើយ<បាន>ទេ សូមឆ្លើយឡើងវិញ។

**សួរដោយលោក សេង លាង៖**

**ស៖** ចម្លើយមុននេះ ខ្ញុំសួរថាតើប្រពន្ធរបស់លោកមានទំនាក់ទំនងសាច់ញាតិអីជាមួយនឹងឈ្មោះខាំភួន ដែរឬទេ?

**លោក ចាន់ ទូយ៖**

**ឆ៖** ប្រពន្ធខ្ញុំត្រូវសែស្រឡាយបងប្អូនឆ្ងាយៗជីដូនជីតាអ៊ីចឹង។

**ស៖** បាទ អរគុណៗ។ អ៊ីចឹងលោកអាចបញ្ជាក់បានទេថា តើនៅពេលដែលឃាត់ខ្លួនហ្នឹង មេដឹកនាំដែលលោកស្គាល់ នរណាខ្លះដែលត្រូវឃាត់ខ្លួនដែរ ឈ្មោះ វ៉ា, ឈ្មោះ ផាន ឃោន ឬក៏ឈ្មោះណាផ្សេងទៀត ដែលមានត្រូវគេឃាត់ខ្លួនដែរឬទេ?

**ឆ៖** បាទ ដំណើងហ្នឹង តាមខ្ញុំដឹង គេចាប់ពួកហ្នឹងមុន បានគេចាប់ពួកខ្ញុំក្រោយ។

**ស៖** អ៊ីចឹងមានន័យថា ឈ្មោះ វ៉ា និងឈ្មោះ ផាន ឃោន ក៏ត្រូវចាប់ខ្លួនមុនលោក ហើយ

ក្រោយមកបានគេចាប់ខ្លួនលោក។ តើលោក -- អម្បាញ់មិញ លោកថាគេចាប់ ដោយសារថាលោកជានីរសាររបស់ឈ្មោះ វ៉ា បានត្រូវគេចាប់ខ្លួន។ តើវាត្រឹមត្រូវដែរឬទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងមានបញ្ហានៃការបកប្រែដដែលហើយ។ អ្នកបកប្រែស្តាប់ចម្លើយអត់ឮ។ <សំណួរទៅកាន់អ្នកបកប្រែ តើ>ឆ្លើយលឿនពេក ឬក៏<>មកបញ្ហា<អ្វី>?

[០៩:៤៩:៥៦]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំឃើញសាក្សីហ្នឹងគឺថា បែរជាងក់ក្បាលទៅវិញ អ៊ីចឹងឯងបានអ្នកបកប្រែមិនអាច មិនដឹងបកថាម៉េច។ <>

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<ក្នុងករណីនេះ ជាក់ស្តែងណាស់ សូមជម្រាបជូនសាក្សីថា យើងកត់ត្រាចូលក្នុងប្រតិចារឹកនូវអ្វីដែលលោកកំពុងនិយាយ ដូច្នេះបើលោកគ្រាន់តែងក់ក្បាល នោះវានឹងមិនមាននៅក្នុងប្រតិចារឹកទេ។ សូមលោកឆ្លើយជាពាក្យថា បាទ ឬក៏ ទេ។>

**សួរដោយលោក សេង លាង៖**

**ស៖** សំណួររបស់ខ្ញុំមុននេះ ចង់ឱ្យលោកបញ្ជាក់ថា តើមានមេដឹកនាំណាខ្លះដែលត្រូវឃាត់ខ្លួននៅក្នុងអំឡុងពេលជាមួយនឹងលោកហ្នឹង?

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ តាមដឹងទៅ មេដឹកនាំដូចថាលើៗហ្នឹង វាបាត់អស់រលីងហើយ បានគេឃាត់ពួកខ្ញុំថ្នាក់ក្រោមៗហ្នឹង ទាំងកូនចៅសែស្រឡាយពូជអំបូរអ៊ីចឹងទៅ។

**ស៖** តើឈ្មោះ វ៉ា និងឈ្មោះ ផាន ឃោន ហ្នឹងត្រូវគេឃាត់ខ្លួនដែរឬទេ នៅពេលហ្នឹង?

**ឆ៖** បាទ ដូចខ្ញុំជម្រាបអំមិញហ្នឹង តាមការខ្ញុំដឹងនិងចងចាំថា ឈ្មោះទាំងអស់ហ្នឹងគេចាប់មុនហើយ បានគេចាប់ពួកខ្ញុំក្រោយ។

**ស៖** បាទ តើនៅពេលដែលលោកត្រូវឃាត់ខ្លួននោះ តើគេយកលោកទៅដាក់នៅកន្លែងណាលោកចាំដែរទេ?

**ឆ៖** បាទ ដាក់នៅភ្នំក្រោលហ្នឹង។

**ស៖** សូមលោកជួយរៀបរាប់ប្រាប់អង្គសវនាការអំពីទីកន្លែងដែលគេយកលោកទៅដាក់ហ្នឹង ជាពិសេសពីអគារៗដែលគេឃុំខ្លួនលោកហ្នឹង តើវាមានស្ថានភាពយ៉ាងម៉េចដែរ លោកអាចប្រាប់អង្គ-សវនាការបានទេ?

[០៩:៤៧:០៩]

**ឆ៖** បាទ រឿងអគារហ្នឹង វាមាន ដឹងពីរជាន់ទៅលើ ហើយខាងក្រោមហ្នឹងលាតនៅជាន់ទី១ ហើយទូលាយក្រោម។

**ស៖** តើទីតាំងនេះ ជាទីតាំងគុកតែម្តង ឬក៏ជាៗកន្លែងអី ដែលលោកអាចបញ្ជាក់បានច្បាស់ទេ?

**ឆ៖** បាទ អាហ្នឹងអត់មែនគុកទេ មន្ទីរតំបន់គេហ្នឹងតែម្តង ផ្ទះថ្ម ផ្ទះតំបន់គេហ្នឹង។

**ស៖** អ៊ីចឹងកន្លែងហ្នឹង វាមិនជាកន្លែងទីតាំងគុកទេ គ្រាន់តែកន្លែងអគារតំបន់ដែលគេប្រើប្រាស់សម្រាប់ឃុំខ្លួនរបស់លោក និងមនុស្សមួយចំនួនដែលត្រូវចាប់ខ្លួននៅពេលនោះ។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើនៅក្នុងអគារហ្នឹង មានមនុស្សប៉ុន្មាននាក់ដែលគេឃុំខ្លួនជាមួយលោក?

**ឆ៖** ក្នុងនោះ ខ្ញុំតាមខ្ញុំចាំបានហ្នឹង វា៨០ជាង។

**ស៖** តើនៅក្នុងចំណោមអ្នកឃុំខ្លួនជាមួយលោកហ្នឹង មានស្ត្រី និងកុមារដែរឬទេ?

**ឆ៖** បាទ មាន ស្ត្រីក៏មាន កុមារក៏មាន ដូចថាម៉ាពោះពីណា បងប្អូនកូនចៅប៉ុន្មាន ចាប់ទៅទាំងអស់ហ្នឹង។

**ស៖** ចុះឈ្មោះ វ៉ា និងឈ្មោះ ផាន ឃោន ដែលលោកមានប្រសាសន៍អម្បាញ់មិញហ្នឹង ត្រូវគេឃុំនៅកន្លែងតែមួយជាមួយលោក ឬក៏យ៉ាងណា?

**ឆ៖** បាទ ហ្នឹងអត់ឃើញឃុំជាមួយពួកខ្ញុំទេបាទ។

[០៩:៤៩:២៧]

**ស៖** អម្បាញ់មិញ លោកមានប្រសាសន៍ថា អគារនោះមានពីរជាន់ តែជាន់ខាងក្រោម គេដាក់លោក ចុះជាន់ខាងលើ តើមានគេដាក់មនុស្សឃុំឃាំងដែរទេ?

**ឆ៖** បាទ ដល់ពេលចាប់ពួកខ្ញុំទៅនុ៎ង អត់មានសិទ្ធិណាទៅមើលលើមើលក្រោមហ្នឹង ម៉េចប៉ានទៅណា មានតែនៅគេចងជាប់រដឹកទៅហ្នឹង។ មិនដឹងពីណានៅលើណានៅក្រោម មិនដឹងគេយកទៅវ៉ៃចោលវ៉ៃអីមិនដឹង តាមខ្ញុំស្មានទៅកាលនោះ។

សៈ តើលោកជាប់ឃុំនៅទីនោះអស់រយៈពេលប្រហែលប៉ុន្មានដែរ លោកអាចចាំបានទេ?

ឆៈ បាទ ខ្ញុំចាំបាន មួយខែ។

សៈ ឥឡូវនិយាយអំពីក្នុងគុកវិញម្ដង តើអ្នកដែលជាប់ឃុំជាមួយលោកហ្នឹង ត្រូវគេចង ឬក៏ត្រូវគេដាក់ខ្នោះ ឬក៏គេទុក មិនដាក់ខ្នោះអីទេ តើលោកអាចរៀបរាប់បានទេ?

ឆៈ បាទ អ្នកដែលចាប់ទៅ មនុស្សធំៗហ្នឹង ចងទាំងអស់ ទុកតែក្មេងៗតូចៗ គេអត់ចង។

សៈ តើនៅពេលដែលលោកជាប់ឃុំហ្នឹង គេឲ្យលោកហូបអាហារមួយថ្ងៃប៉ុន្មានពេល ហើយតើគ្រប់គ្រាន់ដែរឬទេ?

ឆៈ បាទ ហ្នឹងសូមបញ្ជាក់ថា រឿងអ្នកទោសដែលគេឲ្យហូបឆ្អែតទេ បាយស្រូបផ្លែល្ពៅអីមួយចានចង្កឹះៗតែប៉ុណ្ណឹង។

សៈ និយាយអំពីអនាម័យវិញម្ដង។ តើនៅក្នុងអគារនុ៎ងមានអនាម័យល្អត្រឹមត្រូវឬទេ ឬក៏មានសត្វល្អិត សត្វអីដែលរំខានដល់អ្នកទោសដែរឬទេ?

ឆៈ បាទ តាមការចងចាំរបស់ខ្ញុំហ្នឹង វា ព្រោះប៉ុន្មានហើយដែលមនុស្សជាប់គុក មនុស្សគេចាប់ គេចង ហើយមិនដែលគេទុកឲ្យមានល្អទេ។

សៈ លោកចង់និយាយ -- ខ្ញុំចង់បញ្ជាក់អំពីអនាម័យនុ៎ង តើវាៗវាស្អាត ឬក៏វាយ៉ាងម៉េចដែរ លោកអាចបញ្ជាក់បានច្បាស់ទេ?

ឆៈ បាទ រឿងអនាម័យ វាគ្មានហើយអនាម័យនុ៎ង។

សៈ មុននេះបន្តិច លោកមានប្រសាសន៍ថា អ្នកទោសប្រុសៗត្រូវគេចង។ ចុះនៅពេលដែលលោកត្រូវទៅបន្ទប់ទឹក បត់ដៃ បត់ជើងហ្នឹង តើធ្វើរបៀបម៉េចដែរ បានអាចទៅបាន?

ឆៈ បាទ បញ្ហាហ្នឹង ហៅអ្នកយាម អ្នកយាមដឹកយើងទៅបត់ជើង បង្គន់។

[០៩:៥២:៤៩]

សៈ តើអំឡុងពេលមួយខែដែលលោកស្នាក់នៅក្នុងអគារនោះ ត្រូវគេឃុំខ្លួនក្នុងអគារនោះ តើលោកមានឃើញមានអ្នកជំងឺ អ្នកទោសដែលមានជំងឺទេ?

ឆៈ បើតាមខ្ញុំឃើញហ្នឹង អ្នកជំងឺហ្នឹង គឺកើតជំងឺកមរមាស់ហ្នឹងតែម្ដង ខ្លាំង។

សៈ តើគេមានផ្ដល់ថ្នាំព្យាបាលដល់អ្នកជំងឺទេ?

ឆៈ បាទ អត់មានទេ ជូនថ្នាំសង្កូវអី។

**ស៖** តើមានអ្នកជំងឺណាម្នាក់ស្លាប់ដោយសារការអត់អាហារ ដោយសារការឃ្លាន ឬក៏ដោយសារមានជំងឺទេ នៅកន្លែងដែលលោកកំពុងជាប់ឃុំនុ៎ង?

**ឆ៖** បាទ ក្នុងរយៈពេលមួយខែហ្នឹង ដូចអត់មានពីណាស្លាប់អីទេនុ៎ង។

**ស៖** ឥឡូវខ្ញុំចង់ដឹងអំពីការសួរចម្លើយវិញម្តង។ តើរយៈពេលដែលលោកជាប់ឃុំនៅទីនោះមួយខែហ្នឹង តើលោកមានទៅ ធ្លាប់ត្រូវបានគេសួរចម្លើយទេ?

**ឆ៖** បាទ អត់មានសួរចម្លើយទេ ប៉ុន្តែហៅថា អ្នូស! ពួកឯងសុទ្ធតែពួកជនក្បត់ តែប៉ុណ្ណឹង។

**ស៖** នៅក្នុងឯកសារកិច្ចសម្ភាសន៍មួយរបស់លោក គឺឯកសារកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត គឺឯកសារ *អ៊ីស្រី* -- E3/7694, ERN ជាភាសាខ្មែរ 00236706, ERN ជាភាសាអង់គ្លេស 00242144, ERN ជាភាសាបារាំង 00276803។ នៅពេលដែលគេសួរ មានសំណួរមួយដែលគេសួរថាតើ "ការសួរចម្លើយមានធ្វើទារុណកម្មឬទេ?" លោកឆ្លើយថា "ការសួរចម្លើយ មិនមានទារុណកម្មទេ តែមានការសម្លុតគំរាមខ្លាំងៗ ដោយហេតុថាខ្ញុំធ្វើការជាមួយឈ្មោះ សាន វ៉ា ដែលជាគណៈស្រុក បែរជាមិនដឹងរឿងថ្នាក់លើ"។ តើអ្វីដែលខ្ញុំអាននេះ អាចរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** ត្រង់ហ្នឹងដូចមានភ្លេចខ្លះ ព្រោះអត់បានចាប់អារម្មណ៍ និងកត់ត្រាទុកអីផង វាយូរដែរ។

[០៩:៥៥:៥៥]

**ស៖** ឥឡូវបែរមកពីទាក់ទងនឹងការសម្លាប់អ្នកទោសវិញម្តង តើរយៈពេលដែលលោកជាប់ឃុំនៅកន្លែងហ្នឹង តើមានគេយកអ្នកទោសទៅសម្លាប់ដែរឬទេ?

**ឆ៖** បាទ ជនខាងក្រោម ព្រោះខ្ញុំនៅក្រោមហ្នឹង អត់មានយកទៅសម្លាប់ទេ ពេលដែលខ្ញុំជាប់គុកមួយខែហ្នឹង។

**ស៖** អ៊ីចឹងលោកនៅក្នុងចំណោមអ្នកដែលឃុំជាមួយលោកហ្នឹង មិនត្រូវមាន បានគេយកទៅសម្លាប់ទេ។ ចុះពាក់ព័ន្ធជាមួយនឹងបញ្ហាមួយទៀត គឺបញ្ហាពាក់ព័ន្ធជាមួយនឹងការឃុំខ្លួនលោកនុ៎ងវិញថាតើនៅពេលដែលគេចាប់ខ្លួនលោកទៅឃុំហ្នឹង តើនៅពេលហ្នឹង គេមានផ្តល់ឱកាសឲ្យលោកការពារខ្លួន ឬក៏ផ្តល់មេធាវីផ្តល់អីឲ្យលោកដែរឬទេ មុននឹងគេឃុំខ្លួនលោកហ្នឹង?

**ឆ៖** បាទ តាមខ្ញុំចាំថា អត់មានមេធាវីមានអីទេ។ តាមអំពើពាលដែលវាតែម្តង។

**ស៖** តាមអ្វីដែលលោកចាំ តើនៅក្នុងរបបខ្មែរក្រហមនេះមានចៅក្រម មានមេធាវី ឬក៏យ៉ាង

ម៉េចដែរ អាចមានចៅក្រម មានមេធាវី ឬមានតុលាការអីដែរ?

**ឆ៖** បាទ ដូចអត់មានឃើញទេ ដូចអត់ដឹង អត់មានមេធាវី អត់មានតុលាការ អត់មានអីទាំងអស់។

**ស៖** ឥឡូវខ្ញុំមានសំណួរមួយទៀត ពាក់ព័ន្ធនឹងការងារនៅក្នុងពេលដែលលោកជាប់ឃុំហ្នឹង។ តើលោក និងអ្នកទោសផ្សេងហ្នឹងត្រូវគេបង្ខំឱ្យធ្វើការងារអីដែរ នៅពេលដែលលោកជាប់គុកហ្នឹង មានគេបង្ខំឱ្យធ្វើការងារទេ?

**ឆ៖** បាទ តាមការខ្ញុំចាំហ្នឹង គឺពួកអ្នកយាមហ្នឹងវាជញ្ជូនគ្រាប់ក្រចៅហ្នឹងឱ្យទៅវ៉ៃក្នុងគុកហ្នឹង វ៉ៃយកគ្រាប់ហ្នឹង។

**ស៖** ខ្ញុំមានសំណួរមួយពីរទៀតទេ ដោយសារពេលវេលាអស់ហើយ។ តើនៅពេលដែលគេឱ្យលោកវ៉ៃខ្មៅហ្នឹង តើគេឱ្យឧបករណ៍អ្វីខ្លះ ហើយលោកចាប់ផ្ដើមធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន លោកអាចប្រាប់បានទេ?

**ឆ៖** អ៊ីចឹងតាមខ្ញុំចាំមើល ពួកវាហុចលាយៗទៅឱ្យហ្នឹង ប៉ុន្តែយើងដំជាមួយ ជាន់ជាមួយជើងជាមួយហ្នឹងអ៊ីចឹងទៅ បើដៃគេចងទប់អ៊ីចឹងទៅ ដៃគេចង ជើងជាន់ៗហ្នឹង បំបែកគ្រាប់ក្រចៅហ្នឹង។

**ស៖** តាមដែលលោកមានប្រសាសន៍ បានន័យថាគេមិនផ្ដល់ឧបករណ៍អីឱ្យលោកទេ គេបែរចងអ្នកទោស ហើយឱ្យអ្នកទោសបំបែកគ្រាប់ខ្មៅហ្នឹង ដោយប្រើជើង។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតត្រឹមត្រូវហើយ។

[០៩:៥៩:២៥]

**ស៖** តើលោកចាប់ផ្ដើមធ្វើការពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មានដែរ?

**ឆ៖** ធ្វើហ្នឹងអត់មានកំណត់ទេ ធ្វើហ្នឹង ធ្វើប្រហែលជាមួយម៉ោង ពីរម៉ោងអ៊ីចឹង គេឈប់ហើយ។

**លោក សេង លាង៖**

លោកប្រធាន ដោយសារពេលវេលាអស់ហើយ ខ្ញុំសូមប្រគល់វេទិកានេះជូនសហព្រះរាជអាជ្ញាអន្តរជាតិមានសំណួរបន្ត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** អរុណសួស្ដីលោកសាក្សី! លោកបានឆ្លើយថា លោកត្រូវបានគេចាប់ខ្លួន តើលោកនៅនឹក

ឃើញទេ គេចាប់ខ្លួនលោកនៅពេលណាដែរ? សូម្បីតែចាំត្រឹមឆ្នាំក៏បានដែរ?

**លោក ចាន់ ទូយ៖**

**ឆ៖** ខ្ញុំចាំប្រហែលជា -- តាមខ្ញុំចាំ៧៧ – ឆ្នាំ៧៧។

**ស៖** សូមអរគុណ។ ចុះខែចាំទេ ខែណាដែរលោក?

**ឆ៖** ខែហ្នឹង ខែ១១ ប៉ុណ្ណឹងហើយខែនោះ។ ខ្ញុំអត់បានកត់ត្រាអីទុកដែរ។

**ស៖** តើអ្នកណាជាអ្នកចាប់ខ្លួនលោក?

**ឆ៖** អ្នកយកឡានទៅយកខ្ញុំបាទ គឺឈ្មោះ កាន់ ជាមួយ សុត។

**ស៖** តើអ្នកទាំងពីរជាអ្នកណាដែរ? <តើ>អ្នកទាំងពីរនេះជា<ប្រភេទកងកម្លាំង>សន្តិសុខ <ឬ?> <តើលោកអាចពន្យល់បាន>ទេ?

**ឆ៖** បើតាមរបបនុ៎ងហ្នឹង គឺខាងសន្តិសុខគេបាទ។

[១០:០១:៥០]

**ស៖** តើជាសន្តិសុខស្រុក ឬក៏ជាសន្តិសុខតំបន់លោកដឹងដែរទេ?

**ឆ៖** បាទ ស្រុកហ្នឹងគ្មានសន្តិសុខទេ មានតែតំបន់ទេ មានសន្តិសុខ។

**ស៖** សូមអរគុណ។ តើលោកធ្លាប់ដែលដឹងថា អ្នកណាជាអ្នកបញ្ជាឲ្យចាប់ខ្លួនលោកដែរទេ?

**ឆ៖** ខ្ញុំបាទអត់ដឹងពីអ្នកឲ្យអ្នកចាប់អ្នកចងទេ ប៉ុន្តែតាមខ្ញុំដឹង គេចាប់ វ៉ា អីទៅ ចាប់ពួកតា -- បាត់ តាខាំភួន អត់អីទៅហ្នឹង បានគេចាប់ពួកខ្ញុំក្រោមៗមកជាកូនជាចៅគេ ជាសែស្រឡាយ។

**ស៖** បន្ថែមទៅលើការចាប់ខ្លួនលោក តើក្នុងសមាជិកក្រុមគ្រួសារលោកមានអ្នកណាត្រូវបានគេចាប់ខ្លួនដែរទេ?

**ឆ៖** បាទ ចាប់ទាំងអស់មួយពូជតែម្តង ទាំងម្តាយ ទាំងប្អូន ទាំងអី ចាប់ទាំងអស់។

**ស៖** នៅពេលនោះ តើលោករៀបការហើយឬនៅ?

**ឆ៖** បាទ ខ្ញុំរៀបការហើយ។

**ស៖** លោកមានកូនដែរពេលនោះ?

**ឆ៖** អត់ទាន់មានទេ។

**ស៖** លោកជម្រាបជូនតុលាការព្រឹកមិញថា លោកអាយុ៥៦មកដល់ថ្ងៃនេះ។ <ដូច្នេះនៅឆ្នាំ ១៩៧៧ គឺ៣៩ឆ្នាំមុន> បើខ្ញុំគិតលេខនព្វន្តនោះ គឺនៅពេលនោះលោកអាយុប្រហែលជា១៧ឆ្នាំ។ តើការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គណនាលេខរបស់ខ្ញុំនេះ ត្រឹមត្រូវដែរទេ?

**ឆ៖** ហ្នឹងតាមខ្ញុំការហ្នឹង ការតាំងពីនៅតូចដែរហ្នឹងបាទ។

**ស៖** ដូច្នេះ លោកក៏គិតថាលោកអាយុប្រហែលជា ១៧ឆ្នាំ<ដែរ>?

[១០:០៥:០៦]

**លោក វ៉ិចទ័រ កូប៉េ៖**

<>លោកប្រធាន <ខ្ញុំគិតថា>សហព្រះរាជអាជ្ញាគិតនេះ<មិនត្រូវទេ។ បើខ្ញុំគិតមិនខុសទេ> គាត់<កើត>នៅថ្ងៃទី១៧ ឧសភា <៥៦>។ ដូច្នេះ គិតឃើញថា ពេលនោះ គាត់អាយុ២១ហើយ មិនអាយុ១៧ទេ <នៅឆ្នាំ៧៧នោះ>។

**លោក នីកូឡាស គូមជែន៖**

<ខ្ញុំគិតថា ការខុសគ្នានោះគឺត្រង់ថា> សាក្សីព្រឹកមិញ ជម្រាបជូនតុលាការថា គាត់អាយុ៥៦ មកដល់ថ្ងៃនេះ។ អ៊ីចឹងគាត់<មិនមែនកើតឆ្នាំ៥៦ទេ ប៉ុន្តែគាត់អាច>កើតនៅក្នុងឆ្នាំ៦០ ឬក៏ឆ្នាំ១៩៥៩ នេះ<ជាអ្វីដែលសាក្សីគាត់និយាយថា គាត់អាយុ៥៦ឆ្នាំ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ពិតហើយ ប៉ុន្តែនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គឺគាត់កើតនៅថ្ងៃទី១៧ ឧសភា <1976 *(ស៊ីក)* វាមិនសំខាន់ណាស់ណាទេ ប៉ុន្តែ -->

**<លោក នីកូឡាស គូមជែន៖>**

<មិនអីទេ ខ្ញុំនឹងបន្តទៅទៀត។>

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអន្តរជាតិ គប្បីសួរបញ្ជាក់អំពីថ្ងៃខែឆ្នាំកំណើតនេះឱ្យបានច្បាស់លាស់ទៅ ផ្ទៀងផ្ទាត់រវាងសក្ខីកម្មដែលគាត់ផ្តល់ចំពោះសហចៅក្រមស៊ើបអង្កេត អ្នកស៊ើបអង្កេតនៃការិយាល័យ សហចៅក្រមស៊ើបអង្កេតកន្លងមក ហើយជាមួយនឹងអ្វីដែលគាត់បានឆ្លើយចំពោះមុខអង្គជំនុំជម្រះនៅ ពេលនេះ ដើម្បីផ្ទៀងផ្ទាត់ផ្លូវផ្គងមើលថាចម្លើយណាដែលសមស្របជាមុនសិន មុននឹងតាំងសំណួរពាក់ព័ន្ធនឹងបញ្ហានេះតទៅមុខទៀត។

**លោក នីកូឡាស គូមជែន៖**

បាទ លោកប្រធាន។

[១០:០៥:២៨]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី លោកប្រហែលជាអាចជួយយើងខ្ញុំបាន។ យើងមានកំណត់ហេតុស្តាប់ចម្លើយរបស់លោកនៅក្នុងឆ្នាំ២០០៨ គឺគេបានសម្ភាសលោកនៅក្នុង<>ទីរួមខេត្តរតនគិរី ហើយនៅក្នុងកិច្ចសម្ភាសន៍នោះលោកបញ្ជាក់ថា ថ្ងៃខែឆ្នាំកំណើតរបស់លោកនោះ គឺ១៧ ឧសភា ឆ្នាំ១៩៥៦។ តើនេះជាខែឆ្នាំកំណើតរបស់លោក<ឬ? ឬ>លោកមកដល់ថ្ងៃនេះ មានអាយុ៥៦<ឆ្នាំ?> ឬក៏លោកកើតនៅឆ្នាំ១៩៦០? <តើលោកដឹងទេ?>

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ តាមអាយុខ្ញុំហ្នឹង តាមម្តាយគាត់ប្រាប់ កើតប៉ុណ្ណឹងៗ ខ្ញុំក៏ថាប៉ុណ្ណឹងតាមគាត់ទៅ ខ្ញុំអត់ដឹងថាថ្ងៃខ្ញុំកើតប៉ុន្មានដែរ។

**ស៖** សូមអរគុណ។ នៅពេលដែលគេចាប់ខ្លួនលោក តើមានរឿងរ៉ាវអ្វីកើតឡើងចំពោះប្រពន្ធរបស់លោក?

**ឆ៖** បញ្ហាហ្នឹង អង្កាល់គេចាប់ខ្ញុំហ្នឹង ក៏ចាប់ទាំងប្រពន្ធទៅដែរហ្នឹង មានបញ្ហាហ្នឹង ដឹងកាលនោះ អស់សង្ឃឹមរៀងៗខ្លួនហើយ ដឹងថាៗ ងាប់ហើយគ្មានរស់ទេ ដែលពួកអស់ហ្នឹងចាប់ហើយ។

**ស៖** តើមានមូលហេតុអីដែលនាំឲ្យលោកអស់សង្ឃឹមនៅពេលដែលគេចាប់ខ្លួន? <តើលោកបានឃើញអ្វី ដែល>នាំឲ្យលោកអស់សង្ឃឹម<ពេលគេចាប់ខ្លួនលោកនោះ>?

**ឆ៖** បាទ កាលរបបប៉ុលពតហ្នឹង ដែលចាប់ហើយមិនដែលឃើញរស់ អ៊ីចឹងហើយបាននាំគ្នាអស់សង្ឃឹមបាទ។ តែចាប់ហើយ ដឹងថាងាប់ អ៊ីចឹងហើយបានអស់សង្ឃឹម។

**ស៖** លោកបានបញ្ជាក់ថា សាច់ញាតិរបស់លោក ក៏ត្រូវបានចាប់ខ្លួនដែរ ចាប់ជាច្រើននាក់ នេះបើខ្ញុំស្តាប់ចម្លើយលោកមិនច្រឡំទេ ដោយសារថា លោកថា អ្នកទាំងអស់នេះ ជាប់ខ្សែជាមួយនឹងខាំភួន ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ។

[១០:០៧:៥៧]

**ស៖** តើហេតុអ្វីបានជានៅក្នុងរបបនោះ <-- ឬហេតុអ្វីបានជា>ក្នុងករណីនេះ <មនុស្ស>ត្រូវបានគេចាប់ខ្លួន<>ដោយសារតែជាប់ពាក់ព័ន្ធទៅនឹងអ្នកដទៃ តើលោកអាចជម្រាបជូនតុលាការបានទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ តាមខ្ញុំដឹងខ្លះហ្នឹងគឺថា ពេលរបបប៉ុលពតហ្នឹង តែចាប់ឪពុក គឺចាប់ទាំងកូន ចាប់ទាំងម្ដាយ ចាប់ទាំងបង ចាប់ទាំងប្អូនទៅ មួយខ្សែ មួយពូជពង្សអ៊ីចឹងទៅតែម្ដងហ្នឹង ធ្លាប់វាអ៊ីចឹង បានខ្ញុំនិយាយអ៊ីចឹង។

**ស៖** នៅទីតាំងដែលគេឃុំខ្លួនលោកៗថាគេចងលោក។ សូមលោកជម្រាបជូនតុលាការបន្តិចមើល៍ ថាតើគេចងលោកដោយរបៀបណា? គេគ្រាន់តែចងដៃលោកផ្ដោប ឬក៏គេចងលោកភ្ជាប់ទៅនឹងអ្វីមួយ?

**ឆ៖** បាទ តាមដែលពួកវាចងកាលនោះ គឺយកខ្សែមកចងដាក់នឹងកៅអីជើងម៉ាវែងៗ តម្រៀបជើងម៉ាចងដាក់ជើងនឹងជើងម៉ាហ្នឹង ជាប់ៗគ្នារដឹក។ ដល់យប់ចងជើង ដល់ថ្ងៃវាលាជើងឲ្យរើគ្រាប់ខ្មៅតែប៉ុណ្ណឹង។

**ស៖** លោកបានបញ្ជាក់ថា កូន<>ក្មេង<> គេអត់ចងទេ។ តើគេអនុញ្ញាតឲ្យកូន<>ក្មេង<ដើរជុំវិញនោះបានទេ? តើគេអនុញ្ញាតឲ្យលោកនិយាយជាមួយក្មេងៗទាំងនោះទេ>?

**ឆ៖** បាទ ក្មេងៗគេឲ្យនៅក្នុងហ្នឹងទាំងអស់ហ្នឹង ជួនកាលវាសុំទៅបទជើងតូច ជើងធំអ៊ីចឹងវាសុំពួកអ្នកយាមទៅ វាឲ្យចេញយាមទៅ វាមើលអ៊ីចឹងទៅ វាអត់ចងទេ តូចៗ។

**ស៖** <> តើលោកអាចមានលទ្ធភាពនិយាយជាមួយក្មេងៗ ឬក៏និយាយជាមួយនឹងឆ្មាំគុកបានទេ?

**ឆ៖** បាទ រឿងឆ្មាំគុកហ្នឹង អត់ហ៊ានមានសិទ្ធិនិយាយជាមួយពួកគេទេ មានតែនិយាយជាមួយក្មេងៗហ្នឹងបាន។

[១០:១០:៤១]

**ស៖** ចុះលោកមានបានដឹងថា <តើ>អ្នកណាខ្លះ<>គេឃុំឃាំងនៅបន្ទប់ខាងលើនោះ <មិនមែនក្នុងបន្ទប់លោកទេ ប៉ុន្តែក្នុងបន្ទប់ផ្សេងទៀត>?

**ឆ៖** បាទ នៅបន្ទប់ខាងលើនោះអត់ដឹងទេ នៅខាងលើ ដឹងតែខាងក្រោម។

**ស៖** តើលោកមានឃើញគេយកអ្នកណាម្នាក់ចេញទៅក្រៅដែរទេ <នៅពេលយប់> នៅពេល<>លោកនៅ<ទី>នោះ <តើ>ឃើញគេយកមនុស្សចេញទៅក្រៅ<>ទេ?

**ឆ៖** បាទ ខ្ញុំផ្ទាល់អត់មានឃើញទេ។

**ស៖** តើមានអ្នកណាម្នាក់<>នៅក្នុងបន្ទប់របស់លោកហ្នឹងត្រូវបានបាត់ខ្លួនដែរទេ?

**ឆ៖** បាទ នៅក្នុងបន្ទប់ខ្ញុំអត់មានបាត់ខ្លួនទេ ពេលខ្ញុំនៅហ្នឹង នៅជាប់ជាមួយខ្ញុំ។

**ស៖** លោកសាក្សី ខ្ញុំសូមអានចម្លើយរបស់លោកដែលលោកបានឆ្លើយជូនមន្ត្រីស៊ើបអង្កេតនៅឆ្នាំ២០០៨, ERN ជាភាសាបារាំង 00276804, អង់គ្លេស 00242144, ខ្មែរ <00236706>។ មន្ត្រីស៊ើបអង្កេតសួរថា "<តើ>លោកមានដឹងថា អ្នកទោសណាម្នាក់ត្រូវបានគេយកទៅសម្លាប់ចោលអីដែរទេ?" លោកបានឆ្លើយ<>ថា "ខ្ញុំបានឃើញគេយកអ្នកទោសយកទៅសម្លាប់ពីរដង យប់ទី១ គឺឃើញគេយកទៅប្រាំនាក់ យប់ទី២ <មាន>បីនាក់"។ "សំណួរ៖ គេយកទៅសម្លាប់នៅឯណា? ឆ្លើយ៖ <>តាមខ្ញុំដឹងប្រហែលជាគេយកទៅសម្លាប់នៅក្រោយភ្នំក្រោលបន្តិច។ អ្នកទាំងប្រាំបីនាក់នោះ គឺជាបងប្អូនកូនក្មួយផ្ទាល់របស់តាខាំភួន។ ចំណែកបងប្អូន តាហាំ – តា<>ហម វិញមិនមានការចាប់ចងយកទៅសម្លាប់ទេ។" លោកនៅចាំទេថា លោកបានឆ្លើយបែបនេះជូនទៅមន្ត្រីស៊ើបអង្កេត?

**ឆ៖** បាទ អង្កាល់នោះហ្នឹងបានដឹងថាអ៊ីចេះ ដូចខ្ញុំជម្រាបនៅក្នុងនោះមុន ខ្ញុំក៏ភ្លេចចងចាំខ្លះដែរ អង្កាល់ហ្នឹងមានកូនក្មេងរត់ហ្នឹងវាប្រាប់ថា គេដឹកមនុស្សៗទៅ កូនក្មេងតូចៗ ប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹង គ្រាន់តែដឹងថាយកទៅប៉ុន្មាននាក់ៗទេ ប៉ុន្តែបាត់ ដឹងថាគេចាប់ទៅហើយ មានតែយកទៅវ៉ៃចោលតែប៉ុណ្ណឹង ខ្ញុំដឹងអ៊ីចឹង។ ហើយការចងចាំខ្ញុំក៏មិនបានច្បាស់លាស់ដែរអង្កាល់ណោះនោះ។

[១០:១៣:៤៣]

**ស៖** ចុះលោកនៅចាំទេក្នុងចំណោមនាក់ដែលគេយកទៅ<>ហ្នឹង គឺជាសាច់ញាតិកូនក្មួយផ្ទាល់របស់ តាខាំភួន<>?

**ឆ៖** បាទ តាមបាត់ខ្លួនរហូតដល់ឥឡូវហ្នឹង គឺមានតែកូនក្មួយ តាខាំភួន ហ្នឹងទាំងអស់ កូនចៅតាខាំភួន ហ្នឹងទាំងអស់។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន តើគួរឈប់សម្រាកសិន ឬយ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោង១០កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគីថា ពេលដែលចូលម៉ោង១០កន្លះនេះ អង្គជំនុំជម្រះនឹងស្តាប់សារណាភាគីលើសំណើសុំរបស់លោក នួន ជា សូមដាក់បង្ហាញ -- សូមទទួលយកឯកសារមួយដែលជាភាសាដើមហ្នឹង គឺភាសា

អាល្លឺម៉ង់ ដើម្បីយកដេញដោលជាមូលដ្ឋានដេញដោល ស្តាប់សក្ខីកម្មសាក្សី -- អ្នកជំនាញដែលមានរហស្សនាម 2-TCE-88 សូមភាគីជ្រាប។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំង -- បង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងរង់ចាំបង្គាប់ពីយើងមុននឹងនាំសាក្សីចូលមកកន្លែងផ្តល់សក្ខីកម្មជាលើកទី២។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៤:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី អង្គជំនុំជម្រះមានបំណងស្តាប់នូវសារណាផ្ទាល់មាត់របស់ភាគី ពាក់ព័ន្ធនឹងសំណើសុំរបស់សហមេធាវីការពារក្តី នួន ជា សុំប្រើប្រាស់ឯកសារដែលអង្គជំនុំជម្រះ មុននឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-88 ឯកសារ E307/5.2.8 ហើយនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានចេញកាលពីខែមិថុនា ឆ្នាំ២០១៥ ឯកសារ E305/7 អង្គជំនុំជម្រះបានពន្យារការសម្រេចទៅលើភាពអាចទទួលយកបាននៃឯកសារនេះ ដោយរង់ចាំការបកប្រែឯកសារនេះជាភាសាដើម ដែលជាភាសាអាល្លឺម៉ង់ ទៅជាភាសាផ្លូវការប្រើប្រាស់នៅ អ.វ.ត.ក ។

ហើយនាពេលបច្ចុប្បន្ននេះ ឯកសារ E307/5.2.8 ដែលក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំប្រើប្រាស់នោះ ត្រូវបានបកប្រែជាភាសាអង់គ្លេសរួចហើយ។ ហើយកាលពីម្សិលមិញ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងទៅភាគីថា អង្គជំនុំជម្រះមានបំណងស្តាប់នូវសារណាផ្ទាល់មាត់របស់ភាគី ពាក់ព័ន្ធលើភាពអាចទទួលយកបាននូវឯកសារខាងលើ បន្ទាប់ពីការឈប់សម្រាកវគ្គទី១នៃសវនាការព្រឹកនេះ។ ហើយអាស្រ័យហេតុនេះ ជាដំបូង អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមសហព្រះរាជអាជ្ញា ដើម្បីមានឱកាសធ្វើការឆ្លើយតបទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តី

នួន ជា លើឯកសារនេះ។ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំគិតថា ជាការល្អ<ជាងនេះ សម្រាប់យើងក្នុងការឆ្លើយតប> ប្រសិនបើយើងបានស្ដាប់ឮអំពី<អ្វីដែលជាជំនឿរបស់> នួន ជា <>ពាក់ព័ន្ធ<>ទៅនឹង<សក្ខីកម្មរបស់អ្នកជំនាញ ដែលកំពុងផ្ដល់សក្ខីកម្មអំពី>ការប្រព្រឹត្តចំពោះជនជាតិចាម <ពីឯកសារនេះ>។ <>

<យើងអត់ឃើញវានៅចំណុចនេះទេ> ប្រហែលជា<>គាត់<អាច>ពន្យល់បន្តិចសិន <ហើយយើងនឹងអាចឃើញវា>។

**ប្រធានអង្គជំនុំ៖**

បាទ១ ដើម្បីច្បាស់លាស់ ព្រោះបញ្ហានេះវាយូរហើយ ហើយដើម្បីមានភាពច្បាស់លាស់ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី នួន ជា ដើម្បីឡើងបង្ហាញនូវសំណើសុំរបស់ខ្លួន និងភាពចាំបាច់ និងមូលដ្ឋានសមស្រប តាមផ្លូវច្បាប់ដែលនៃសំណើរបស់ខ្លួន ដើម្បីភាគីដទៃទៀតអាចយល់បាន ហើយនិងមានមតិយោបល់លើបញ្ហាសំណើរបស់លោក។

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំនឹងបញ្ជាក់នៅពេលនេះ គឺថាអ្វីដែលយើងកំពុងតែនិយាយគឺជាឯកសារ<ដើម>ជាភាសាអាល្លឺម៉ង់<>។ នេះគឺជាឯកសារដែលបានព្រាងឡើងដោយសេវាសន្តិសុខអាល្លឺម៉ង់ <>ខាងកើត ដែលជាភាសាអាល្លឺម៉ង់ គេហៅថា ស្តាហ្ស៊ី៖ <អេស-ធី-អេ-អេស-អាយ>។ <នៅពេលមួយនោះ> យើងបានទទួលពីអ្នកជំនាញលើផ្នែកនេះ<>នូវ<ឯកសារថតចម្លង>របស់សេវាសន្តិសុខអាល្លឺម៉ង់ខាងកើត។

[១០:៣៨:៥១]

ផ្នែកសំខាន់នៃឯកសាររបស់អាល្លឺម៉ង់ខាងកើតនេះ គឺ<>មាននូវឯកសារមួយដែលគេហៅថា *<គុធប៊ីយូក្រាហ្វី៖ ខេ-យូ-អ័រ-ហ្សេត ប៊ី-អាយ-អូ-ជី-អ័រ-អេ-ភី-អេច-អាយ-អ៊ី បកប្រែ>*ជាភាសា<អង់គ្លេស>ថា "ប្រវត្តិរូបសង្ខេប"។ <អ្វីដែលបានកើតឡើងនៅពេលនោះ ដូចដែលយើងអាចស្រង់ចេញពីឯកសារនេះ> គឺមានផ្ដល់នូវព័ត៌មានមួយចំនួនទាក់ទងទៅនឹងកម្មាភិបាលខ្មែរក្រហម ដែល<>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01217189



ពួកខាងចារកម្មវៀតណាម <នៅឆ្នាំ៧៧ ឬឆ្នាំ៧៨ ហើយអាចនៅឆ្នាំ៧៩> បានធ្វើការសរសេរប្រវត្តិរូបសង្ខេបរបស់សមាជិក នៃរណសិរ្សសង្គ្រោះជាតិកម្ពុជា។ ប្រវត្តិរូបដែលសរសេរដោយវៀតណាមនេះ គឺត្រូវបានបញ្ជូនទៅដៃគូជាអាល្លឺម៉ង់ខាងកើត ហើយ<គេ>បានធ្វើការបកប្រែ<>ឯកសារនេះពីភាសាវៀតណាមមក។ យើងទទួលបានបណ្តុំនៃប្រវត្តិរូបសង្ខេបទាំងនេះ ហើយខ្ញុំសូមបញ្ជាក់ថា គឺមានឈ្មោះមនុស្ស ប្រាំបួននាក់ ដែលនៅពេលនេះយើងគិតថាជាមនុស្សដែលសំខាន់ ហើយមានភាពពាក់ព័ន្ធខ្លាំង។ យើង<>មានប្រវត្តិរូប<សង្ខេប>របស់ ហេង សំរិន, ហ៊ុន សែន, ជា ស៊ីម, ប៉ែន សុវណ្ណ, ហោ ណាំហុង, កែវ ចិន្តា, ប៉ែន ណាវុធ, អ៊ុក ប៊ុនឈឿន និង ម៉ាត់ លី។ ដូចដែលខ្ញុំបានបញ្ជាក់រួចហើយ គឺមានប្រវត្តិរូបរបស់អ្នកដទៃទៀត ប៉ុន្តែខ្ញុំសូមផ្តោតតែទៅលើមនុស្សប្រាំបួននាក់នេះ។ នៅក្នុងប្រវត្តិរូបទាំងអស់នោះ គឺយើងបានឃើញ ថាតើពួកគេបានធ្វើអ្វី ក្រោយពេលដែលពួកគេបានចូលបដិវត្តន៍ ហើយនិងអ្វីដែលពួកគេបានធ្វើការប្រឆាំងនឹងបក្សកុម្មុយនីស្តយកម្ពុជា <នៅពេលណាមួយនោះ>។ ដូច្នេះ ខ្ញុំជឿជាក់ថា ប្រវត្តិរូបប្រាំបួននាក់<នេះ> និងមនុស្សដទៃទៀតហ្នឹង គឺវាមានភាពពាក់ព័ន្ធ ហើយវាសំខាន់ផងដែរ ក្នុងការស្វែងរកការពិត។ ជាពិសេស គឺវាផ្តល់ឱ្យយើងឃើញនូវទិដ្ឋភាពមួយដែលច្បាស់លាស់ជាងមុន អំពីអតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា<មួយណា>ដែលរៀបចំឡើងដោយវៀតណាម ហើយប្រហែលជា<ពួកគាត់>អាចមានតួនាទីមួយនៅក្នុង<ការប្រឆាំង>បក្សកុម្មុយនីស្តកម្ពុជា <ព្រោះ>ថាពួកគាត់ជាអ្នកដែលមានឋានៈខ្ពង់ខ្ពស់ផងដែរ។

ពិសេសជាងនេះទៅទៀត នៅពេលដែលយើងនិយាយទៅដល់អ្នកជំនាញ យើងផ្តោតជាសំខាន់ទៅលើការចោទសួរសំណួរទាក់ទងទៅនឹងប្រវត្តិរូបនេះ អាចថាសួរតែទៅលើមនុស្សបីបួននាក់ ឬក៏អាចដល់ប្រាំនាក់ <>អំពីអ្នកដែលយើងជឿជាក់ថា មានតួនាទីសំខាន់នៅក្នុងតំបន់២១ <ឬធំទូលាយជាងនោះគឺនៅ>ភូមិភាគបូព៌ានោះ។

[១០:៤២:៤០]

ដូចដែលខ្ញុំបានបញ្ជាក់កាលពីម្សិលមិញ នៅពេលដែលខ្ញុំសួរសាក្សី។ យើងជឿជាក់ថា ហេង សំរិន <មានតួនាទីសំខាន់> ក្នុងនាមជាមេបញ្ជាការយោធា និងជានាយសេនាធិការរង<នៅភូមិភាគបូព៌ា>នៅក្នុងឆ្នាំ៧៥។ <ដូចគ្នានោះដែរសម្រាប់>សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ <ជាការពិត> អ៊ុក ប៊ុនឈឿន <ជាអនុលេខា>តំបន់២១ ហើយគាត់ជាមនុស្សដ៏សំខាន់មួយ ពាក់ព័ន្ធទៅនឹងហេតុការណ៍ <-- ពាក់ព័ន្ធទៅនឹង>ជនជាតិចាម។ <>ដូចគ្នាចំពោះ ម៉ាត់ លី ដែលឈ្មោះរបស់គាត់ត្រូវបាន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គេកោសលុបចេញ <ពី>ប្រវត្តិរូប<សង្ខេប>ដែលបានពង្រាង ដែលបានសរសេរឡើង គឺប្រាកដណាស់ថាជាឈ្មោះ ម៉ាត់ លី។ ហើយមនុស្សផ្សេងទៀត ដែលខ្ញុំទើបតែលើកឡើងមុននេះបន្តិច គឺដូចជា កែវ ចិន្តា ដែលជាប្រធានតុលាការជំនុំជម្រះ ប៉ុល ពត, អៀង សារី ទោះបីថា គាត់មិនសូវមានភាពពាក់ព័ន្ធសម្រាប់<អ្នកជំនាញ>ដែលត្រូវមកដល់នេះ<។> ហើយដូចគ្នាចំពោះ ហោ ណាំហុង ហើយ <គាត់>អាចមានភាពសំខាន់<ពេលយើងនិយាយអំពី>មន្ទីរ ស-២១ <នៅពេលណាមួយនោះ> ហើយនិងព្រៃស<>។ ដូច្នេះខ្ញុំគិតថា <ការពណ៌នារបស់>ប្រវត្តិរូបទាំងអស់នេះគឺ<>សំខាន់ ព្រោះ<ពួកគេ>ពាក់ព័ន្ធទៅនឹងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាជាន់ខ្ពស់ដែលបានរត់គេចចេញចូលទៅវៀតណាម។ ជាពិសេស គឺមានឯកសារមួយទាក់ទងទៅនឹងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលថាគាត់ផ្តាច់ខ្លួនចូលទៅវៀតណាម នៅខែមិថុនា ឆ្នាំ៧៧។ ហើយឯកសារនេះក៏បាននិយាយអំពី ស្មារតីបដិវត្តន៍របស់មនុស្សទាំងអស់នេះ បើយោងតាមវៀតណាម ហើយនៅពេលដែលពួកគេចាប់ផ្តើមប្រឆាំងជាមួយបក្សកុម្មុយនីស្តកម្ពុជា ។ ដោយសារមានហេតុផលជាច្រើនបែបនេះហើយ ទើបយើងខ្ញុំជឿជាក់ថា *ស្តាហ្វ៊ី* ឬក៏ *<គុចប៊ីយូ>ក្រាហ្វី* <មានភាពពាក់ព័ន្ធ> ដើម្បីស្វែងរកឲ្យឃើញនូវការពិត។

[១០:៤៥:២០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមានសំណួរមួយ គឺថាសំណួរនោះពាក់ព័ន្ធមួយផ្នែក<>ទៅនឹងតម្លៃនៃភស្តុតាង <ប៉ុន្តែមិនត្រឹមតែប៉ុណ្ណឹងទេ> ខ្ញុំ<កត់សម្គាល់>ឃើញថាលោកនិយាយថា ឯកសារនោះសំខាន់ ដូច្នេះខ្ញុំគិតថា លោកគិតថាឯកសារហ្នឹងអាចជឿជាក់បាន<> ហើយ<លោកចង់ឲ្យ>អង្គជំនុំជម្រះ<>ជឿជាក់<លើឯកសារហ្នឹង>ដែរ។ ប៉ុន្តែបញ្ហាមួយដែលលោកបានលើកឡើង គឺថាវា<បានឆ្លងកាត់>ការបកប្រែ<ទៅជាភាសាអាល្លឺម៉ង់>។ ឯកសារនេះ<បាន>បកប្រែ<>ពីវៀតណាម<>។ បានន័យថាយើងអត់មានឯកសារដើម<>ទេ។ <នេះជាការយល់ឃើញរបស់ខ្ញុំ ហើយវាគ្រាន់តែជាការសង្កេតមួយប៉ុណ្ណោះ។> ប៉ុន្តែចំណុចទី២ <ខ្ញុំឯកភាពថា វាគួរឲ្យចាប់អារម្មណ៍ ពេលដែលវាចូលទៅដល់កិច្ចការផ្ទៃក្នុងរបស់ភ្នាក់ងារចារកម្ម ប៉ុន្តែពេលដែលចូលទៅដល់ព័ត៌មានដែលផ្ទុកនៅក្នុងនោះ> ថាតើ<លោក>មាន<ព័ត៌មានណាមួយ>ផ្អែកទៅលើមូលដ្ឋាន<>ប្រវត្តិសង្ខេប<ទាំងនេះ ដែលរួមបញ្ចូល>ការវាយតម្លៃ<របស់>អ្នកសរសេរ<ប្រវត្តិរូបនេះទេ? ដូចដែលលោកដឹងហើយថា មូលដ្ឋានផ្អែកតែទៅលើការសម្ភាសន៍បុគ្គលនេះ ឬក៏មានព័ត៌មានអ្វីទៀត? បើមាន ដាក់ចូលមក។> តើលោកអាចបំភ្លឺអង្គជំនុំជម្រះ

បានទេ?

[១០:៤៦:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយនឹងឆ្លើយ ប៉ុន្តែអ្វីដែលយើងដឹង គឺថាឯកសារនេះគឺមាននៅក្នុងបណ្ណសារ *<ខឺ>ស្តាហ្ស៊ី* នៅទីក្រុងបែរឡាំង ហើយយើងអាចចូលទៅពិនិត្យបាន គឺថាគ្រប់គ្នាអាចចូលទៅពិនិត្យបាន។ <សំណួរសួរថា តើនរណាដែល>ពេលនោះ <សេវា>ស៊ើបអង្កេតអាល្លឺម៉ង់ខាងកើត<បានទាក់ទងជាមួយក្នុងការបកប្រែ និងថា តើនរណាដែលជា>ដៃគូ<>វៀតណាម <គឺមិនច្បាស់ទេសម្រាប់យើង>។ ដូច្នេះគឺ<>យើង<ត្រូវ>ធ្វើការស៊ើបអង្កេតបន្ថែមទៀត។ <>ប៉ុន្តែដោយសារតែយើងមានធនធានតិច ដូច្នេះ ហើយខ្ញុំគិតថាយើងពឹងផ្អែកទៅលើតែប្រភពព័ត៌មានដែលយើងមានតែប៉ុណ្ណោះ។ មិនមែនបានន័យថា យើងខ្ញុំមិនចង់ឆ្លើយតបទៅនឹងអ្វីដែលលោកស្រីចៅក្រមបានលើកឡើងនោះទេ ប៉ុន្តែអ្វីដែលសំខាន់ គឺថា យើងមានធនធានមានកម្រិត។

ដូច្នេះ ខ្ញុំគិតថានេះជាឯកសារបន្ថែមដែលមានភាពសំខាន់ ហើយដោយសារតែយើងមិនមានធនធានគ្រប់គ្រាន់ ទើបយើងអាចត្រឹមតែប្រើប្រាស់ប្រវត្តិរូបសង្ខេប<របស់អ្នកដើរតួ>សំខាន់ <នៅក្នុងការ>បះបោរ <ហើយអ្នកទាំងនោះពិតជានៅរស់រានមានជីវិត>នៅក្នុងឆ្នាំ៧៩ <ហើយ>ពួកគាត់បានបង្កើតបានជារបបថ្មីនៅថ្ងៃ០៧ មករា ៧៩។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងមានសំណួរទៀត គឺមានពីរករណីទៀតគឺថាមានមនុស្សពីរនាក់ដែលមិនស្គាល់ឈ្មោះ។ <មូលហេតុដែលលោកចង់ឲ្យ>យើងទទួលស្គាល់ ដោយសារ<លោកគិតថា លោកដឹងថា ពួកគេ>ជាអ្នកណា <ព្រោះបើមិនដូច្នេះទេ គ្មានអ្នកណាស្គាល់បុគ្គលទាំងពីរនាក់នេះទេ។>

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាមានបុគ្គលជាច្រើនដែលយើងមិនដឹងថាពួកគាត់ជាអ្នកណាទេ។ <យើងទើបតែទទួលបានពួកគេមក។> <>ដោយផ្អែកទៅលើការពណ៌នា គឺថាគាត់អាចជាមនុស្សដ៏សំខាន់មួយ។ ឧទាហរណ៍ជាក់ស្តែង ដែលយើងអាចថា <៩៥>ភាគរយយើងជឿជាក់ថា ប្រវត្តិ<រូប>ដែលត្រូវបានកោសលុបហ្នឹងគឺជារបស់ ម៉ាត់ លី ព្រោះព័ត៌មានផ្ទាល់ខ្លួននៅក្នុងឯកសារនោះ គឺវាដូចគ្នា ឬក៏ថាសឹងតែដូចគ្នាបេះបិទជាមួយនឹងអ្វីដែលយើងបានធ្វើការស្តាប់ចម្លើយជាដើម។ ប៉ុន្តែមានឈ្មោះមួយចំនួនទៀត ដែល

យើងមិនប្រាកដថាតើជាឈ្មោះរបស់អ្នកណា <ប៉ុន្តែយើងបានដាក់ចូលក្នុងសំណុំរឿង ព្រោះពួកគេអាចមានតួនាទីសំខាន់ខ្លាំង ពេល>យើង<>ឈានទៅដល់ផ្នែកបោសសម្អាត ឬក៏ឈានទៅដល់ជម្លោះ<ប្រដាប់អាវុធ>ផ្ទៃក្នុងរបស់<>កម្ពុជា<ប្រជាធិបតេយ្យ>។

[១០:៤៩:៣៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមការបំភ្លឺមួយ។ ខ្ញុំ លោកចង់សុំឱ្យឯកសារហ្នឹងត្រូវបានទទួលយកបានអង្គជំនុំជម្រះ ដើម្បីយកមកសួរអ្នកជំនាញ ហ៊ីនតុន ឬក៏លោកសូមឱ្យឯកសារហ្នឹងត្រូវបានប្រកាសទទួលយកជាលក្ខណៈទូទៅ ព្រោះថាឯកសារហ្នឹង ពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២។ ខ្ញុំវង្វេងហើយ សូមលោកបំភ្លឺឱ្យច្បាស់អំពីចំណុចនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សំណើខ្ញុំ គឺថាស្នើសុំឱ្យដាក់ចូលជាភស្តុតាង ព្រោះយើងឃើញថា ឯកសារមួយនេះ គឺមានភាពពាក់ព័ន្ធខ្លាំងក្នុងការ<ស្វែងរក>ការពិត ជាពិសេសទាក់ទងទៅនឹងការបះបោរ ហើយនិងជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាម។ <មូលហេតុច្បាស់លាស់ក្នុងការនិយាយអំពី>បញ្ហា<ទាំងនោះ>នៅពេលបច្ចុប្បន្ននេះ គឺ<>បញ្ហា<ដែលយើងចង់បង្ហាញឯកសារ>មួយចំនួន<>ទៅ<>អ្នកជំនាញ។ ព្រោះអ្នក<ទាំងនោះ>មានភាពពាក់ព័ន្ធជាមួយនឹងកម្មាភិបាលជាន់ខ្ពស់នៅក្នុងតំបន់២១ និងភូមិភាគបូព៌ា ដែលនៅពេលនោះ<>មានជនជាតិចាម<ភាគច្រើន>រស់នៅ<>។ ហេតុដូច្នេះហើយទើបខ្ញុំចង់លើកយកឯកសារនេះមកសួរដេញដោលជាមួយអ្នកជំនាញ មិនមែនសួរទាំងអស់ទេ ប៉ុន្តែសួរមួយចំនួន។ ដូច្នេះទើបខ្ញុំស្នើសុំឱ្យទទួលយកឯកសារនេះ ធ្វើជាភស្តុតាង ហើយ<ការស្នើសុំនេះគឺពាក់ព័ន្ធទៅនឹង>ប្រវត្តិរូបសង្ខេបទាំងអស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ<គិតថាវាមានសារៈសំខាន់សម្រាប់ខ្ញុំ ក្នុងការ>ធ្វើការកត់

សម្គាល់នៅពេលនេះ ហើយ<>ភាគី<ប្រហែលជាអាច>ឆ្លើយតបទៅនឹង<ការអង្កេតទាំងអស់របស់> មេធាវីការពារក្តី<>តែម្តង។ យើងខ្ញុំមិនជំទាស់អ្វីទៅនឹងការស្នើសុំរបស់ក្រុមមេធាវី នួន ជា ទេ។ ខ្ញុំ មានការកត់សម្គាល់ពីរពាក់ព័ន្ធទៅនឹងសំណួរដែល<>សួរដោយចៅក្រម <ឡាវែន៍ នៅព្រឹកមិញនេះ>។ ឯកសារមួយចំនួនត្រូវបានទទួលយកជាភស្តុតាងដោយអង្គជំនុំជម្រះរួចមកហើយ ហើយអង្គជំនុំជម្រះ បញ្ជាក់ថា នឹងវាយតម្លៃទៅលើ<>ភស្តុតាងនៅពេលក្រោយ។ <តើមានប្រយោជន៍អ្វីក្នុងករណីឯកសារ បែបនេះ។> ខ្ញុំនឹកឃើញដល់ឯកសារមួយដែលយើងបានស្នើសុំដាក់ជាភស្តុតាង ហើយអង្គជំនុំជម្រះ ទទួលយក គឺឯកសារ E3/9644 ដែលជាសម្រង់ដកចេញពីឯកសាររុស្ស៊ី ដែលដកចេញពីបណ្ណសារវៀ តណាម នៅពេលនោះ <ហើយយើងនៅក្នុងបរិបទ>ជម្លោះប្រដាប់<អាវុធ> ហើយជាសម័យសង្គ្រាម ត្រជាក់។ <>យើងដឹងថា <>ឯកសារចេញមកពីភាគី<មួយ ឬភាគីមួយផ្សេងទៀត>អាចមានខ្លឹម សារបង្កប់ ហើយអាចមានការបកស្រាយផ្សេងៗ <ដែលអាចសំខាន់សម្រាប់>ភាគី<ក្នុងការសួរ សំណួរ>។

[១០:៥២:៥៣]

<ក្នុងករណី>ណាក៏ដោយ ចំពោះការប្រើប្រាស់<ដែល>អង្គជំនុំជម្រះ ឬដោយមេធាវីការពារ ក្តី <ចង់ធ្វើឱ្យឯកសារទាំងអស់នេះស្ថិតក្នុងសេចក្តីសម្រេចរបស់ខ្លួន វាត្រូវមានធាតុផ្សំនៃបរិបទ ដែល មានសារៈសំខាន់ក្នុងការដឹងថា តើអ្វីនៅក្នុងចិត្តរបស់មនុស្ស ឬក៏អ្វីដែលភាគី>វៀតណាម<យកចិត្តទុក ដាក់នៅពេលនោះ ក៏ដូចជាការយកចិត្តទុកដាក់ដោយភាគី>អាល្លឺម៉ង់<នៅពេលនោះដែរ> <ពីព្រោះ> យើង<កំពុងដោះស្រាយលើ>បរិបទនៅសម័យសង្គ្រាមត្រជាក់។ <ទាំងនេះគឺជាសញ្ញារើសអើងចំពោះ ការវាយតម្លៃ>ដែលវាមានសារៈសំខាន់ក្នុងការពិភាក្សាគ្នាទៅលើចលនានយោបាយ<របស់>បក្ស កុម្មុយនីស្តកម្ពុជា <ដែល>មេធាវីការពារក្តីបានបញ្ជាក់<ជាច្រើនដង>រួចមកហើយថា ចលនាហ្នឹងមិន មែនជាចលនាតែមួយទេ<>។ <ហើយវាមានសារៈសំខាន់សម្រាប់>យើងគិតថា <តើពួកវាត្រូវបាន កាត់សេចក្តីដោយត្រឹមត្រូវឬទេ។ វាមានសារៈសំខាន់ក្នុងការដឹងថា ទាំងអស់នេះជាការសម្រេចនៅ ពេលនោះ។ វាទាក់ទងទៅនឹងនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ> ដើម្បី<>មានទស្សនៈយល់ឃើញ ជាទូទៅ ទៅលើថា <>ចលនានៃបក្សកុម្មុយនីស្តកម្ពុជា ហើយថាតើសម្ព័ន្ធមិត្តយល់ឃើញយ៉ាងណា <ចំពោះបក្សកុម្មុយនីស្តកម្ពុជា ឬក៏អ្នកផ្សេងៗទៀត ដែលមិនមែនជាសម្ព័ន្ធមិត្ត ហើយកំពុងសម្លឹងមើល ទៅលើមនុស្សនៅក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជា ដែលអាចចាត់ទុកថាជាសម្ព័ន្ធមិត្តក្នុងផ្នែកនៃ>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជម្លោះប្រដាប់អាវុធ ឬក៏ជាជម្លោះនយោបាយ។ <ដូច្នេះការកត់សម្គាល់នេះគឺមានតម្លៃអាចទទួលយកបាន ព្រោះក្នុងការវាយតម្លៃអំពីគុណតម្លៃនៃភស្តុតាង តាមគោលការណ៍រក្សាព័ត៌មានត្រឹមត្រូវក្នុងឯកសារ ប៉ុន្តែងាយនឹងយល់ថា វាជាទស្សនៈរបស់ចលនានយោបាយមួយ ឬទស្សនៈរបស់ប្រទេសមួយ នៅពេលនោះ។> នេះជាអ្វីដែលខ្ញុំចង់បញ្ជាក់ជូន។

<>

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីធ្វើសារណារតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា។

[១០:៥៤:៤៤]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា យើងត្រូវបែងចែកឲ្យបានច្បាស់នូវសំណួរពីរ។ សំណួរទី១ គឺថា តើឯកសារហ្នឹងគួរទទួលយកឬក៏អត់? ហើយថាតើមានភាពពាក់ព័ន្ធ<ទៅនឹងបញ្ហាក្នុងការជំនុំជម្រះ>ឬក៏<>ទៅតាមទ្រឹស្តី<>របស់ខាងមេធាវីការពារក្តី<ឬអត់?>។ ទី២ <តើពួកគេ>ទាក់ទងទៅនឹង<សាក្សី>អ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្ម <ឬ>ផ្តល់សក្ខីកម្មតែចំពោះការប្រព្រឹត្តចំពោះជនជាតិចាម។ ដូច្នេះ កន្លងមកខ្ញុំស្តាប់ឮដូចជាមេធាវីការពារក្តីមិនបានលើកឡើងអ្វីទាក់ទងទៅនឹងការប្រព្រឹត្តចំពោះជនជាតិចាមនោះឡើយ។ <មេធាវីការពារក្តីបាន>លើកថា ប្រវត្តិរូប<មួយ ដែលឈ្មោះត្រូវបាន>លុបចេញ <ហើយគាត់ជឿថា ជា>ឈ្មោះរបស់ជនជាតិចាមម្នាក់។ គាត់មិនបានបង្ហាញថាតើវាពាក់ព័ន្ធយ៉ាងណាទេ ប៉ុន្តែខ្ញុំអាចនិយាយថា មិនមានពាក់ព័ន្ធ<ទេ។> ប៉ុន្តែយ៉ាងណាក៏ដោយយើងមិនជំទាស់ទេ ប្រសិនបើគាត់ចង់លើកយកប្រវត្តិរូបនេះមកសួរ<សាក្សី>អ្នកជំនាញ។ ប៉ុន្តែ<ការសួរ>អ្នកជំនាញ<ដែលនឹងមកទីនេះ ដើម្បី>និយាយ<អំពី>ជនជាតិចាម <អំពី>ការបះបោរនៅភូមិភាគបូព៌ា ក៏ដូចជាគោលនយោបាយនៅភូមិភាគបូព៌ា<> គឺស្ថិតនៅក្រៅជំនាញរបស់គាត់។ ដូច្នេះ ហើយវាមិនត្រូវជាមួយនឹងអ្វីដែល<សាក្សី>ត្រូវមកផ្តល់សក្ខីកម្មអំពីការប្រព្រឹត្តចំពោះជនជាតិចាមនោះឡើយ។ <ចំពោះការទទួលយក>ប្រវត្តិរូបរួម<ទាំងនេះ ខ្ញុំអាចនិយាយបានថា> ខ្ញុំយល់<ពីការ>លើកឡើង<របស់មេធាវីការពារក្តី។ ពួកគេគិតថា> មានភាពពាក់ព័ន្ធ <និងមានតម្លៃ>ទៅតាមទ្រឹស្តីរបស់ពួកគេ<ដែល>ថា បក្សកុម្មុយនីស្តកម្ពុជាគឺតែងតែមានការបែកបាក់ផ្ទៃក្នុង។ ខ្ញុំ<អាចនិយាយ>ថា វា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<អាច>មានភាពពាក់ព័ន្ធ។ <ខ្ញុំគិតថា> វា<ពិតជា>បង្ហាញ<ភាព>ផ្ទុយ<គ្នា> ប៉ុន្តែ<យើងមើលឃើញពី>ភាពពាក់ព័ន្ធ។ <ខ្ញុំគិតថា វា>បង្ហាញថា <ជាការពិត> មិនមានការ<បះបោរទេ រហូតដល់មានការបោសសម្អាតបានកើតឡើងយ៉ាងពេញទំហឹងនៅចុងរបបនោះ>។ <ជាថ្មីម្តងទៀត ទោះបីជា>ព័ត៌មានហ្នឹងមិនត្រឹមត្រូវ<ក្តី វា>អាចនឹងមានតម្លៃភស្តុតាង<ខ្លះដែរ>។ <ខ្ញុំយល់ស្របជាមួយការលើកឡើងរបស់>មេធាវីការពារក្តី ខៀវ សំផន <អំពីបញ្ហានោះ។ ឧទាហរណ៍ យើងដឹងពី>ខាងភ្នាក់ងារស៊ើបអង្កេតរបស់អាល្លឺម៉ង់ខាងកើត ឬក៏សូវៀត <វាមាននៅក្នុងសៀវភៅរបស់ ស្តេហ្វេន ម៉ូរីស ដែល>វៀតណាម គិតថា នួន ជា គឺជាមនុស្សរបស់ពួកគេនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ <យើងជំទាស់>ការ<>ប្រើប្រាស់ឯកសារទាំងអស់នេះ លើកលែងតែប្រវត្តិរូបរបស់ជនជាតិចាម <ដែលត្រូវសួរអ្នកជំនាញ។> <>យើង<មិន>ជំទាស់<សារណារបស់ពួកគេសម្រាប់គោលបំណងទូទៅទេ>។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វង់ម៉ាក ឡាវែន៍!

[១០:៥៧:៣០]

**ចៅក្រម ហ្វង់ម៉ាក ឡាវែន៍៖**

សូមលោកប្រាប់ខ្ញុំ ថាតើខ្ញុំយល់ហ្នឹងត្រឹមត្រូវអត់នូវសម្តីរបស់លោក។ លោកជំទាស់ទៅនឹងការប្រើប្រាស់ឯកសារនេះ<ទាំងស្រុង ឬ>មួយភាគធំសម្រាប់សួរដេញដោលអ្នកជំនាញ ក៏ប៉ុន្តែលោកមិនជំទាស់ទៅនឹង ភាពទទួលយកបាននៃឯកសារនេះទេ ដោយសារតែវាមានភាពពាក់ព័ន្ធទៅនឹងទស្សនៈរបស់មេធាវីការពារក្តី ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**លោក នីកូឡាស គូមជែន៖**

បាទ ត្រឹមត្រូវហើយលោកចៅក្រម។

ខ្ញុំមិនជឿជាក់ទៅលើអ្វីដែលមេធាវីការពារក្តីបកស្រាយទេ ប៉ុន្តែខ្ញុំ<ពិតជាមើលឃើញថា ពួកគេបានតតាំងទៅលើភាពជាប់ពាក់ព័ន្ធរបស់ឯកសារនេះ ដូច្នេះ ពិតជាដូចលោកចៅក្រមបានមានប្រសាសន៍ហើយ។> ខ្ញុំមិនជំទាស់ទៅលើការទទួលយកឯកសារដាក់ចូលទៅក្នុងសំណុំរឿងនោះឡើយ។ ប៉ុន្តែយើងមិនគួរសួរអ្វីហួសពីជំនាញរបស់អ្នកជំនាញនោះឡើយ <វាជាការខាតពេលវេលា>។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<បើសិនជាយើងមានសាក្សី ដើម្បីផ្ដល់សក្ខីកម្មពីភាព>ជំនាញ<>ទៅលើ<ការប្រព្រឹត្តិចំពោះ>ជនជាតិចាម <ហើយពួកគេសួរទូទៅ>អំពីការបះបោរនៅភូមិភាគបូព៌ា គឺហាក់ដូចជាមិនពាក់ព័ន្ធ។ <មិនពាក់ព័ន្ធទេ> គឺថាខ្ញុំចង់និយាយថា <វាហួសពី>ជំនាញរបស់<សាក្សី>។

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់! ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ យើងខ្ញុំគោរពទៅតាមការសម្រេចទាំងស្រុងរបស់អង្គជំនុំជម្រះទៅលើបញ្ហានៃឯកសារនេះ។

[១០:៥៩:២១]

**ប្រធានអង្គជំនុំ៖**

បាទ ផ្ដល់វេទិកាជូនទៅក្រុម សហមេធាវីការពារក្ដីលោក ខៀវ សំផន -- អ៎! លោក នួន ជា ដើម្បីធ្វើការសារណាតបចុងក្រោយរបស់ខ្លួនទៅនឹងសារណារបស់ភាគីផ្សេងទៀត ជាពិសេសសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើមានសូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។ ខ្ញុំសូមឆ្លើយតបអ្វីដែលនិយាយទាក់ទងទៅនឹងអ្នកជំនាញដែលនឹងអញ្ជើញមកដល់។ ដូចខ្ញុំបានបញ្ជាក់រួចហើយគឺថា មានប្រវត្តិរូបសង្ខេបមួយ គឺជារបស់ អ៊ុក ប៊ុនឈឿន។ អ៊ុក ប៊ុនឈឿន គឺជាអនុប្រធាននៅតំបន់២១។ តំបន់២១ គឺរួមមានស្រុកក្រូចឆ្មារផងដែរ ដូចជាកោះផល <> ស្វាយឃ្លាំងជាដើម។ នៅក្នុងប្រវត្តិរូបជាភាសាវៀតណាម យើងអាចអានទៅឃើញថា នៅថ្ងៃ០១ កក្កដា ៧៥ <ជាភាសា>អាល្លឺម៉ង់ <(អានជាភាសាអាល្លឺម៉ង់ មិនមានការបកប្រែ)> គឺថាគាត់ក្លាយទៅជាអនុលេខាតំបន់២១។ <គួរឲ្យចាប់អារម្មណ៍>ជាងនេះទៅទៀត <គាត់>និយាយថា នៅថ្ងៃ២៥ ឧសភា បើតាមប្រវត្តិរូបនេះ គាត់ -- ខ្ញុំសូមដកស្រង់ជាភាសា អាល្លឺម៉ង់ឡើងវិញ៖ <(អានជាភាសាអាល្លឺម៉ង់ មិនមានការបកប្រែ)> មានន័យថា គាត់បានចាកចេញពីអង្គការ<ប្រតិកិរិយា> គឺមានន័យថា<>កម្ពុជា<ប្រជាធិបតេយ្យរួចហើយ> គឺ<ថ្ងៃទី>២៥ ឧសភា ៧៥។ <>ក្នុង<>ភាសាអាល្លឺម៉ង់ <គាត់និយាយ>ថា៖ <(អានជាភាសាអាល្លឺម៉ង់ មិនមានការបកប្រែ)> គឺជាភាសាអង់គ្លេសមានន័យ<>ថា៖ "ខ្ញុំធ្វើការវាយប្រហារ<ប្រឆាំង>ជាមួយនឹងពួកប្រតិកិរិយា ប៉ុល ពត, អៀង សារី នៅក្នុង

តំបន់២១”។ <តើ>គាត់<បាន>ធ្វើ<បែបនោះទេ>នៅខែឧសភា ឆ្នាំ៧៥? <តើវាពាក់ព័ន្ធយ៉ាងម៉េចទៅនឹងការចាកចេញពី>តួនាទីរបស់គាត់នៅខែឧសភា ឆ្នាំ៧៨<?> <ដូច្នេះរចនាសម្ព័ន្ធអាជ្ញាធរដូចដែល>អ្នកជំនាញ<បានពិភាក្សាយ៉ាងទូលំទូលាយ ពាក់ព័ន្ធទៅនឹង>តំបន់២១ <>ខ្ញុំគិតថា វា<មានសារៈ>សំខាន់<ណាស់ សម្រាប់>ពួកយើងអាចយល់ដឹងឲ្យបានច្បាស់លាស់<ពីបញ្ហានេះ។> ព្រោះនេះជាការចង្អុលបង្ហាញមួយ ដែល<អាច>បង្ហាញអំពីទ្រឹស្តីរបស់យើងខ្ញុំដែលថា មានការប្រឆាំង<>មិនមែនចាប់ផ្តើមឆ្នាំ៧៧, ៧៨ ទេ គឺ<ចាប់ផ្តើម>ភ្លាមៗក្រោយថ្ងៃ១៧ មេសា ៧៥ នោះឯង។ ហើយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បាននិយាយដូចគ្នានេះដែរ។

នៅពេលដែលយើងនិយាយអំពីគោលនយោបាយចាមពាក់ព័ន្ធទៅនឹង<>ភូមិភាគបូព៌ា ខ្ញុំគិតថាឯកសារនេះ <>យើងគួរតែអាចបង្ហាញជូនអ្នកជំនាញ ព្រោះយើងដឹងថា <គាត់បានសួរ>អំពីរចនាសម្ព័ន្ធ<អាជ្ញាធរ>នៅតំបន់២១ ផងដែរ។

[១១:០៣:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយចុះភាគីសហមេធាវីការពារក្តីលោក ខៀវ សំផន មានអីចង់បន្ថែមកត់សម្គាល់បន្ថែមអីទេ? បាទ បើមិនមាន--

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំអាចនិយាយថា “ទេ” ក៏ប៉ុន្តែ ខ្ញុំនឹកឃើញដល់អ្វីដែលអង្គជំនុំជម្រះបានសម្រេចទៅលើឯកសារមួយ គឺឯកសារ <E347/1.56> ដែលអង្គជំនុំជម្រះបានពន្យល់ថាឯកសារនោះគឺមានភាពពាក់ព័ន្ធ ពីព្រោះថាវានិយាយអំពីជម្លោះប្រដាប់អាវុធជាមួយវៀតណាម ហើយនិងកម្ពុជា ហើយនិងបរិបទប្រវត្តិសាស្ត្រ។ ដូច្នេះ វាដូចតែគ្នាទេចំពោះឯកសារដែលលើកឡើងដោយមេធាវីការពារក្តី នួន ជា នោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយកិច្ចពិភាក្សាលើសំណើសុំរបស់សហមេធាវីការពារក្តី នួន ជា បានចប់ហើយៗអង្គជំនុំជម្រះសូមអរគុណចំពោះភាគីទាំងអស់ដែលបានធ្វើសារណាផ្ទាល់មាត់ ដែលជាមូលដ្ឋានសម្រាប់អង្គជំនុំជម្រះយកទៅពិចារណាសម្រេចលើសំណើសុំរបស់លោក នួន ជា និងបានចេញនូវសេចក្តីសម្រេចក្នុងពេលឆាប់ខាងមុខនេះឲ្យបានមុនពេលអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មអ្នក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01217198



ជំនាញដែលមានរហស្សនាម 2-TCW-88។

បាទ តទៅនេះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១១:០៥:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ ហើយជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ព្រឹកមិញនេះលោកជម្រាបជូនតុលាការថា គេឃុំខ្លួនលោកនៅឯ<>ភ្នំក្រោល។ តើអគារ<>ភ្នំក្រោល<>ទីតាំងនៅកន្លែងណា <ដែល>គេឃុំខ្លួន<លោក?> គេឃុំខ្លួនបន្ទប់ខាងក្រោម ឬក៏គេឃុំខ្លួននៅបន្ទប់ខាងលើ? <តើលោកអាចរៀបរាប់បន្តិចបានទេ អំពីទីតាំងនោះ។>

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបព្រឹកមិញហើយ។ ពួកខ្ញុំហ្នឹងគេឃុំខាងក្រោមបាទ គេឃុំនៅភ្នំក្រោលតែម្តង មន្ទីរភ្នំក្រោលដែលផ្ទះថ្ម។

**ស៖** សូមអរគុណ។ ប្រហែលជាខ្ញុំយល់មិនច្បាស់។ <អ្វីដែល>ខ្ញុំសួរ<គឺ>អគារ<>ដែលគេឃុំខ្លួនលោកហ្នឹង <តើ>វានៅជើងភ្នំ ឬក៏នៅលើកំពូលភ្នំ<ក្រោល>។ តើអគារនេះស្ថិតនៅត្រង់កន្លែងណា?

**ឆ៖** អគារហ្នឹងនៅលើភ្នំ ត្រង់មន្ទីរទាហាននៅឥឡូវ ទាហានស្រុកនៅឥឡូវហ្នឹង។ ហ្នឹងតាម--

[១១:០៧:២៥]

**ស៖** សូមអរគុណ។ លោកសាក្សី <តើ>លោកមានដឹងវាលពិឃាត <ពីទីកន្លែងដែលមានឆ្អឹងខ្មោច ដែលគេយក>មនុស្ស<>ទៅសម្លាប់ក្នុងរបប<>កម្ពុជាប្រជាធិបតេយ្យ<ទេ>? នៅក្នុងស្រុករបស់លោកនោះ តើលោកដឹងថាមានវាលពិឃាតនៅកន្លែងណាដែរទេ ជិតភ្នំក្រោលនោះ?

**ឆ៖** បាទ ពេលដែលគេចាប់ថ្មីៗហ្នឹងមិនទាន់រំដោះនុំង អត់ដឹងដែរ។ តែក្រោយៗមកគេថា ឃើញឆ្អឹងមនុស្សត្រង់នេះ ត្រង់នោះៗ អីចឹងដឹងវាគេងាប់សង្គ្រាមវាយគ្នាមិនដឹង យកទៅគេវាយចោល

មិនដឹង អាហ្នឹង។

**ស៖** សូមលោកជម្រាបជូនតុលាការបន្តិចមក លោកដឹងអ្វីខ្លះដែរ?

**ឆ៖** បាទដូចខ្ញុំជម្រាបជូនអីចឹងហើយ តាមខ្ញុំដឹងហ្នឹង ដឹងតែប៉ុណ្ណឹង។ បើថាឃើញគេសម្លាប់អីគរ ឬក៏មានរណ្ដៅអីហ្នឹង ក៏អត់ឃើញដែរ។

**ស៖** សូមអរគុណ។ តើលោកដឹងថាគេមានរកឃើញរណ្ដៅកប់ខ្មោចនៅកន្លែងណាដែរ ក្រោយពីរបបនោះមក?

**ឆ៖** បាទ ឥឡូវដូចអត់ឃើញមានពីណាផ្សាយប្រកាសអីផង តាំងពីរបបនោះមក រហូតដល់ឥឡូវ។ ខ្ញុំក៏មិនចាប់អារម្មណ៍ដែរ វាផុតៗទៅហើយ ឲ្យវាផុតស្រលះទៅ។ ខ្ញុំចង់ស្អប់របបហ្នឹងផង ស្អប់របបហ្នឹងខ្លាំងពេក វាលែងខ្វល់។

[១១:០៩:៤៤]

**ស៖** ខ្ញុំសូមនិយាយលម្អិតបន្តិច អំពីបុរសម្នាក់ដែលលោកនិយាយពីឈ្មោះគាត់ព្រឹកមិញនេះ <ផាន់> ខន។ តើលោកស្គាល់<គាត់ទេ ផាន់ ខន? លោកនិយាយថា> គាត់ជាតំណាងរាស្ត្រ <តើត្រឹមត្រូវទេ>? ឥឡូវ កំពុងតែមានភាពច្របូកច្របល់ ចំពោះឈ្មោះបន្តិច។ ខ្ញុំនិយាយអំពី ផាន់ ខន តើផាន់ ខន ជាអ្នកណា លោកស្គាល់ទេ?

**ឆ៖** បាទ ផាន់ ខន ដូចអត់ស្គាល់ទេ មិនមានឈ្មោះទេ។ អត់មានឈ្មោះទេ។

**លោក សេង លាង៖**

ផាន យោន។

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ បើ ផាន យោន ហ្នឹង ស្គាល់។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ឥឡូវនេះ ខ្ញុំមិនសួរឈ្មោះ ខាំភួន ទេ ខ្ញុំសួរឈ្មោះ ផាន យោន។ តើលោកស្គាល់ឈ្មោះផាន យោន នេះទេ?

[១១:១១:០៤]

**ឆ៖** បាទ ខ្ញុំស្គាល់ឈ្មោះ ផាន យោន។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមបង្ហាញឲ្យលោកមើលឯកសារ E3/1645 <> លោកប្រធានសូមអនុញ្ញាតបង្ហាញឯកសារនេះ<ជាភាសាខ្មែរ> ទៅឲ្យសាក្សីមើល។ <>

**<ប្រធានអង្គជំនុំ៖>**

<អង្គជំនុំជម្រះអនុញ្ញាត។>

**<លោក នីកូឡាស គូមជែន៖>**

<សូមអរគុណលោកប្រធាន។>

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នេះគឺជាបញ្ជីឈ្មោះ ដែលមានកាលបរិច្ឆេទនៅលើនេះដែរ ថ្ងៃទី២៣ វិច្ឆិកា ៧៧។ នេះជាបញ្ជីអ្នកទោសដែលគេបញ្ជូនមកស-២១ <នៅថ្ងៃនោះ>។ លោកឃើញហើយ នៅលេខរៀង<> ៩៧ ហើយជាពិសេសគឺលេខរៀងទី១០៦ រហូតដល់លេខរៀង១៤៣ ដែលគេបានបញ្ជាក់ថា មនុស្សទាំងអស់នេះ គឺមកពីតំបន់១០៥។ <ខ្ញុំសូមទាញចំណាប់អារម្មណ៍លើកទៅលើលេខរៀងទី១២៨ នៅកាឡោនទី២ បញ្ជាក់ថា> ផាន ឃោន នេះ មានឈ្មោះហៅ<ក្រៅ>ថា <> ជួន<> ដែលមានអាយុ៣៥ឆ្នាំ ប្រុស ជាសមាជិក<ពាណិជ្ជកម្មរដ្ឋ>តំបន់១០៥ <>។ លោកស្គាល់ទេ?

[១១:១៣:៣០]

ខ្ញុំសូមអានឲ្យលោកស្ដាប់ គឺលេខ១២៨ បាទ សូមឲ្យសហការីខ្ញុំអានជាខ្មែរតែម្ដង ច្បាស់សម្រាប់លោកតែម្ដង។

**លោក សេង លាង៖**

លេខរៀងទី១២៨ នៅកូឡោនទី២ ឈ្មោះ ផាន ឃោន ហៅ ជួន អាយុ៣៥ ភេទប្រុស មកពីតំបន់១០៥។ ទទួលខុសត្រូវខាងពាណិជ្ជកម្ម នៅតំបន់១០៥ហ្នឹង។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី លោកស្គាល់មនុស្សម្នាក់នេះទេ?

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ ឈ្មោះ ផាន ឃោន នោះ ខ្ញុំស្គាល់ បាទ។

[១១:១៤:៣២]

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ តើឈ្មោះនេះ គាត់កាន់មុខតំណែងអ្វីដែរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បាទ ឈ្មោះ ផាន ឃោន ហ្នឹង នៅរបបហ្នឹង គាត់នៅពាណិជ្ជកម្ម ដឹកប្រេង ដឹងស្ពី ដឹកក្រណាត់ ដឹកអី ចែកជូនប្រជាជនកាលហ្នឹង។

**ស៖** ហើយឈ្មោះ ផាន ឃោន នេះ តើគាត់មានជាប់ទំនាក់ទំនងសាច់ញាតិអីជាមួយនឹងឈ្មោះ ខាំភួន ដែរទេ? បាទគឺ ខាំភួន នេះ ជាមនុស្សដែលលោកនិយាយថាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍មួយ <លោកបានឮថា> នៅភ្នំពេញ ដែល<ហាម ត្រូវបានសម្លាប់ ក្នុងការ>បាញ់គ្នា<>។ តើ ផាន ឃោន ដែលមានឈ្មោះនៅលើបញ្ជីនេះ ជាប់ពាក់ព័ន្ធ ឬក៏ជាសាច់ញាតិអ្វីជាមួយនឹង ខាំភួន ដែរ?

**ឆ៖** បាទ តាមឈ្មោះ ផាន ឃោន ហ្នឹងគឺជាប្អូនថ្លៃរបស់ តាហាម។ ដល់ពេលនោះ បានមានបញ្ហាទៅ តាមខ្ញុំពិនិត្យទៅ ដឹងហ្នឹង ប្រហែលជាខាងខ្សែ តាហាម ហ្នឹងខឹងឲ្យ ខាំភួន ហ្នឹងចាប់ទាំងខ្សែ តាផាន ឃោន ទាំងអស់ទៅ។

**ស៖** លោកសាក្សី នៅពេល<>នោះ តើលោកធ្លាប់ឮ ឬក៏ដឹងថា ផាន ឃោន នេះត្រូវបានគេចាប់ខ្លួនដែរទេ?

**ឆ៖** បាទ ពេលថ្មីៗនេះអត់ដឹងទេបាទ។ ក្រោយមក ដល់ឆ្នាំរំដោះហ្នឹងបានដឹង។

**ស៖** តើលោកដឹងថាមានអ្វីកើតឡើងដល់គ្រួសារ ផាន ឃោន នេះដែរ? បើសិនណាជា ផាន ឃោន នេះមានប្រពន្ធ កូន <បងប្អូន ឬ>ឪពុកម្ដាយ តើ<លោកដឹងទេ>មានអ្វីកើតឡើងទៅដល់សមាជិកក្រុមគ្រួសាររបស់គាត់ <ក្រោយ>ពេលគេចាប់ខ្លួនគាត់?

**ឆ៖** បាទ ខ្ញុំដឹងបញ្ហាហ្នឹង។ ដល់គេ -- ដល់បាត់ ផាន ឃោន ហ្នឹង ក៏បាត់ទាំងកូនទាំងប្រពន្ធរហូតដល់ឥឡូវ។ បាត់រហូត លែងដឹងដំណឹងអ្វីទាំងអស់បាទ។

**ស៖** លោកក៏បានជម្រាបជូនតុលាការ<ថា> មេរបស់លោកឈ្មោះ វ៉ា នេះក៏ត្រូវបានចាប់ខ្លួន។ តើមានអ្វីកើតឡើងទៅដល់<គ្រួសារគាត់>?

**ឆ៖** បាទ វ៉ា ហ្នឹង ជាក្មួយរបស់តា ខាំភួន។ ដល់អ៊ីចឹង តាខាំភួនៗ ងាប់ទៅ ក៏បងប្អូនខាងតាហាម ហ្នឹងក៏ចាប់ខ្សែ តាខាំភួន ហ្នឹងឈ្មោះ វ៉ា ហ្នឹងទៅទាំងអស់ដែរ មួយពូជហ្នឹងដែរ។

[១១:១៨:២៨]

**ស៖** តើ វ៉ា មានប្រពន្ធ មានកូន មានបងប្អូនបង្កើតអីដែរទេ? ហើយបើសិនណាជាមាន លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដឹងថាតើមានអ្វីកើតឡើងទៅដល់សមាជិកសាច់ញាតិរបស់គាត់នោះដែរទេ?

**ឆ៖** បាទ មិនដឹងបងប្អូនគាត់ បងប្អូនឈ្មោះ រ៉ា ហ្នឹង គេបាត់ខ្លួនរហូតដល់ឥឡូវទាំងអស់ដែរ។

**ស៖** សូមអរគុណ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន សូមការអនុញ្ញាតបង្ហាញឯកសារ E3/156 <ជាភាសាខ្មែរ។ ខ្ញុំ>ជូនទៅសាក្សីមើល ឯកសារនេះមានតែមួយទំព័រទេ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំនឹងអានឯកសារនេះឲ្យលោកស្ដាប់ ហើយលោកអាចតាមមើលនៅខាងលើ<ហើយខាងឆ្វេង>នោះ សរសេរថាទូរលេខ៥៤ <"វិទ្យុប៉ុស្តិ៍> ២៩០<">គឺ "គោរពជូនបងជាទីគោរព!" ហើយខាងក្រោមនោះដាក់ថា "អ៊ំនួន"។ ហើយនៅកថាខណ្ឌទី១ ឯកសារនេះសរសេរថា "អំពីសភាពការណ៍ខ្មាំងនៅក្រៅ ពួកចារកម្មយួន គឺវាចូលមកកន្លែងកងពល"។ ខ្ញុំមិនអានមកខាងក្រោមទៀតទេ។ ឯកថាខណ្ឌទី២ តាមការវិភាគ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

[១១:២០:៤៥]

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ លោកប្រធាន មុនពេលសហព្រះរាជអាជ្ញាអានទូរលេខនេះ ឲ្យសាក្សីស្ដាប់គាត់គួរតែសួរសំណួរផ្ដើមជាមុនសិន ដើម្បីឲ្យ<យើងអាចយល់អំពីទំនាក់ទំនងរវាង>សាក្សី<និង>ឯកសារ<នេះ។> <តើអ្វីជាទំនាក់ទំនងរវាងសាក្សី និងឯកសារ ដែលសហព្រះរាជអាជ្ញាបង្កើតឡើង ហើយថាតើសាក្សីស្ថិតក្នុងជំហរបែបណា ក្នុងការផ្ដល់មតិយោបល់លើឯកសារនោះ។ ដូច្នេះ ជំហានដំបូងគឺមិនត្រូវបានបំពេញឲ្យគ្រប់គ្រាន់ទេ។>។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅនឹងការអានឯកសារឲ្យសាក្សីស្ដាប់ដោយមិនសួរសំណួរផ្ដើមសិន។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំហៀបនឹងភ្ជាប់ការជាប់ទាក់ទងជាមួយជាមួយនឹងសាក្សីទៅហើយ។ ឯកសារនេះ<និយាយអំពីបុរស>ម្នាក់ដែលខ្ញុំទើបតែលើកឈ្មោះមុននេះទេ <ហើយឈ្មោះគាត់ក៏បញ្ចាក់ក្នុងទូរលេខនេះដែរ>មានឈ្មោះ ចាជួន នោះ។ ដូច្នេះ ខ្ញុំនឹងបំពេញបំណងមេធាវីការពារក្តី ប៉ុន្តែសូមអានឲ្យបានពេញបន្តិច។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមិនជំទាស់ទេ ពីព្រោះខ្ញុំដឹងថា អង្គជំនុំជម្រះមិនតម្រូវឲ្យមានការជាប់ទាក់ទងគ្នារវាងសាក្សី ហើយនិងឯកសារនេះទេ។ ក៏ប៉ុន្តែ ជួន នេះ ដែលមាននៅឯកសារមុននោះ គឺថាវាមិនជាប់ទាក់ទងទៅនឹងសាក្សីរូបនេះទេ។ <សាក្សីនេះមិនដឹងអ្វីទាំងអស់ចំពោះឯកសារនេះ។> ឯកសារនេះ មិន<មែនគាត់>ជាអ្នកទទួល ហើយ<ក៏>មិន<គាត់ជាអ្នកបញ្ជូនដែរ។> <ទោះយ៉ាងណា គាត់មិនមានតួនាទីនៅ>តំបន់១០៥នោះទេ។ <វាពិតជាមិនមានភាពពាក់ព័ន្ធក្នុងការសួរសំណួរទាំងនេះ ទៅសាក្សីនេះទេ។ ទោះយ៉ាងណា> ខ្ញុំដឹង<>ថា អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាគាត់សួរហើយ។

**លោក នីកូឡាស គូមជែន៖**

<លោកចៅក្រម យើង>ទើបតែដឹងដែរថា មេធាវីការពារក្តីបានដាក់ស្នើសុំអង្គជំនុំជម្រះទទួលយកឯកសារមួយដែលជាឯកសារ<ដែល>មិន<ស្គាល់ឈ្មោះ>អ្នកនិពន្ធ <និងមិនស្គាល់ប្រភព>។ ខ្ញុំ<នឹង>សួរសំណួរទៅ<សាក្សី នូវអ្វីដែលគាត់ដឹង។ គាត់អាចមិនដឹងអ្វីទាំងអស់ ប៉ុន្តែមានឈ្មោះបុគ្គលមួយចំនួននៅក្នុងនេះ ហើយខ្ញុំចង់ដឹងថា តើគាត់ដឹងពីជោគវាសនារបស់បុគ្គលទាំងអស់នេះទេ។> ព្រោះបុគ្គលរូបនេះ គឺមកពីតំបន់១០៥ <ហើយគាត់បានធ្វើការនៅទីនោះ>។ ដូច្នេះ លោកសាក្សីខ្ញុំសូមចូលទៅកថាខណ្ឌទី៣ ដែលបញ្ជាក់អំពីបញ្ហាសភាពការណ៍ផ្ទៃក្នុងបក្ស។ ខ្ញុំសូមឲ្យសហការីខ្ញុំអានឈ្មោះ។

[១១:២៣:២៤]

**លោក សេង លាង៖**

*កាំម៉ារ៉ាត* សុត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** “គឺមានសមមិត្ត សុត ប្រធានរោងចក្រជួសជុលបានប៉ះពាល់សីលធម៌ជាមួយនារី ឥឡូវ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នេះ គឺបានចាប់ហើយ គឺចាប់ទាំងបុរស ចាប់ទាំងនារី។ មិត្តនេះ កាលមុនមានជាប់ឆ្លើយចម្លើយពួកអាក្បត់ អាជួន<>។ ពេលនោះ <តំបន់បាន>តាមដានសកម្មភាពវាបន្ថែមទៀត”។ ដូច្នេះលោកសាក្សីលោកដែលឮសូរឈ្មោះសមមិត្ត សុត ប្រធានរោងចក្រជួសជុលដែរទេ?

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ ឈ្មោះ សុត ហ្នឹងស្គាល់ឈ្មោះ ប៉ុន្តែដូចបានសួរថា មានលេខរៀងអី សំបុត្រអីអីចឹង ខ្ញុំអត់ដឹងទេបាទ។ ពីណាផ្ញើឲ្យពីណា អាផ្ញើពីនោះអត់ដឹងទេបាទ។

**ស៖** ឯកសារនេះ ចុះហត្ថលេខាដោយមនុស្សម្នាក់ឈ្មោះ សារុន តើ<នេះជាឈ្មោះរបស់> មនុស្សម្នាក់<ដែលលោកនិយាយថា>ជំនួសឈ្មោះ ហម ដែលជាលេខាតំបន់នោះមែនទេ?

<>

[១១:២៥:០០]

**ឆ៖** បាទ ហ្នឹងមែន។

**ស៖** តើលោកដឹងថា គាត់ហ្នឹងរស់រានមានជីវិតពីរបបនោះដែរឬក៏អត់ទេ? លោកដឹងថាមានអ្វីកើតឡើងទៅដល់ឈ្មោះ សុត នេះដែរទេ?

**ឆ៖** កាលនោះ សុត ហ្នឹងវានៅម្តុំភ្នំក្រោលហ្នឹងដែរ នៅកន្លែងហ្គារាសឡានផង នៅត្រង់ណាត្រង់ណីទេ ការងារគាត់ហ្នឹងដូចជាមិនច្បាស់លាស់ទេ ខ្ញុំមិនបានអ្នកស៊ើបការណ៍ ដឹងការងារអីធំដុំទេ គ្រាន់តែដឹងថា មានឈ្មោះ សុត មាន។

**ស៖** បើលោកមិនដឹងទេ ក៏មិនជាអ្វីដែរ ក៏ប៉ុន្តែ <តើលោកដឹង ឬក៏មិនដឹងទេថា> សុត ម្នាក់នេះ<ត្រូវបានចាប់ខ្លួន តើគាត់សម្លាប់ឬក៏រស់ក្រោយរបបនោះ?> <>ទូរលេខនេះ ចុះ<ខែ>មេសា ឆ្នាំ៧៨។ <លោកដឹង ឬមិនដឹង គឺមិនអីទេ គ្រាន់តែប្រាប់យើងមក>?

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបអីចឹង ហើយបញ្ហាគេនៅថ្នាក់លើនោះ មិនអាចដឹងបានទេ បាទ។

**ស៖** ខ្ញុំមិនសួរថាមានអ្វីកើតឡើងទៅដល់ថ្នាក់លើនោះទេ។ ចាប់ពីឆ្នាំ១៩៧៨ តៗមក តើលោកធ្លាប់បានជួបឈ្មោះ សុត នេះទៀតទេ?

**ឆ៖** បាទ ដូចខ្ញុំជម្រាប កាលដើមមកហើយថា មានឈ្មោះ សុត ហ្នឹងជាមួយឈ្មោះ កាំ ហ្នឹងទៅចាប់ពួកខ្ញុំ ខ្ញុំដឹងតែប៉ុណ្ណឹង រហូតបាត់ឈ្មោះរហូតទៅ។

**ស៖** សូមអរគុណ ខ្ញុំសូមសួរបញ្ជាក់ពីរបីចំណុច។ នៅពេលដែលលោកធ្វើជានីរសារ លោក

មានកាន់កាំភ្លើងទេ? គេមានឲ្យអាវុធលោកប្រើប្រាស់ទេ?

**ធ៖** បាទ កាលនៅធ្វើនីរសារគេហ្នឹង គេឲ្យកាន់។

**ស៖** តើលោកមានភារកិច្ចអ្វីក្រៅពីនីរសារនេះដែរទេ? មានចូលរួមប្រយុទ្ធអីនៅសមរភូមិណាអីដែរទេ <ក្រៅពីធ្វើជានីរសារនោះ>?

**ធ៖** បាទ ខ្ញុំអត់មានប្រយុទ្ធនៅណាទេ មានតែការពារគេ ដល់គេចាប់ខ្លួន ក៏ឈប់កាន់កាំភ្លើងតាំងពីហ្នឹងរហូតទៅ រហូតដល់គេយកទៅដាក់ការដ្ឋានហ្នឹងរហូតទៅប៉ុណ្ណឹង ដល់រំដោះ ៧៩។

**ស៖** សូមអរគុណ។ នៅក្នុងរបបនោះ គឺគិតពី<ខែ>មេសា ៧៥ រហូតដល់ ចុងបញ្ចប់ឆ្នាំ៧៨ តើមានជនជាតិវៀតណាមរស់នៅក្នុងស្រុករបស់លោកទេ?

**ធ៖** បាទ តាមខ្ញុំពិនិត្យទៅដូចអត់មានទេ របបនោះ ដូចវាតឹងតែងណាស់ ឈ្មោះគេថា យួនៗមួយហ្នឹងគឺយកទៅវ៉ៃចោលតែម្តង យកទៅបាត់មុខតែម្តង។

[១១:២៨:៥០]

**ស៖** តើលោកមានដឹងថា មានជនភៀសខ្លួនវៀតណាម ជ្រៀតចូលមក<>ក្នុងស្រុករបស់លោកទេ <តាមការចងចាំរបស់លោក> ដូចជា <អតីតទាហាន ផៀវ ដែលប្រឆាំងនឹងរបបកុម្មុយនីស្ត> ជនជាតិ ម៉ុងតេណា <ឬជនជាតិចិនជាដើម?> <តើលោកដឹងទេ តើមានជនភៀសខ្លួនណាម្នាក់ត្រូវបានចាប់ខ្លួននៅក្នុងស្រុករបស់លោកទេ>?

**ធ៖** បាទ កាលរបបប៉ុលពតហ្នឹង ដូចអត់មានជនជាតិវៀតណាម ជនជាតិអីមកចូលទេ កាលរបបហ្នឹង។

**ស៖** សូមអរគុណ។ ចុះនៅក្នុងភូមិស្រុករបស់លោក តើមានសាច់ញាតិរបស់អ្នករស់នៅក្នុងតំបន់របស់លោកហ្នឹងធ្វើជាទាហានលន់នល់ហ្នឹងដែរទេ?

**ធ៖** បាទ មានដូចជាឪពុកក្មេកខ្ញុំអីចឹង ហ្នឹងគេយកទៅវ៉ៃចោលទាំងពីរយូរហើយ គេបាញ់ចោលអស់ហើយ។

**ស៖** ហេតុអីបានជាគេចាប់ឪពុកក្មេកលោកយកទៅបាញ់ចោល?

**ធ៖** តាមរបបគេហ្នឹងឲ្យតែដឹងថាធ្វើទាហាន លន់ នល់ ធ្វើគិញ ធ្វើខ្មាំង សេ.អ៊ី.អា, កា.ហ្ស.បេ ចេះតែចោទប្រកាន់ទៅៗ ហើយគេរបបគេហ្នឹង មិនដឹងស្អីស្អុកទេ។ អីចឹងបានថាទេ ជនជាតិផ្សេងៗ ជនជាតិខ្មែរខ្លួនឯង ជនជាតិខ្លួនឯងក៏សម្លាប់ចោលដែរ។

**ស៖** នៅពេលដែលលោកធ្វើជានីរសារ ហើយលោកកាន់កាំភ្លើង។ តើលោកមានទទួលការបញ្ជា ឬក៏លោកមានទទួលការបំពាក់បំប៉នបណ្ដុះបណ្ដាល<អំពីរបៀបធ្វើយ៉ាងណាចំពោះសត្រូវ>ទេ?

**ឆ៖** បាទ អត់មានទេ ព្រោះរូបខ្ញុំអត់មាននៅពាក់ព័ន្ធអីសោះទេ ប៉ុន្តែការពារគេតែប៉ុណ្ណឹង ចាប់ខ្លួនទៅក៏មិនបានកាន់កាំភ្លើងទេ គេដកចេញអស់ទៅ។

[១១:៣១:២៧]

**ស៖** លោកបានបញ្ជាក់ថា នៅពេលនុ៎ងលោកគ្មានមេធាវីទេ <ហើយខ្ញុំសន្និដ្ឋានថា>គ្មានតុលាការអីកាត់ទោសទេ។ តើលោក<ធ្លាប់ឃើញ ធ្លាប់ឮថា>នៅក្នុងរបបហ្នឹង<>មាន<ការ>កាត់ក្តីដោយមានតុលាការ មានមេធាវីការពារក្តី <និងប្រាប់ពីសិទ្ធិ>អីទេ?

**ឆ៖** បាទ បញ្ហាហ្នឹងដូចអត់មានទេ ដូចគ្មានតុលាការ អត់មានមេធាវី អត់មានអីទេ អង្កាល់ណោះ ដឹងថាចាប់ ដឹងថាងាប់ ម្នាក់ៗសង្ឃឹមថាងាប់អ៊ីចឹងតែម្តង។ របបនោះអត់មានដូចរបបយើងឥឡូវមានតុលាការ មានមេធាវី មានអីឯណា។ របបហ្នឹងដឹងថាចាប់ ដឹងថាត្រូវបាញ់ៗចោលតែមិនដឹងយកទៅសម្លាប់ចោលប៉ុណ្ណឹង។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន តើសមល្មមនឹងអាចឈប់សម្រាកបាយថ្ងៃត្រង់ដឹង?

**ប្រធានអង្គជំនុំ៖**

លោកត្រូវការពេលវេលាទំនងជាប៉ុន្មានទៀតក្នុងការសួរដេញដោលសាក្សីរូបនេះ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា សាក្សីរូបនេះមានពេលវេលាតែថ្ងៃនេះទេក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំសល់តែមួយសំណួរទៀតទេ ហើយប្រគល់នាទីនេះជូនដើមបណ្ដឹងរដ្ឋប្បវេណី <ហើយខ្ញុំជឿថាពួកគេត្រូវការពេលប្រហែលជា ២០នាទី>។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សីខ្លួនលោកផ្ទាល់ តើមានបាត់បង់សាច់ញាតិសន្តានអីរបស់លោកផ្ទាល់ទេនៅក្នុងរបបនោះ?

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ របបនុ៎ងៗក៏ពុកខ្ញុំក៏គេយកទៅវ៉ៃចោលដែរ ទាំងអស់ ម៉ាពិសេសខ្មែរខ្ញុំជាមួយខ្មែរខាំភូន, ខ្មែរ រ៉ា ហ្នឹង ងាប់ទាំងអស់ច្រើនជាងគេនៅភូមិខ្ញុំ។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ សូមប្រគល់នាទីជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១១:៣៣:៤០]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគី សាធារណជន ខ្ញុំសូមប្រគល់សិទ្ធិនៅក្នុងការសួរនេះជូនលោកមេធាវី ហុង គីមសួន។ លោក ហុង គីមសួន ប្រហែលជាត្រូវការរយៈពេល១៥នាទីតែប៉ុណ្ណោះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោក ហុង គីមសួន៖**

សូមអរគុណ។ បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព និងអង្គសវនាការទាំងអស់ជាទីគោរព។

ខ្ញុំបាទ ហុង គីមសួន ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមសួរបន្ថែមមិនជាវែងទេដល់លោកសាក្សីទាក់ទងតែជាមួយនឹងមន្ទីរសន្តិសុខភ្នំក្រោលតែប៉ុណ្ណោះ។

[១១:៣៤:២៤]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គីមសួន៖**

**ស៖** លោកព្រះរាជអាជ្ញាបានសួរលោកច្រើនដែរ អំពីការងាររបស់លោកមុនពេលដែលលោកមកធ្វើជា -- មុនពេលដែលគេចាប់ខ្លួនលោកមកដាក់ក្នុងមន្ទីរសន្តិសុខភ្នំក្រោលនេះ។ ខ្ញុំសួរលោកបន្តិច

ថា តើនៅក្នុងស្រុកដែលលោករស់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង លោករស់នៅតែស្រុកកោះញែកតែមួយ ឬក៏មានប្តូរស្រុកផ្សេងទៀតទេ?

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ ខ្ញុំរស់នៅតែស្រុកតែមួយហ្នឹង អត់មានដូរស្រុកទៅណាមកណាទេ។

**ស៖** នៅក្នុងសម័យខ្មែរក្រហមហ្នឹង ស្រុកកោះញែកមានដាក់ឈ្មោះជាលេខ ជាអក្សរអីផ្សេងពីឈ្មោះកោះញែកដែរទេ?

**ឆ៖** បាទ កាលនោះ ដឹងៗខ្លះដែរ វាដាក់ឈ្មោះហ្នឹង ប៉ុន្តែដឹងជាលេខនេះស្អី គេដាក់ហ្នឹង គេដាក់តែស្រុកកោះញែកហ្នឹង វាស្រុក រ-១ អីចឹង។

**ស៖** បាទ សូមអរគុណ។ ឥឡូវចូលដល់នៅក្នុងមន្ទីរសន្តិសុខ តើមន្ទីរសន្តិសុខភ្នំក្រោល មានឈ្មោះហៅផ្សេង ក្រៅពីឈ្មោះភ្នំក្រោលហ្នឹងទៀតទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១១:៣៦:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ចំណុចនេះអាចលម្អិតបន្តិចហើយ ប៉ុន្តែ<ខ្ញុំគិតថា>សាក្សី<មិន>បាននិយាយ<>ថា កន្លែងដែលគេឃុំគាត់ហ្នឹង<ជាមន្ទីរឃុំខ្លួន ឬជាគុកនោះទេ។ ជាការពិត គាត់និយាយយ៉ាងច្បាស់ថា វា>មិនមែនជាគុកទេ <វា>ជាមន្ទីររបស់តំបន់១០៥។ <ជាការពិត គាត់ត្រូវបានគេឃុំខ្លួន។ ប៉ុន្តែមិនដូចមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិយាយយោងទៅនោះទេ មិនមែនជាគុក ហើយក៏មិនមែនជាមន្ទីរឃុំឃាំងដែរ>។

**លោក ហុង គីមសួន៖**

ខ្ញុំបាទសូមឆ្លើយលោកប្រធាន។ ខ្ញុំមិនបាននិយាយអំពីពាក្យថា "គុក" ទេ អម្បាញ់មិញ។ ខ្ញុំសួរទៅសាក្សី ដោយសារនៅក្នុងឯកសារបានសរសេរអំពីមន្ទីរសន្តិសុខភ្នំក្រោល។ អីចឹង ខ្ញុំបាទក៏សួរទៅតាមអក្សរដែលមានសរសេរនៅក្នុងឯកសារ។ ដូច្នេះ ខ្ញុំបាទសូមបន្តការសាកសួរទៀត បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញសួរទៀតចុះ ហើយមេធាវីកុំរំខានអី ចាំដល់ពេលលោកទៅ លោកនឹងចាំសួរលម្អិតទៅ បើសិនជាសាក្សីឆ្លើយមិនច្បាស់នោះ វាបានផលប្រយោជន៍ពេញទំហឹងទៅលើមេធាវីហើយ។

[១១:៣៧:២៣]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** អ៊ីចឹងខ្ញុំសូមសួរបន្តទៅទៀតថា នៅក្នុងមន្ទីរសន្តិសុខភ្នំក្រោល អគារដែលគេឃុំឃាំង លោក និងប្រជាពលរដ្ឋផ្សេងទៀតហ្នឹង មានអគារផ្សេងពីហ្នឹងទៀតដែរទេ?

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ រកកន្លែងឃុំឃាំងហ្នឹង ជាមន្ទីររបស់តំបន់តែម្តង ឃុំឃាំងខ្ញុំ ឃុំឃាំងពួកខ្ញុំហ្នឹង។

**ស៖** បាទ សូមអរគុណ។ សូមសួរថា ក្រៅអំពីអគារដែលឃុំឃាំងលោកហ្នឹង នៅក្នុងមន្ទីរហ្នឹង មានៗអគារផ្សេងទៀតដែលឃុំឃាំង ដែលផ្សេងៗទៀតដែរទេ?

**ឆ៖** បាទ អត់ឃើញទេ រឿងកន្លែងឃុំឃាំងផ្សេងនោះ ដូចជាមានកន្លែងដឹងថា កន្លែងសន្តិសុខ គេប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរបន្តទាក់ទងជាមួយនឹងការចាប់លោក ប្រពន្ធលោក និងប្រជាពលរដ្ឋទាំងអស់ លោកមានប្រសាសន៍ហើយថា ប្រហែលជា៨៨នាក់។ តើ៨៨នាក់ហ្នឹង មនុស្សប្រុស មនុស្សស្រី និងកូនក្មេង គេដាក់រួមគ្នា ឬក៏មានការបែងចែកស្រីផ្សេង ប្រុសផ្សេង ក្មេងផ្សេងដែរ?

**ឆ៖** បាទ គេ កាលគេចងហ្នឹង គេចងស្រីម្ខាងទៅអ៊ីចឹង ចងប្រុសៗហ្នឹងម្ខាងមកអ៊ីចឹងទៅ។ ក្មេងៗតូចៗហ្នឹង គេអត់ចងទេ។

[១១:៣៨:៥៨]

**ស៖** បើខ្ញុំមិនច្រឡំទេ មានន័យថា អគារមួយហ្នឹងដាក់ទាំងស្រី ទាំងប្រុស គឺគ្រាន់តែទៅចងដាក់មួយចំហៀងស្រី មួយចំហៀងប្រុស។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ បញ្ហាហ្នឹងអ៊ីចឹងមែន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរអំពីស្ថានភាពនៃការរស់នៅ ឬក៏ការឃុំឃាំងលោកនៅក្នុងអគារនោះ។ ពីព្រឹកមិញ លោកបានជម្រាបជូនអង្គសវនាការអំពីរបបហូប។ លោកមានប្រសាសន៍បន្តិចមើលថាតើរបបហូបហ្នឹង ឬក៏បាយ ឬក៏ម្ហូបហ្នឹង គេឲ្យមួយថ្ងៃហ្នឹងចំណុះ បើយើងៗគិតជាចាន ឬក៏ជាវែកវិញ បានប៉ុន្មានដែរ ក្នុងមួយនាក់?

**ឆ៖** បាទ ដូចខ្ញុំជម្រាបព្រឹកមិញថា បាយហ្នឹងវាឲ្យម្នាក់មួយចានចង្អឹះប៉ុណ្ណឹង ស្រូកដាក់សម្លល្ពៅទៅ ប៉ុណ្ណឹង។

**ស៖** លោកបានទទួលរបបហូបប៉ុន្មានថ្ងៃពេលក្នុងមួយថ្ងៃ ហើយគេចែកឲ្យពេលណាខ្លះ?

**ឆ៖** ជួនកាល វាឲ្យហូបបាយថ្ងៃត្រង់ ល្ងាចអត់ទៅ។ ជួនកាល ឲ្យហូបល្ងាច ព្រឹកអត់ទៅ។

**ស៖** បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញបន្តកិច្ចដំណើរការសវនាការតទៅទៀត។ ហើយមន្ត្រីតុលាការសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤១នាទី ដល់ម៉ោង ១៣:៣៨ នាទី)*

[១៣:៣៨:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ហើយមានពេល១០នាទីបន្ថែមទៀតណា៎!

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន។

01217211



**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំនឹងបន្តសំណួរខ្ញុំបន្តិចទៀតតាមដែលលោកប្រធានបានអនុញ្ញាត។ ពេលសម្រាកពិសាបាយថ្ងៃត្រង់នេះ ខ្ញុំបានសួរលោកអំពីរបបអាហារ ហើយលោកបានឆ្លើយអំពីការចែកអាហារបានប្រហែលមួយកូនចាន និងមួយពេលក្នុងមួយថ្ងៃ។ អ៊ីចឹងសំណួរដែលខ្ញុំចង់សួរលោកតទៅទៀតនេះ គឺនៅទាក់ទងអំពីស្ថានភាពក្នុងមន្ទីរឃុំឃាំងដដែល។ ក្រៅពីម្ហូបអាហារប្រចាំថ្ងៃ តើទឹកផឹក ឬទឹកងូត ពួកសន្តិសុខដែលយាមនោះបានផ្តល់ឲ្យពួកក្រុមដែលលោកនៅក្នុងមន្ទីរឃុំឃាំងយ៉ាងម៉េចដែរបាទ?

[១៣:៤០:១០]

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ គឺបញ្ហាទឹកហ្នឹង ទឹកងូតគ្នាទេក្នុងមួយខែហ្នឹង ហូបហ្នឹងបានព្រឹក កាលបានព្រឹកទៅក៏អត់ល្ងាច បានល្ងាចក៏អត់ព្រឹក។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់បានទេ ថាតើទឹកដែលឲ្យសម្រាប់អ្នកជាប់ឃុំឃាំងផឹកហ្នឹង ពាក្យថា "បានព្រឹកអត់ល្ងាច ល្ងាចអត់ព្រឹក" ចុះក្មេងវិញ តើគេចែកឲ្យដូចមនុស្សចាស់ ឬក៏ខុសគ្នាយ៉ាងម៉េចដែរ?

**ឆ៖** បាទ ទឹកហ្នឹងគឺពួកយាមហ្នឹងវាដងមកឲ្យផឹកហ្នឹង ដងដាក់ប៉ោតតែម្តង ដាក់ក្នុងហ្នឹង។ មានផ្តិលដួសផឹកហ្នឹងទៅ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងរបបហូបចុកទាំងទឹកទាំងម្ហូបអាហារនេះ ចំពោះអ្នកដែលជាប់ឃុំជាមួយនឹងលោក ដែលលោកមានប្រសាសន៍ព្រឹកមិញថា ប្រហែលជា៨៨នាក់ហ្នឹង តើលក្ខខណ្ឌក្នុងការចែករបបហូបហ្នឹង គេចែកម្តងទាំងអស់គ្នា ឬក៏ចែកជាដំណាក់ៗ ឧទាហរណ៍ចែកជាមួយក្រុមម្តងៗអ៊ីចឹង ឬយ៉ាងម៉េចបាទ?

**ឆ៖** អាបញ្ហារបបហ្នឹង គឺពេលដែលហូបអ៊ីចឹង មានអ្នកយាមឆ្នាំគុកហ្នឹង យាមដួសឲ្យម្នាក់មួយចានចង្កឹះៗហ្នឹង។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងកន្លែងឃុំឃាំងហ្នឹងមានទារកដែរទេ មានកូនង៉ាដែរទេ?

**ប្រធានអង្គជំនុំ៖**

ទាន់! កុំអាលទាន់!

**លោក ចាន់ ទូយ៖**

**ឆ៖** ក្នុងនោះកូនង៉ាអត់មានទេ មានតែអាយុ១៧, ១២, ៨ឆ្នាំ, ៦ឆ្នាំអីហ្នឹងមាន។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** បាទ សូមអរគុណ។ តើមានអ្នកជំងឺដែល -- មានអ្នកជាប់ឃុំហ្នឹងមានអ្នកណាឈឺរាករូស ឬក៏ហើមអី មានដែរទេ?

**ឆ៖** បាទ ក្នុងរយៈមួយខែហ្នឹងអត់មានពីណារាករូសមានអីទេ មានតែកើតរមាស់ហ្នឹងតែម្តង។ ដូចខ្ញុំជម្រាបព្រឹកមិញអីចឹង។

[១៣:៤៣:០៥]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរអំពីការរស់នៅដែល នៅក្នុងមន្ទីរសន្តិសុខភ្នំក្រោលនេះ។ តើកន្លែងដេក ទំហំដេក កន្លែងដេកហ្នឹងមានទំហំប៉ុនណា ហើយមានកន្ទេល ឬខ្នើយក្រាលដេកដែរទេ?

**ឆ៖** បាទ សូមជម្រាបដែរបញ្ហាកន្លែងដេកហ្នឹង គឺមានកន្ទេល មានភួយអីទេ ដល់យប់ៗហ្នឹងយកទៅចង យកខ្សែមកចងជើង ថ្ងៃហ្នឹង ដូចជម្រាបព្រឹកមិញហ្នឹង។ ថ្ងៃៗហ្នឹង ចងតែដៃ និងជើងហ្នឹងទ្រាំជាន់គ្រាប់ស្អីខ្មៅហ្នឹង ប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ចុះសម្លៀកបំពាក់អ្នកដែលជាប់ឃុំហ្នឹង ខាងពួកសន្តិសុខគេឲ្យយើងស្លៀកពាក់យ៉ាងម៉េចដែរ?

**ឆ៖** បាទ ការស្លៀកបំពាក់ហ្នឹង គេចាប់ទៅថ្ងៃណា យើងមានស្លៀកអី ស្លៀកតែប៉ុណ្ណឹងរហូតហ្នឹងហើយ។

**ស៖** បាទ សូមអរគុណ។ កម្រាលដែលលោក និងក្រុមអ្នកដែលជាប់ឃុំសម្រាកហ្នឹង តើវាមានជាសង្កើច មានចៃ មានអី ឬក៏អត់ទេ?

**ឆ៖** បាទ បញ្ហាសម្រាកហ្នឹង ក៏ដេក -- ដេកលើឥដ្ឋហ្នឹងហើយ មិនមានកន្ទេលមានអីទេ ដឹងសង្កើច ដឹងស្អី បើជាន់គ្រាប់ខ្មៅលើហ្នឹងដែរ។

[១៣:៤៤:៤៧]

**ស៖** បាទ សូមអរគុណ។ នៅក្នុងខែ១១ នៃឆ្នាំ១៩៧៧ លោកថាជាប់មួយខែ។ អីចឹងមានន័យថា ដល់ខែ១២ អីចឹងមែនទេ?

**ឆ៖** បាទ ក្នុងខែ១១ហ្នឹង។

**ស៖** បាទ សូមអរគុណ។ តើរដូវដែលពួកខ្មែរក្រហមចាប់លោកទៅឃុំឃាំងហ្នឹង ជារដូវធ្លាក់ខ្យល់ ឬក៏រដូវភ្លៀង?

**ឆ៖** ពេលចាប់ទៅឃុំឃាំងហ្នឹងនៅភ្លៀងតិចៗដែរខែ១១។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកបន្តទាក់ទងជាមួយនឹងការដោះលែង។ លោកថាត្រូវបានជាប់ឃុំនៅទីនោះប្រហែលជាជាងមួយខែ ហើយត្រូវបានដោះលែងទៅវិញ។ តើការដោះលែងពីមន្ទីរឃុំឃាំងហ្នឹងឲ្យលោកមានសេរីភាពវិញ ឬមួយក៏យកលោកទៅធ្វើការនៅកន្លែងណា?

**ឆ៖** បាទ ការដោះលែងហ្នឹង ដូចថាវាចែកទៅខាងការដ្ឋានហ្នឹងមួយកន្លែង២០នាក់ មាន១០នាក់ មានប្រាំនាក់ វាចែកគ្រប់កន្លែងការដ្ឋានគេធ្វើការនោះ។

**ស៖** តើដោះលែងទាំង៨៨នាក់ហ្នឹង ឬមួយក៏ដោះលែងតែលោក?

**ឆ៖** ដោះលែងតែមួយចំនួនពួកខ្ញុំហ្នឹងភ្លេចចំនួនដែរ ខ្ញុំក៏ភ្លេចដែរត្រង់ហ្នឹង។ ហើយមួយចំនួនហ្នឹងមិនដឹងយកទៅខាងណា។

**ស៖** លោកនៅចាំឈ្មោះទេ អ្នកដែលត្រូវបានដោះលែង ឬអ្នកដែលទៅជាប់ជាមួយគ្នានឹងលោក តើពួកគេសព្វថ្ងៃមាននៅរស់ដែរទេ?

[១៣:៤៦:៥៥]

**ឆ៖** បាទ នៅចាំអ្នកខ្លះក៏ស្លាប់ហើយ អ្នកខ្លះនៅរស់ ចេះនៅកូនក្មេងហ្នឹងនៅរស់ ពួកក្មេងៗចាស់ៗហ្នឹងស្លាប់អស់ហើយ។

**ស៖** តើនៅកន្លែងការដ្ឋានដែលពួកខាងសន្តិសុខគេដោះលែងឲ្យទៅធ្វើការហ្នឹងជាការដ្ឋាន ជាប្រជាជនសាមញ្ញ ឬក៏ការដ្ឋានក្រោមការគ្រប់គ្រងរបស់ពួកសន្តិសុខដដែល?

**ឆ៖** កន្លែងការដ្ឋានហ្នឹងគឺជាកន្លែងលុតដំ កន្លែងស៊ីអត់ស៊ីឃ្លានដែរនោះហើយ កន្លែងការដ្ឋាននោះ។

**ស៖** បាទ សូមអរគុណ។ តើនៅកន្លែងលុតដំហ្នឹង កូនក្មេង និងស្រីៗដែលជាប់ឃុំជាមួយលោកមានបញ្ជូនទៅធ្វើការទីនោះដែរឬទេ?

**ឆ៖** បាទ ស្រីៗក៏ធ្វើការ ប្រុសៗក៏ធ្វើការដូចគ្នាហ្នឹង ធ្វើទាំងយប់ធ្វើទាំងថ្ងៃនោះ។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងការដ្ឋានធ្វើការលុតដំហ្នឹងមាន លោកដែលមានដឹង ឬមាន

ឃើញការចាប់មនុស្សយកចេញទៅបាត់ដែរទេ?

**ឆ៖** កន្លែងការដ្ឋានខ្ញុំនៅហ្នឹងវាជួនកាលគេដូរពីនេះទៅនោះ ពីនោះមកនេះអ៊ីចឹង វាអត់ទៀងទាត់ដែរ យើងក៏យកទៅណាមកណា ខ្ញុំអត់ដឹងថាគេយកទៅសម្លាប់ចោលក៏មិនដឹង ព្រោះវាបាត់មុខរហូតដែរអាខ្លះ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកទាក់ទងជាមួយនឹងក្រុមញាតិ ក្រុមសាច់ញាតិគ្រួសាររបស់លោកក្នុងសម័យរបបខ្មែរក្រហមដែលលោកបានជម្រាបជូនអង្គសវនាការតាំងពីព្រឹកមកថាមានចាប់ជាប់ខ្សែញាតិសន្តាន បងប្អូន។ តើក្រុមគ្រួសាររបស់លោកដែលជាប់សាច់ញាតិហ្នឹងមានបាត់ខ្លួន ឬបានស្លាប់ប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ បាត់ច្រើន ប៉ុន្តែមិនដឹងទៅណាទៅណីទេ ខ្លះបាត់ដំណឹងរហូតឃើញមកដល់ឥឡូវ។

**ស៖** បាទ សូមអរគុណ។ សំណួរមួយទៀត លោកមានស្គាល់ត្រពាំងព្រីងដែរទេ?

**ឆ៖** ត្រពាំងព្រីងហ្នឹង ត្រពាំងព្រីងមួយណា ច្រើនត្រពាំងព្រីង។

**ស៖** បាទ សូមអរគុណ។ ក្នុងឯកសារត្រពាំងព្រីងទាក់ទងជាមួយនឹងនៅទិសខាងលិចនៃសន្តិសុខភ្នំក្រោល ប្រហែល៤គីឡូម៉ែត្រ។ តើលោកមានធ្លាប់ដឹង ធ្លាប់ឮដែរទេ?

[១៣:៥០:០៥]

**ឆ៖** បាទ ទិសខាងត្រពាំងព្រីងហ្នឹង ខ្ញុំក៏មិនសូវយល់ មិនសូវបានដើរដែរម្តុំនុ៎ង។

**ស៖** បាទ សូមអរគុណ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមដែលលោករស់នៅក្នុងស្រុកកោះញែកនោះ តើដែលមានកម្មាភិបាលជាន់ខ្ពស់ ឬថ្នាក់ដឹកនាំប្រទេសសម័យនោះទៅដល់ទីតាំងស្រុកកន្លែងដែលលោករស់នៅដែរទេ?

**ឆ៖** បាទ ដូចអត់ឃើញមានអ្នកធំៗ អ្នកបរទេស អ្នកណាទេ មានចៅហ្វាយស្រុកហ្នឹង គណៈតំបន់អីហ្នឹង ចុះទៅត្រួតពិនិត្យទំនប់ប្រឡាយអីប៉ុណ្ណឹង។

**ស៖** សំណួរខ្ញុំសួរ អំមិញសួរអំពីថ្នាក់ដឹកនាំប្រទេស។ លោកដែលឮសូរឈ្មោះ លោក ខៀវ សំផន ឬក៏លោក នួន ជា អីទៅដល់តំបន់ដែលលោករស់នៅហ្នឹងដែរទេ?

**ឆ៖** ឮតែឈ្មោះតាមវិទ្យុដែរ មុខមាត់ដឹងយ៉ាងណាផង ឮតែតាមវិទ្យុដែរកាលនោះ។

**ស៖** បាទ ជាសំណួរចុងក្រោយ ពីព្រឹកមិញលោកនិយាយនៅពេលព្រះរាជអាជ្ញាបានសួរលោកថាលោកមិនចង់ដឹង មិនចង់ឮ ឬមិនចាប់អារម្មណ៍អំពីរបបនេះតទៅទៀតទេ។ អ៊ីចឹងលោកគិតថា នៅ

ក្នុងការចាប់លោកទៅឃុំឃាំង ឬក៏បងប្អូនរបស់លោកដែលស្លាប់ហ្នឹង គឺជានយោបាយខ្សែបណ្ដោយថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យដែរទេ?

[១៣:៥១:៤៧]

**ឆ៖** បាទ ខ្ញុំយល់ឃើញតែប៉ុណ្ណឹង ពីព្រោះថា អត់មានបរទេសណាទៅចាប់ទៅចងផង ឃើញតែខ្មែរគ្នាឯងកាលនោះ។ មានតែរបបហ្នឹងតែម្ដង។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកសាក្សី ខ្ញុំមានសំណួរតែត្រឹមនេះ។

សូមអរគុណលោកប្រធាន ខ្ញុំសូមបញ្ចប់បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនក្រុមសហមេធាវីការពារក្ដី។ ដំបូងនេះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១៣:៥២:២៥]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសាកសួរលោកនៅពេលរសៀលនេះ។ លោកសាក្សី លោកស្ដាប់ខ្ញុំឮទេ?

**លោក ចាន់ ទូយ៖**

**ឆ៖** ស្ដាប់ឮបាទ។

**ស៖** កាលពីព្រឹកមិញលោកបានឆ្លើយទៅនឹងសំណួររបស់ព្រះរាជអាជ្ញាដែលថា <កន្លែងដែល> លោកត្រូវបានគេឃុំមួយខែ <>មិនមែននៅគុកទេ <ប៉ុន្តែជាការពិត គឺជា>មន្ទីរតំបន់ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺនៅមន្ទីរតំបន់។

**ស៖** ខ្ញុំចង់សួរលោកថា តាមដែលលោកឆ្លើយជាមួយអ្នកស៊ើបអង្កេតរបស់<មជ្ឈមណ្ឌលឯក-សារកម្ពុជា> គឺឯកសារ <E3/7823> ភាសាអង់គ្លេសមានលេខ 00645464, ខ្មែរមានលេខ <00231426>, ភាសាបារាំង <00632712> គឺលោកនិយាយ "គឺគេមិនចាត់ទុកថាជាគុកទេ។ <ប៉ុន្តែនៅពេលដែល>ស្ថានភាពវាមិនមានភាពស្ថិរភាព <>មនុស្ស<>ទាំងអស់<ត្រូវបានគេទុក>នៅទីនោះ <មុនពេលពួកគេត្រូវបានបញ្ជូនទៅកន្លែងខុសៗគ្នា"> ហើយលោកបានបន្ថែមថា <"យកទៅសម្លាប់ ឬ>បញ្ជូនទៅភូមិវិញ"។ ដូច្នេះ តើវាជាការត្រឹមត្រូវទេ ដែលថាកន្លែងដែលគេឃុំខ្លួនលោកហ្នឹងមិនមែនជាគុកទេ?

**ឆ៖** បាទ ខ្ញុំយល់ដឹងថា កន្លែងឃុំឃាំងហ្នឹង គឺនៅមន្ទីរតំបន់ហ្នឹង។

[១៣:៥៥:១១]

**ស៖** កន្លែងដែលគេឃុំឃាំងលោកហ្នឹង<ក៏>គេហៅថា <>ក-១៧ ដែរ តើមែនទេ?

**ឆ៖** បាទ កន្លែងឃុំឃាំងហ្នឹង ក-១៧។

**ស៖** ប្រហែលជាមានបញ្ហាបន្តិច<ក្នុងការបកប្រែ។> កន្លែងដែលលោកហើយនិងអ្នកដទៃ<ត្រូវបានគេ>ឃុំហ្នឹង <តើវា>ជាគុក ឬក៏ជាកន្លែងឃុំឃាំង ឬក៏ជាមន្ទីរតំបន់<ដែលមាន>អគារជាប់<ៗគ្នា>?

**ឆ៖** បាទ ខ្ញុំយល់ដឹងថាតែកន្លែងឃុំឃាំងរបស់ខ្ញុំគឺនៅមន្ទីរតំបន់ហ្នឹងតែម្តង នៅផ្ទះថ្មហ្នឹង។

**ស៖** មិនអីទេលោកសាក្សី លោកទើបតែឆ្លើយសំណួរខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺឆ្លើយសំណួរទាក់ទងទៅនឹងប្រជាជនដែលត្រូវបានគេឃុំខ្លួន<ជាមួយ> ហើយក្រោយមកទៀតត្រូវបានគេដោះលែង។ តើលោកចាំឈ្មោះមនុស្សដែលត្រូវបានគេឃុំជាមួយលោក ហើយក្រោយមកទៀត ត្រូវបានគេដោះលែង<>ដូចលោកដែរទេ<>?

**ឆ៖** ខ្ញុំចាំតែបងប្អូនសាច់ញាតិខ្ញុំហ្នឹង ហើយអ្នកក្រៅៗពីហ្នឹងមិនដឹងទៅខាងណា ខាងណីខ្លះអស់។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺ E3/7694 គឺលោកបាននិយាយអំពី ពូរបស់លោកឈ្មោះ <សាវ៉ាត់ និង> សុគត់ ហើយនិងស្ត្រីមួយចំនួន។ តើពួកគាត់ត្រូវបានគេដោះលែងជាមួយលោកដែរ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ឈ្មោះហ្នឹងអត់ច្បាស់ទេ ឈ្មោះសុវ៉ាត់ សុគត់ ហ្នឹង អត់ដឹងផង។

**ស៖** សុំទោសប្រហែលខ្ញុំអានឈ្មោះមិនច្បាស់ ខ្ញុំសូមអានទៅលើអ្វីដែលលោកបាននិយាយគឺ មានលេខ ERN ខ្មែរ 00236707, អង់គ្លេសមានលេខ 00242144, <> ខ្ញុំនឹងផ្ដល់លេខ ERN បារាំង <នៅពេលក្រោយ> គឺនៅផ្នែកចុងក្រោយនៃចម្លើយរបស់លោក គឺលោកនិយាយថា៖ "ខ្ញុំចាំអ្នកជាប់គុកជាមួយគ្នានៅ ភ្នំក្រោល មានឈ្មោះ ពូសារ៉ាត បច្ចុប្បន្នគាត់រស់នៅភូមិពាមជីមៀត ឃុំពាមជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី ហើយនិង ពូ<សុខុត> បច្ចុប្បន្នគាត់រស់នៅភូមិកោះមឿលក្រោម ឃុំណងឃីលីក ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ក្រៅពីនេះ មានស្រីខ្លះៗដែរ តែឥឡូវ មិនដឹងនៅទីណាទេ។" តើលោកនឹកឃើញទេ អ្វីដែលលោកឆ្លើយនេះ?

**ឆ៖** បាទ ដូចខ្ញុំជម្រាបព្រឹកមិញហ្នឹងថា មិនទាន់ច្បាស់ ត្រង់ណា ឈ្មោះដែលអានអំមិញហ្នឹង គឺត្រឹមត្រូវហើយឈ្មោះហ្នឹង ដូច ពូ <នេត> សារ៉ាត, ដូច ពូ សុខុត អីហ្នឹង អាហ្នឹងត្រឹមត្រូវដាក់ឃុំឃាំងជាមួយខ្ញុំនៅក្នុងផ្ទះថ្មទាំងអស់គ្នាដែរ។

**ស៖** ហើយពួកគាត់ហ្នឹងត្រូវបានគេដោះលែងជាមួយលោកដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ដោះលែងថ្ងៃតែមួយជាមួយគ្នាហ្នឹង។

**ស៖** នៅក្នុងចម្លើយរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា <មានពីរដង> គឺលោកបាននិយាយអំពីកងពល៩២០ តើលោកចាំអ្វីខ្លះទាក់ទងទៅនឹងកងពល ៩២០នេះ?

[១៣:៥៩:៥៨]

**ឆ៖** បាទ ខ្ញុំចាំតែគេថា កងពលហ្នឹង កងពលលេខ៩២០ ដឹងតែប៉ុណ្ណឹង មិនដឹងកងពលពីណាមកៗ ដឹងថាកងពលទៅទិសខាងកើតហ្នឹងកងពល៩២០។ អ្នកខ្លះក៏រត់មកសារភាពអីច្រើនហ្នឹងក៏ ថានៅឯណា នៅសួរទៅវិញទៅមក ថានៅកងពល៩២០។

**ស៖** តើលោកចាំទេថា អ្នកណាជាមេបញ្ជាការកងពល៩២០ នេះ?

**ឆ៖** បាទ រឿងមេៗគេមេបញ្ជាការហ្នឹង ខ្ញុំអត់ដឹងទេ រឿងមេបញ្ជាការគេហ្នឹង ថាច្បាស់អ្នកណាផង។

**ស៖** តើលោកធ្លាប់ឮឈ្មោះ <តាឈីន> ទេ?

**ឆ៖** ជិន ហ្នឹង ជិន មួយណា វាមានច្រើន ជិន។ ជិនតូច ក៏មាន ជិនធំក៏មាននៅភូមិហ្នឹងមានច្រើនឈ្មោះ ជិន។

**ស៖** ប្រហែលជាខ្ញុំអានឈ្មោះមិនច្បាស់ ប៉ុន្តែខ្ញុំចង់និយាយអំពី តាឈីន មេបញ្ជាការកងពល

៩២០។ <គាត់ជាមនុស្សសំខាន់ជាងគេបំផុតនៅក្នុងកងពល៩២០។> តើលោក<ស្គាល់ម្នាក់ហ្នឹងទេ>?

**ឆ៖** បាទ នឹកអត់ឃើញដែរ មេបញ្ជាការហ្នឹង។

**ស៖** តើលោកធ្លាប់ឮថា<នៅពេលណាមួយនោះ>សមាជិកកងពល៩២០ ត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅភ្នំពេញទេ?

**ឆ៖** បាទ អត់ដែល អត់ដែលឃើញផង។

[១៤:០២:០៩]

**ស៖** តើលោកធ្លាប់ឮទេថា <នៅពេលណាមួយនោះ>មានមនុស្សប្រហែលជា១០០នាក់ជាង <ឬក៏អាចច្រើនជាងនេះ>មកពីកងពល៩២០ ត្រូវបានគេឃុំខ្លួននៅស-២១ <>ត្រូវបានគេដោះលែង <>ទេ?

**ឆ៖** បាទ បញ្ហាហ្នឹងអត់ឮទេ មកដល់ណេះហើយលែងឮហើយ។

**ស៖** នៅពេលព្រឹកមិញនេះ លោកបាននិយាយអំពីជម្លោះមួយរវាង តាហម ហើយនិង ខាំភួន។ តើពួកគាត់ឈ្លោះគ្នាដោយសារមូលហេតុអ្វីដែរ? ចង់ដឹងថា ហេតុអ្វីបានជា<ពួកគេមានបញ្ហាជាមួយគ្នាបែបនេះ? ហើយហេតុអ្វីបានជា> ខាំភួន សម្លាប់ តាហម <ឬ ឡាំង?> តើលោកដឹងថាពួកគាត់ឈ្លោះគ្នារឿងអ្វីទេ?

**ឆ៖** បាទ បញ្ហា តាហម ជាមួយ តាខាំភួន ហ្នឹងខ្ញុំអត់ដឹងទេ ព្រោះមកដល់ភ្នំពេញហើយដឹងសម្លាប់គ្នាដោយរបៀបណា ដូចខ្ញុំជម្រាបព្រឹកមិញអ៊ីចឹង។ ខ្ញុំមិនដែលដឹងគេសម្លាប់ដឹង ឬក៏គេដាក់គុកដាក់អី មិនហ៊ានថាដែរ ពីព្រោះភ្នែកអត់ឃើញ អត់ដឹង ដឹងតែបាត់រហូតតែម្តង។

**ស៖** ព្រឹកមិញនេះនៅពេលដែលលោកឆ្លើយសំណួរខាងព្រះរាជអាជ្ញា លោកបានប្រាប់ថា លោកបានឮអំពីនីរសាររបស់ ខាំភួន។ ឥឡូវនេះ ខ្ញុំសូមអាននូវកំណត់ហេតុស្តាប់ចម្លើយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺបុគ្គលម្នាក់ទៀតក៏បាននិយាយទាក់ទងទៅនឹងការស្លាប់របស់ តាហម ហៅ ឡាំង គឺ E3/7960, <ERN> អង់គ្លេសមានលេខ 00450296, ខ្មែរមានលេខ 00851666, បារាំងមានលេខ 0073899(ស៊ីក)។ គាត់បាននិយាយដូចតទៅនេះ៖ "ខាំភួន ត្រូវបានគេនាំយកមកភ្នំពេញ នៅក្នុងបន្ទប់មួយដែលមានគ្រែពីរ។ ខាំភួន សម្លាប់គាត់ដោយប្រើដែក<មួយដុំ ដែលយកមកពី>ឡាន (សន្ទុះឡាន) ហើយបន្ទាប់មកគាត់សម្លាប់ខ្លួនគាត់តាមក្រោយ"។ តើលោកធ្លាប់ឮអំពីរឿងរ៉ាវទាំងអស់នេះ ថាតើនីរសារធ្លាប់បានប្រាប់លោកដែលថា ខាំភួន សម្លាប់ ហម <ឬ ឡាំង> ដោយ<ប្រើ>ដែកសរសៃ<យក

មក>ពីក្នុងឡាន ហើយបន្ទាប់គាត់សម្លាប់ខ្លួនឯង។ តើលោកធ្លាប់ឮទេ?

[១៤:០៥:៤២]

**ឆ៖** បាទ នីរសារហ្នឹងក៏បានប្រាប់ដែរ ថាកាលនុ៎ងថា ស្លាប់ហើយពីរនាក់នោះ ប៉ុន្តែវាមិនប៉ាន លេចមុខថា ស្លាប់ដោយយ៉ាងប្រការណាទេ។ អ៊ីចឹងគេជូនពួកនីរសារហ្នឹងទៅវិញ។

**សៈ** លោកបាននិយាយថា លោកត្រូវបានគេចាប់ខ្លួន ហើយឃុំខ្លួននៅក្នុងខែវិច្ឆិកា ឆ្នាំ៧៧។ តើវាអាចទេ ដែលថា ខាំភួន សម្លាប់ តាហម <ឬ ឡាំង> នៅថ្ងៃ២៦ តុលា ៧៧ គឺប្រហែលជាប៉ុន្មានអាទិត្យ មុនគេចាប់ខ្លួនលោក តើវាអាចទេ?

**ឆ៖** បើពេលថ្មីៗហ្នឹង អត់ដឹងទេ ដល់ក្រោយមកបានយូរៗ បានដឹង តាមដំណឹងដែរ។ នាពេលថ្មីកំពុងកើតហេតុ កើតរឿង កើតរ៉ាវហ្នឹង អត់មានពីណាដឹង។

**សៈ** ខ្ញុំយល់ ប៉ុន្តែខ្ញុំចង់សួរលោកអ៊ីចេះ។ នៅពេលលោកបានឮរឿងរ៉ាវពីនីរសារ ទាក់ទងការស្លាប់របស់ តាហម ថាតើលោកដឹងរឿងរ៉ាវហ្នឹង គឺប្រហែលជាពីរបីសប្តាហ៍ មុនគេចាប់ខ្លួន<លោក តើអាច>ទេ?

**ឆ៖** បាទ តាមមើលទៅប្រហែលជារយៈពេលហ្នឹងដែរ បាទ។ ខ្ញុំក៏មិនបានចាំៗច្បាស់ដែរ រឿងអ៊ីចឹងៗអី។ ព្រោះខ្លាចគេដឹងចាប់ដាក់គុក គេដាក់អីៗទៀតនោះ។

**សៈ** តើលោកដឹងទេថា ខាំភួន ហើយនិងអ្នកពាក់ព័ន្ធជាមួយ<ខាំភួន> <>ត្រូវបានគេចោទប្រកាន់ថា<>ក្បត់<ជាតិ> ដោយសារតែពួកគាត់ធ្វើការទាក់ទងជិតស្និទ្ធជាមួយកងទ័ពវៀតណាម <>?

**ឆ៖** បាទ រឿងហ្នឹងៗខ្ញុំអត់ដឹងទេ ព្រោះខ្ញុំមិនមែនថ្នាក់ដឹកនាំទៅមើលគេ ម៉េចដឹងរឿងគេ។

**សៈ** នៅពេលដែលលោកត្រូវបានគេឃុំខ្លួន តើលោកធ្លាប់ឮអ្នកណាម្នាក់និយាយអំពីផែនការផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា ដែលមានការជួយពីកងទ័ពវៀតណាមដែរឬទេ?

**ឆ៖** បាទ កំពុងគេឃុំខ្លួន នៅអត់មានពីណានិយាយប្រាប់ទេ បើមនុស្សទោសហើយ នរណាទៅប្រាប់ស្អី មានពីណាទៅប្រាប់។

[១៤:០៩:១២]

**សៈ** តើលោកស្គាល់ តាស្វាយ ទេ? ប្រសិនបើលោកស្គាល់ តាស្វាយ ហ្នឹង តើ តាស្វាយ ហ្នឹងជាអ្នកណាដែរ?

**ឆ៖** តា ស្វាយ ហ្នឹងខ្ញុំស្គាល់។ ពីដើមនុ៎ង គាត់ចៅហ្វាយស្រុកកោះញែកហ្នឹង។

**ស៖** តើគាត់មានឈ្មោះ ទិត ហែម ផង<ដែរ>ទេ?

**ឆ៖** ដឹងដែរ ឈ្មោះគាត់ពីដើមៗមក ដឹងតែគេហៅ ស្វាយៗ អ៊ីចឹង។

**ស៖** តើលោកធ្លាប់ឮឈ្មោះ កាស៊ី ដែរឬទេ?

**ឆ៖** កាស៊ី ហ្នឹង ឮតែឈ្មោះ ប៉ុន្តែអត់ឃើញមុខ កាស៊ី។ គាត់នៅឯស្រុកផ្សេង។

**ស៖** តើគាត់គឺជាប្រធានស្រុក៥ <> ស្រុកកែវសីមា ដែរឬទេ <តើគេស្គាល់ថាឈ្មោះ ភីម ហៅ កាស៊ី មែនទេ>?

**ឆ៖** បាទ គាត់មិនដឹងប្រធាន ដឹងអនុផង ខ្ញុំអត់ដឹងដែរ គាត់នៅស្រុកផ្សេង។

**ស៖** ខ្ញុំសូមអាននូវសម្រង់មួយឲ្យលោកស្តាប់ លោកសាក្សី។ ហើយបន្ទាប់មកទៀត ខ្ញុំនឹងសួរឲ្យលោកឆ្លើយតប<>។ លោកប្រធាន ខ្ញុំអានឯកសារ E3/7960 គឺERN អង់គ្លេស 00450295, បារាំងមានលេខ <0073898 (ស៊ីក)> ដល់<99>, ខ្មែរមានលេខ 00851665 ដល់<666>។ គឺគេឆ្លើយដូចតទៅនេះ <សាក្សីនេះបាន>និយាយ<ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា>ថា "នៅចុងឆ្នាំ៧៦ <និង>ដើមឆ្នាំ៧៧ ខាំភួន ហើយនិងស្វាយ ត្រូវបានចាប់ខ្លួន ដោយសារតែមានផែនការក្បត់ជាមួយវៀតណាម។ ខាំភួន នាំវៀតណាមចូលតាមរយៈ ស្វាយ។ វៀតណាមត្រូវបានគេរក្សាដោយសម្ងាត់នៅ <នៅជិត>ភូមិ"។ ហើយមុននេះបន្តិច "<យើងបានត្រៀមខ្លួនតាំងពីចលនា> ខាំភួន <មកម្ល៉េះ ប៉ុន្តែ> អាវុធនៅក្នុងឃ្លាំង <ប៉ុន្តែកាន់រួចជាស្រេច>"។ តើលោកធ្លាប់ឮ ខាំភួន ហើយនិងស្វាយ <ជាប់ពាក់ព័ន្ធ>ក្នុងផែនការមួយ ដើម្បីចល័ត<>កងទ័ពវៀតណាមចូលទៅក្នុងខេត្តមណ្ឌលគិរី <ដូចដែលសាក្សីនេះនិយាយ>ដែរឬទេ?

**ឆ៖** បាទ បញ្ហាហ្នឹង ខ្ញុំអត់ដឹងដែរ អ្នកធំៗលើៗ ខ្ញុំអត់ដឹង គេមានផែនការអីៗផង អត់ដឹងទេ កាលនោះ ខ្ញុំប្រាប់ត្រង់។ អត់ដឹង។

**ស៖** តើលោក<មិន>ធ្លាប់ឮ<អំពីការ>ស្តុកអាវុធនៅក្នុងឃ្លាំង ដើម្បីផ្តួលរំលំរដ្ឋាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** បញ្ហាហ្នឹង ខ្ញុំអត់ដឹងទេ បាទ។ ផ្ញើទុកអាវុធ ទុករំសេវអី អត់ដឹងទេ អត់ដឹង។

[១៤:១៤:០៣]

**ស៖** តើលោកធ្លាប់ឮថា<ប្រជាជន និង>អតីតកម្មាភិបាលដែលពាក់ព័ន្ធជាមួយនឹង ខាំភួន

ហ្នឹង បានរត់គេចចូលទៅវៀតណាម បន្ទាប់ពីបែកធ្លាយនូវផែនការនោះ<ទេ>?

**ឆ៖** បាទ បញ្ហាហ្នឹងអត់ដឹងដែរ ដឹងមេណារត់ ដល់ទៅឃើញ ឮល្បី។ មិនដឹងគេនៅស្រុកផ្សេងៗអី នៅកន្លែងផ្សេងៗ។ ហ្នឹង អត់ដឹងដែរ។

**ស៖** ខ្ញុំមិនជឿនោះទេ ប៉ុន្តែបើលោកមិនដឹង ក៏មិនអីដែរ។ ឥឡូវនេះ ខ្ញុំសួរអ៊ីចេះវិញ តើលោកដឹងទេថាអ្នកណាជាប្រធានភូមិភាគនៅក្នុងឆ្នាំ៧៥, ៧៦ <រហូតដល់ខែកញ្ញា>? តើលោកដឹងទេថាអ្នកណាជាប្រធានភូមិភាគ?

**ឆ៖** បាទ បញ្ហាហ្នឹងកាន់តែវែងឆ្ងាយហើយ ខ្ញុំអត់ដឹង អត់ឮអីទេ ដល់ភូមិភាគ ដល់អីហ្នឹង។ ដឹងតែត្រឹមតំបន់ និងស្រុកកោះញែក ដែលខ្ញុំដឹងប៉ុណ្ណឹង។ ពីព្រោះកាលរបបនោះ មិនដែលផ្សព្វផ្សាយអីដូចសម័យយើងឥឡូវណា សុទ្ធតែសម្ងាត់ទាំងអស់ហ្នឹង។

**ស៖** តើលោកធ្លាប់ឮអង្គការមួយដែលគេហៅថា ហ្វុលរ៉ូ ទេ?

**ឆ៖** ដល់ ហ្វុលរ៉ូៗ ហ្នឹងឮតែសម័យអ៊ុនតាក់មកឥឡូវនេះទេ បានឮ ហ្វុលរ៉ូ។

**ស៖** លោកច្បាស់ហើយថា លោកឮនៅសម័យនុ៎ង?

**ឆ៖** បាទ ច្បាស់កាលសម័យអ៊ុនតាក់ចុះមកហ្នឹង ឮតែ ហ្វុលរ៉ូៗ។

**ស៖** ខ្ញុំនឹងជួយលោក ឲ្យលោកនឹកឃើញឡើងវិញខ្លះ។ ខ្ញុំយោងទៅលើឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E3/7823 ទំព័រអង់គ្លេស ទំព័រ៤៥ <ERN 00645495>, ខ្មែរមានលេខ <00231459 និង 60>, បារាំងមានលេខ <00632742>។ "សំណួរ៖ តើលោកធ្លាប់ឮ ហ្វុលរ៉ូ ទេ?" លោកឆ្លើយថា៖ បាទ ខ្ញុំធ្លាប់ឮ"។ ហើយបន្ទាប់មកទៀតលោកនិយាយថា៖ "<ជាការពិត> ហ្វុលរ៉ូ ជា<ក្រុម>ជនជាតិភាគតិច ដែលវាយប្រហារប្រឆាំងវៀតណាម<។ តើក្រុមជនជាតិភាគតិចមួយណា? ពួកគេគឺជនជាតិរ៉ាដែ និងព្នង>"។ ហើយបន្ទាប់មកទៀត "នៅពេលនោះ គេមិនចង់ឲ្យវៀតណាម<ពង្រីករបប>កុម្មុយនីស្ត <ពួកគេមិនចង់បានរបបកុម្មុយនីស្តទេ> <>គេចង់ឲ្យរស់នៅប្រទេសសេរី។ ខ្មែរមិនអាចចូលរួមបានទេ ប៉ុន្តែអាចមានទំនាក់ទំនងខ្លះ។ តើ ហ្វុលរ៉ូ មានមន្ទីរនៅក្នុង<ស្រុកកោះញែក>ទេ? <បាទ"។ ប៉ុន្តែអ៊ីចឹងលោកចង់សំដៅទៅលើឆ្នាំ៩៣ទេ។> ចាតើចម្លើយដែលលោកផ្តល់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង តើលោកយោងទៅលើឆ្នាំ<៩៣> ឬក៏លោកនិយាយអំពី<ការវាយប្រហារប្រឆាំងនឹង>កុម្មុយនីស្តវៀតណាមនៅមុនឆ្នាំ៧៥?

**ឆ៖** សម័យ ហ្វុលរ៉ូ ហ្នឹងដូចខ្ញុំជម្រាបប្រាប់អំមិញហ្នឹងហើយ សម័យហ្វុលរ៉ូ ឮសម័យអ៊ុនតាក់

ចុះមកហ្នឹង ដឹងថាហ្វុលរ៉ូ។ គ្រាន់តែឮថាហ្វុលរ៉ូៗហ្នឹង ប៉ុនអត់ទៅស្គាល់ហ្វុលរ៉ូផង។ មិនមែនលាក់លៀមអីទេ ព្រោះអត់ដឹង។ កន្លែងណាដឹង ខ្ញុំប្រាប់ កន្លែងណាអត់ដឹង ដឹងចេះប្រាប់ទេ មិនចេះតែពន្លើសទេ។

[១៤:១៨:៤៥]

**ស៖** ខ្ញុំសូមអានទូវមជ្ឈមណ្ឌលឯកសារដដែល E3/7960 គឺ "ខាំភួន នាំវៀតណាមចូលមក <តាមរយៈ>ស្វាយ ហើយ ខាំ វៀង បានប្រាប់ខ្ញុំថា មេដឹកនាំ<>នឹងបំពាក់អាវុធឲ្យ<> ហ្វុលរ៉ូ"។ ដូច្នេះ ហ្វុលរ៉ូ គឺមានតាំងពីឆ្នាំ៧៨ ហើយវាមានភាពសកម្មនៅក្នុងឆ្នាំនោះ។ តើលោកនឹកឃើញអំពីចលនា ហ្វុលរ៉ូ នេះទេ?

**ឆ៖** បាទ ដូចខ្ញុំជម្រាបអីចឹងអំមិញ សម័យអ៊ុនតាក់មក៩៣អីហ្នឹង ដឹង៩៣ហ្នឹង ដែលហៅហ្វុលរ៉ូៗ។

**ស៖** ខ្ញុំយល់ អត់អីទេ។ ឥឡូវខ្ញុំសាកល្បងសួរលោកម្តងទៀត <ដើម្បីចង់បានប្រតិកម្មរបស់លោក> គឺនៅទំព័របន្ទាប់ E3/7960 អង់គ្លេសមានលេខ 00450296, បារាំងមានលេខ <00763900>, ខ្មែរមានលេខ 00851667។ នេះគឺជាសក្ខីកម្មជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា <របស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាម្នាក់> ហើយគាត់ឆ្លើយដូចតទៅនេះ៖ "នៅក្នុងឆ្នាំ៧៨ ចលនាហ្វុលរ៉ូ បានទាក់ទងជាមួយយើង។ នៅក្នុងឆ្នាំ៧៨ ការចាប់ខ្លួនហ្វុលរ៉ូ ត្រូវបានធ្វើឡើង ហើយបញ្ជូនមកភ្នំពេញ។ <ពួកគេបានត្រឡប់មកវិញ។> ពួកគេមានគ្នាច្រើន ហើយនៅក្រាំងតេះ ពួកគេមានទាហានចំនួនជាង១០០នាក់។ វៀតណាមពិបាកនឹងចូលមកប្រសិនបើ ប៉ុល ពត បំពាក់អាវុធឲ្យចលនាហ្វុលរ៉ូបានទាន់ពេលវេលា ពួកគេខ្លាំង។ ពួកហ្វុលរ៉ូ ជាជនជាតិភាគតិចវៀតណាម។ ខ្ញុំបានជួបពួកគេនៅឆ្នាំ១៩៧៩ គេចង់រំដោះប្រទេសពួកគេក្នុងក្រុមហ្វុលរ៉ូ មានរដែ ចារ៉ាយ កាហា។" តើលោកធ្លាប់ឮអំពី<អ្វី>ទាំងនេះទេ <ដូចជា>ហ្វុលរ៉ូ អាចថា<ការ>ប្តូរ<ទី> ហើយ<>ទាក់ទងជាមួយខ្មែរក្រហមជាមួយបក្សកុម្មុយនីស្តកម្ពុជាជាដើម?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:២១:៣៧]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា វាមានផ្នែកមួយនៃការសួរដែលមិន<មូលដ្ឋាននោះទេ>។ <ប្រហែលជាមានមូលហេតុដែលខ្ញុំមិនដឹង។> មេធាវីបាននិយាយថា <"តើលោកដឹងថា> ហ្វុលរ៉ូ បានប្តូរ<ទីទេ?"> ប៉ុន្តែអ្វីដែល<សាក្សីបាននិយាយ ហើយ>ឯកសារសរសេរគឺថាហ្វុលរ៉ូ បានវាយប្រហារជាមួយនឹងពួកវៀតណាម<ជាប់រហូត>។

**លោក វ៉ិចទ័រ កូប៉េ៖**

យើងមានហេតុផលជឿជាក់ថា ហ្វុលរ៉ូ<អាច> ប្តូរទី -- ប្តូរគោលដៅ។ <ដំបូងវាយប្រឆាំង>នឹងបក្សកុម្មុយនីស្តកម្ពុជា <ក្រោយមកទៀតបានចូលរួមជាមួយពួកគេវិញ>។ ក៏ប៉ុន្តែយ៉ាងម៉េចក៏ដោយខ្ញុំសូមដកនូវផ្នែកនេះចេញពីសំណួររបស់ខ្ញុំវិញ។

**<សួរដោយលោក វ៉ិចទ័រ កូប៉េ៖>**

**ស៖** លោកសាក្សី តើអ្វីដែលខ្ញុំអានឲ្យលោកស្តាប់មុននេះធ្វើឲ្យលោកនឹកឃើញទេ ថាលោកធ្លាប់ឮដែរឬទេ ឬលោកនៅតែរក្សាគោលជំហររបស់លោកថា លោកបានឮហ្វុលរ៉ូហ្នឹង នៅក្រោយឆ្នាំ៩៣ទេ?

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបបញ្ជាក់ប្រាប់អម្បាញ់មិញហ្នឹងហើយ។ កាលមុនៗហ្នឹងក៏អត់ដែលឃើញឮជនជាតិហ្វុលរ៉ូ។ ដល់៩៣ អ៊ុនតាក់មកហ្នឹង បានឮ ខ្លាចតែថាខ្ញុំវង្វេង ភ្លេចភ្លាំងអីមិនដឹង ដូចជាអត់ចាំច្បាស់ទេ ត្រង់ហ្នឹង អត់ដែលឮ អត់ដែលល្បីល្បាញអីផងចំពោះខ្ញុំ។

**ស៖** ខ្ញុំនឹងផ្អាកប្រធានបទមួយនេះ។ លោកសាក្សី ឥឡូវនេះ ខ្ញុំសូមបន្តទៅមុខទៀត។ តើលោកធ្លាប់ឃើញយោធាវៀតណាមឈ្លានពានចូល<ភូមិភាគ>១០៥នៅក្នុងខេត្តមណ្ឌលគិរីទេ? តើលោកធ្លាប់ឃើញ<វៀតណាមណាមួយ>វាយប្រហារចូលទៅក្នុង<ទឹកដី>របស់កម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** បញ្ហាហ្នឹងជ្រាបស្រាប់ហើយ ទូទៅហើយនៅឆ្នាំរំដោះ៧៩ហ្នឹង ឃើញមែន។

**ស៖** ខ្ញុំសូមអាននូវសម្រង់ដដែលដើម្បីឲ្យលោកនឹកឃើញ គឺបាននិយាយថា គឺឯកសារ E3/7960 ទំព័រដដែល "តាំងពីដើមឆ្នាំ៧៧ ខ្ញុំ<បម្រើការនៅ>កងទ័ព<តំបន់>វរសេនា<តូច៥២រហូតដល់វៀតណាមចូលមករំដោះ។> នៅក្នុងឆ្នាំ៧៨ គឺមានការវាយប្រហាររបស់វៀតណាម យើង<ពិបាក>ដឹងអំពីទីតាំងរបស់វៀតណាម<> គេដាក់ផ្លាស់ទី។ វៀតណាមចាប់ផ្តើមការវាយប្រហារ

មុន"។ ដូច្នេះសាក្សីរូបនោះ <ដែលជាអ្នកប្រយុទ្ធនៅ>កងពល<ធំ>៩០២ <និយាយសំដៅទៅការ> បន្ត<>វាយប្រហារ<>ពីវៀតណាមក្នុងឆ្នាំ<៧៧> <នៅមណ្ឌលគិរី។> តើលោកធ្លាប់ពីបញ្ហានេះទេ?

[១៤:២៥:១៧]

**ឆៈ** បញ្ហាហ្នឹងក៏អត់ដឹងដែរ គឺនៅសមរភូមិមុខៗ ព្រោះខ្ញុំនៅក្នុងស្រុក ក្នុងភូមិ នៅក្នុងឃុំ នៅក្នុងស្រុកហ្នឹង អត់ទេ។ មានតែកងទ័ពព្រំដែន កងទ័ពអីហ្នឹង អាចដឹងអាហ្នឹង ខ្ញុំអត់ដឹងច្បាស់ដែររឿងវ៉ៃប្រហារវ៉ៃអីហ្នឹង។ ដឹងតែរឿងគេចាប់ទៅចងខ្ញុំប៉ុណ្ណឹងទេ សំខាន់។ ខ្ញុំមិនដែលចាប់អារម្មណ៍ក្នុងខួរក្បាលខ្ញុំរាល់ថ្ងៃនេះ។

**សៈ** ខ្ញុំនឹងនិយាយអំពី តាហម ម្តងទៀត តើលោកដឹងទេថា តាហម <ខ្លួនឯងហ្នឹង> គឺជាជនជាតិចារ៉ាយ?

**ឆៈ** ដឹងបញ្ហាតាហម មិនដឹងចារ៉ាយ មិនដឹងទំពួនទេ ប៉ុន្តែថា និយាយភាសាឡាវទាំងអស់ នៅកាលមុន ភាសាឡាវ ភាសាខ្មែរនោះ ជនជាតិពិតប្រាកដហ្នឹង ខ្ញុំក៏មិនដឹងថាជនជាតិស្អីផង។

**សៈ** ប៉ុន្តែលោកមិនច្បាស់ទេថា គាត់ជាជនជាតិចារ៉ាយ តើអ៊ីចឹងមែនទេ?

**ឆៈ** បាទ បញ្ហាជនជាតិហ្នឹង ខ្ញុំអត់ដឹងច្បាស់លាស់ថាគាត់ជនជាតិអីផង។ បើនៅនោះ មានតែនិយាយភាសាខ្មែរ ភាសាឡាវអីមាន និយាយជនជាតិចារ៉ាយ អត់ឃើញឮ អត់ឃើញពីណាថាអីជនជាតិចារ៉ាយអី វាមិនល្បី។

**សៈ** ខ្ញុំសូមសួរនៅសំណួរចុងក្រោយរបស់ខ្ញុំមួយទៀត លោកសាក្សី។ គឺខ្ញុំសូមអាននៅសម្រង់តូចមួយមកពីឯកសារ E3/7696។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់លេខ ERN ខ្មែរ ហើយបារាំងនឹងផ្តល់នៅពេលក្រោយឈប់សម្រាកគឺមានតែមួយប្រយោគទេ ដែលខ្ញុំចង់អាន ហើយខ្ញុំអានដោយប្រុងប្រយ័ត្ន។ អង់គ្លេសមានលេខ 00384180 បុគ្គលរូបនេះបាននិយាយអំពី ខាំភួន គឺមនុស្សដែលយើងជជែកគ្នាយូរមកហើយនេះ ហើយគាត់បាននិយាយថា "ផែនការរបស់ ខាំភួន គឺកម្ទេចបក្សកុម្មុយនីស្តនៅក្នុងខែសីហា ឬក៏កញ្ញា <៧៧> ហើយផែនការហ្នឹងត្រូវបានគេរកឃើញនៅក្នុងខែកក្កដា <៧៧>។" តើលោកធ្លាប់ឮអំពីកាលបរិច្ឆេទ ឬក៏ផែនការប្រឆាំងបក្សកុម្មុយនីស្តកម្ពុជា ឬក៏ថា លោកមិនដែលឮអំពីចំណុចទាំងអស់នេះទេ?

**ឆៈ** បាទ ចំណុចទាំងអស់ហ្នឹងមិនដែលឮទេ ពីព្រោះថាមិនមែនថ្នាក់ដឹកនាំធំដុំអីពួកហ្នឹង។

[១៤:២៨:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកក្នុងឋានៈជាមេធាវីរបស់លោកខៀវ សំផន។ សំណួរទី១ ខ្ញុំចង់សួរលោកថា នៅពេលដែលត្រូវបានគេចាប់ខ្លួននៅឆ្នាំ៧៧ តើលោក<ក៏បានដឹង>អំពីការចាប់ខ្លួនអ្នកផ្សេងទៀត<ដែរ ហើយលោកបាននិយាយនៅក្នុងចម្លើយផ្ដល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត> នៅក្នុងឯកសារ E3/7694 ជាកំណត់ហេតុស្ដាប់ចម្លើយរបស់លោក ERN ជាភាសាបារាំង 00276802, ERN ជាភាសាអង់គ្លេស 00242142, ERN ជាភាសាខ្មែរ 00236704 លោកបាននិយាយអំពីកូន<ប្រុស>របស់ ខាំភូន លោកថា គាត់ក៏ត្រូវបានចាប់ខ្លួនដែរ។ អ៊ីចឹងលោកចាំចម្លើយដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតទេ <ឬក៏លោកចង់ឲ្យខ្ញុំជួយរំឭកការចងចាំនោះ>?

[១៤:៣០:៤០]

**ឆ៖** ពេលហ្នឹង ខ្ញុំដូចភ្លេចភ្លាំងអស់ដែរ កាលសួរហ្នឹង។ កាលនោះ នៅចងចាំអីខ្លះៗ ដល់ឥឡូវដូចភ្លេចភ្លាំង មិនចាប់អារម្មណ៍រឿងយើងអ៊ីចឹងៗ។ ដូចថារឿងរបបនោះ មិនចង់ឮ មិនចង់ដឹង មិនចង់ឲ្យមានតែម្ដងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង។

**ស៖** សូមអភ័យទោស ខ្ញុំនឹងសួរពាក់ព័ន្ធទៅនឹងរយៈកាលនោះ សូមឲ្យលោកព្យាយាមនឹកឡើងវិញ។ នៅក្នុង ERN ដែលខ្ញុំបានរៀបរាប់អម្បាញ់មិញហ្នឹងលោកបានឆ្លើយថា៖ "ដំបូងឡើយ<>មានការចាប់ខ្លួនកូន<ប្រុសរបស់> តាខាំភូន ឈ្មោះ ខាំភូន ខាំ ដោយសារ<គាត់>ចេញចូលទៅប្រទេសវៀតណាម ញឹកញាប់"។ តើលោកអាចនឹកឃើញឡើងវិញទេ ហើយលោកអាចជម្រាបខ្ញុំបានទេ ថាហេតុអ្វីបានជាលោកដឹងថា កូនប្រុសរបស់ ខាំភូន ឬក៏ខាំភូន ខ្លួនឯងផ្ទាល់នេះ តែម្ដងចេញចូលវៀតណាម

ញ៉ើកញាប់នោះ?

**ឆ៖** បញ្ហានេះដូចខ្ញុំជម្រាបហ្នឹងឯង អារឿងបញ្ហាគេលើៗហ្នឹង បើខ្ញុំអត់ដឹងទេរឿងអ៊ីចឹងៗ។ អ្នកធំៗគេលើ គេដឹងផែនការម៉េចៗ ព្រោះខ្ញុំអត់ដឹងទេ។ កន្លែងណាខ្ញុំដឹង ខ្ញុំប្រាប់។

**ស៖** <ដើម្បីឲ្យកាន់តែច្បាស់ ជាការពិត>ខ្ញុំសួរសំណួរនេះ ពីព្រោះថា លោកខ្លួនឯងផ្ទាល់ទេ ដែលជាអ្នកបានឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ<>។ អ៊ីចឹង ខ្ញុំចង់សួរលោកថាតើលោកបានព័ត៌មានហ្នឹងមកពីណា? ខ្ញុំ<យល់ថា លោកមិនដឹងអ្វីដែលបាន>កើតឡើងនៅថ្នាក់លើទេ។ <ប៉ុន្តែលោកគឺជាអ្នកប្រាប់ព័ត៌មានទាំងនោះទៅ>សហចៅក្រមស៊ើបអង្កេត<>។ ខ្ញុំចង់បានចម្លើយជាក់លាក់ពីលោក ថាលោកទទួលបានព័ត៌មានហ្នឹងពីណា? <សូមលោករៀបរាប់ឲ្យបានលម្អិតអំពីបញ្ហានេះ ហើយប្រាប់យើងអំពីថាតើលោកទទួលបានព័ត៌មាននោះពី>អ្នកណា <ហើយនរណា>ប្រាប់លោក?

**ឆ៖** បញ្ហាហ្នឹង អារឿងខ្ញុំដូចភ្លេចភ្លាំងឆ្លើយ និយាយជាមួយខាងសម្ភាសមិនដឹង វាភ្លេចអស់ហើយពីព្រោះវាមិនបានចាប់អារម្មណ៍តាំងពីពេលសម្ភាសហ្នឹងម្តងដែរ មិនដឹងជានិយាយរឿងហ្នឹង មិនដឹងមិននិយាយរឿងហ្នឹងផង កាលហ្នឹង ខ្ញុំមានយោបល់តែប៉ុណ្ណឹង។

[១៤:៣៣:៥៥]

**ស៖** ដូច្នេះ មានន័យថា <លោកបាននិយាយដូច្នេះថា> មុនពេលគេចាប់ខ្លួនលោកនៅឆ្នាំ៧៧ លោកជានីរសារ ហើយលោកមានមុខងារតែមួយហ្នឹងគត់មែនទេដែលជានីរសារហ្នឹង?

**ឆ៖** បាទ គឺមុខងារតែនីរសារហ្នឹង។

**ស៖** អ៊ីចឹងក្នុងឋានៈជានីរសារលោកមិនធ្លាប់ចូលរួមក្នុងការប្រជុំរបស់ថ្នាក់ដឹកនាំភូមិឃុំស្រុកទេ មែនទេ?

**ឆ៖** បាទ ថ្នាក់នីរសារ មិនដែលគេឲ្យចូលប្រជុំចូលអីជាមួយអ្នកធំៗ អ្នកអី អ្នកភូមិឃុំទេណា អ្នកនីរសារហ្នឹង បានតែដាំបាយ ធ្វើស្ល គក់ខោអាវឲ្យ ការពារគេ គេប្រើទៅ ហុចសំបុត្រ ហុចស្លាម តែប៉ុណ្ណឹងនីរសារ សម័យនោះវាច្រើនគ្នាធ្វើដែរ របបនោះ។ ទៅមានសិទ្ធិអីទៅចូលប្រជុំ ចូលរួមនឹងពួកមេធំៗទេអាហ្នឹង ពួកលាក់ការណ៍គេយ៉ាងម៉េចយ៉ាម៉ា អាហ្នឹង អត់ដឹង។

**ស៖** ដូច្នេះមានន័យថា លោកមិនបានចូលរួមក្នុងការតាក់តែងគោលនយោបាយនៅថ្នាក់មូល-ដ្ឋាន ថ្នាក់លើទេ ហើយលោកក៏មិនដឹងថា អ្នកណាជាអ្នកចេញបញ្ជា ហើយការអនុវត្តបញ្ជាហ្នឹងគេ

អនុវត្តតាមរបៀបណាក៏លោកមិនដឹងដែរ។ មានន័យថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពីព្រោះថាអត់បានចូលរួមប្រជុំនឹងគេទេ ដូចខ្ញុំអ៊ីចឹង។ ម៉េចទៅដឹងរឿងហេតុការណ៍គេធំៗខាងលើ អត់ដឹងទេ។

**ស៖** តាមរយៈការបកប្រែជាភាសាបារាំង ខ្ញុំឮថា "ខ្ញុំដឹងអំពីផែនការដែលដាក់ចេញមកដោយថ្នាក់លើ"។ អ៊ីចឹងការបកប្រែហ្នឹងត្រឹមត្រូវទេ ខ្ញុំស្ដាប់ឮមកអ៊ីចឹងត្រូវទេ?

**ឆ៖** មិនដឹងបកប្រែរឿងស្អី នុ៎ងខ្ញុំអត់យល់ដែរ មិនដឹងបកស្រាយ។

**ស៖** តាមរយៈការបកប្រែជាភាសាបារាំងអម្បាញ់មិញនេះ ខ្ញុំឮថា លោកឆ្លើយថាលោកដឹងអំពីផែនការរបស់ថ្នាក់លើ។ <តើខ្ញុំយល់លោកបានត្រឹមត្រូវទេ? តើនេះជាអ្វីដែលលោកបាននិយាយ ឬក៏បញ្ហាក្នុងការ>បកប្រែ<>?

**ឆ៖** បាទ ខ្ញុំនិយាយអម្បាញ់មិញហ្នឹង មិនមែននិយាយថាខ្ញុំដឹងពីផែនការពីថ្នាក់លើទេ។ ថារឿងការងារថ្នាក់លើខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែជានីរសារទេ ម៉េចក៏ដឹងការងារគេថ្នាក់លើៗ។ មិនមែនខ្ញុំថាខ្ញុំដឹងពីផែនការពីថ្នាក់លើទេ។ ហ្នឹងស្ដាប់អត់ច្បាស់។

[១៤:៣៧:៣៨]

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីពេលដែលគេចាប់ខ្លួនលោក លោកថា មនុស្សពីរនាក់មកចាប់ខ្លួនលោក។ លោកថាឈ្មោះ កាំ ហើយនិង សុត។ តើអ្នកទាំងពីរនេះជាអ្នកមកចាប់លោកផ្ទាល់មែនទេ?

**ឆ៖** បាទ អ្នកទាំងពីរហ្នឹង កាំ ជាមួយ សុត ហ្នឹងបើកឡានមកចាប់ ដឹកទៅទាំងក្រុមគ្រួសារហ្នឹងទាំងអស់។

**ស៖** លោកឆ្លើយថា គេដឹកលោកទៅដាក់នៅមន្ទីរតំបន់ ហើយគេឃុំលោកនៅទីនោះមួយខែ ហើយលោកថាកន្លែងហ្នឹងគេហៅថា ក-១៧។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើអ្នកណាជាប្រធាន ក-១៧ នេះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់។

**លោក ចាន់ ទូយ៖**

**ឆ៖** ប្រធានតំបន់ហ្នឹងឯង ប្រធានក-១៧ គឺ តាហម។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំនោះទេ តាមរយៈសក្ខីកម្មរបស់លោក នៅពេលដែលគេចាប់ខ្លួនលោក តាហម មិននៅតំបន់ទៀតទេ គាត់ស្លាប់ហើយ។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវ ឬក៏ខុស?

**ឆ៖** អ៊ីចឹងខ្ញុំស្តាប់អំមិញ ក៏អត់បានច្បាស់ដែរបាទ។ ក្រោយពេលដែល តាហម ស្លាប់ហ្នឹងដូចខ្ញុំបញ្ជាក់ប្រាប់តុលាការពីព្រឹកមិញហើយថាមានតាសារុន ហ្នឹងឡើងជាប្រធានហ្នឹងបានចាប់ប្រទូសប្រទាំងហ្នឹង ខ្ញុំបាននិយាយហើយព្រឹកមិញ ក្រៅពីហ្នឹងរឿងវែងឆ្ងាយអីទៀតខ្ញុំដូចភ្លេចភ្លាំងអស់ខ្លះដែរ។

[១៤:៤០:១១]

**ស៖** នៅពេលដែលលោកជាប់ឃុំមួយខែ នៅក-១៧នោះ អ្នកណាជាអ្នកយាមនៅមន្ទីរ ក-១៧ នោះ?

**ឆ៖** មានពួកទាហានហ្នឹងហើយ នៅយាម។

**ស៖** លោកចាំឈ្មោះទាហានទាំងអស់នុ៎ងទេ?

**ឆ៖** បាទ ទាហានហ្នឹង អត់ចាំទេ បាទ។ ព្រោះទាហានមកពីណាពីណីផង អត់ចាំទេ។

**ស៖** តើអ្នកយាមហ្នឹង មានបាននិយាយអំពីឈ្មោះថ្នាក់លើរបស់ពួកគេទេ?

**ឆ៖** កាលនោះ ដូចខ្ញុំភ្លេចខ្លះដែរ មិនដឹង ដូចអត់មាននិយាយអីចំពោះពួកហ្នឹងទេ។ គ្រាន់តែពួកទាហានហ្នឹង វាចំណាំនិយាយថា ខ្សែពួកខ្ញុំ ពួកអាក្បត់។ វាច្រើននិយាយក្បត់ៗទេរបបគេហ្នឹង។ ច្រើននិយាយភាសាហ្នឹង។

**ស៖** ក្នុងពេលដែលលោកជាប់មួយខែ នៅក-១៧ តើលោកធ្លាប់ឃើញ កាំ និង សុត ទៅទីនោះទេ? <អ្នកដែលចាប់ខ្លួនលោកនោះ តើលោកបានឃើញពួកគេទៀតទេ ក្នុងអំឡុងពេលនោះ?>

**ឆ៖** បាទ ពេលដែលឃុំខ្លួនហ្នឹង អត់មានឃើញមុខ កាំ ជាមួយមុខ សុត ទៀតទេ មានតែអ្នកផ្សេងៗមក មិនដឹងគេមកពីណា។ មកយាម មកកាន់ពួកខ្ញុំហ្នឹង។ កាំ និង សុត បាត់មុខរហូត។

**ស៖** ថ្ងៃនេះ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកថា លោកមិនបានឃើញអ្នកដែលនៅ<អាគារ>ខាងលើ <ដែលលោកបាននៅនោះទេ>។ អ៊ីចឹង ខ្ញុំចង់ដឹងថា <ដោយមិនបានឃើញមនុស្សទាំងអស់នោះ តើ>លោកដឹងទេថា <ពួកគេជា>អ្នកណាទេ?

[១៤:៤៣:០៧]

**ឆ៖** បាទ ដូចខ្ញុំជម្រាបព្រឹកមិញហើយថា អ្នកខាងលើហ្នឹង អ្នកណាៗទេ អត់ដឹងដែរ។ ដឹងតែពួកអ្នកខាងក្រោមនេះឯង។ ដឹងម៉េច បើគេចងជាប់ទាំងអស់គ្នា ពីណាទៅដើរសួរម៉េច! របបហ្នឹង តែ

ប៉ានបម្រះ បាញ់ចោលហើយ មានសួរចម្លើយយើងណា របបហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន មុនពេលឈប់សម្រាក តើខ្ញុំអាចសុំការអនុញ្ញាត<ផ្ដល់ឱកាសដល់សហការីរបស់ខ្ញុំ គឺក្រុមមេធាវីការពារក្ដីលោក នួន ជា ឡើងបញ្ចេញមតិ។ តើខ្ញុំអាចបង្ហាញជូនដល់សាក្សី នូវ>ទំព័រទី១នៃឯកសារ E3/7695 <បានទេ? នេះ>ជាចម្លើយរបស់សាក្សី 2-TCW-817 ដើម្បីឱ្យសាក្សីគាត់អាចពិនិត្យមើលឈ្មោះ <ដោយមិនចាំបាច់និយាយឈ្មោះឮៗនោះទេ ហើយបន្ទាប់ពីចូលពីសម្រាកមកវិញ ខ្ញុំនឹងបន្តសួរទៅកាន់សាក្សី។> ដូច្នេះ សូមមន្ត្រីតុលាការមេត្តាយកឯកសារជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

សូមអញ្ជើញមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបានសន្យាថា ផ្ដល់លេខ ERN ចេញពីសម្រង់មួយជូនអង្គជំនុំជម្រះដែលសាក្សីបាននិយាយថា "ផែនការ<>បំផ្លិចបំផ្លាញបក្សកុម្មុយនីស្ត<> នៅក្នុង<ខែសីហា ឬកញ្ញា>ឆ្នាំ១៩៧៧។" ERN ជាភាសាបារាំង 00384283, ខ្មែរ <00231559>។

[១៤:៤៤:៥៨]

**អ្នកបកប្រែ៖**

ខ្ញុំអត់ទាន់ លោកប្រធាន ញាប់ពេក សូមការអនុញ្ញាតម្ដងទៀត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ហើយលោកសាក្សី នៅក្នុងអំឡុងពេលសម្រាកបន្តិចទៀតនេះ លោកអានពិនិត្យអានឯកសារនុ៎ងទៅ ហើយបន្តិចទៀត គឺម៉ោងបីចូលវិញណ៎ះ។

ហើយបង្គាប់ឱ្យ -- មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥នាទី ដល់ម៉ោង ១៥:០៣នាទី)*

[១៥:០៣:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំសូមអរគុណ មេធាវីការក្តី ដែលបានផ្តល់ERN ផងដែរ។

លោកនឹកឃើញទេ សំណួរចុងក្រោយដែលមេធាវីការពារក្តីនួន ជា បានសួរទៅសាក្សី <គឺជា> ចម្លើយមួយ<>ចេញពីឯកសារ<អំពី>ផែនការកម្ទេចបក្សកុម្មុយនីស្ត<>ក្នុងឆ្នាំ៧៧។ <ខ្ញុំគិតថា វាសំខាន់សម្រាប់គ្រប់គ្នាយល់ថា តើឯកសារនេះមកពីណា។ នោះ>គឺឯកសារ E3/7696 ជាកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែ<ពេល>គាត់អានហ្នឹងគឺ<សាក្សី>អានចេញពីចម្លើយ<សារភាព>ស-២១ <របស់លោក -- សាក្សីដែលយើង -- បុគ្គលដែលយើងបាននិយាយ គឺ ខាំភួន>។ ដូច្នេះវាជាចំណុចមួយដែលសំខាន់ណាស់ដែលត្រូវដឹងទាំងអស់គ្នាថានេះជាភស្តុតាងដែលបានមកពីចម្លើយសារភាពដោយការធ្វើទារុណកម្មនៅឯស-២១ នោះទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

<តើអាចទេ>លោកមេធាវី កូប៉េ សូមលោក<>ប្រាប់ជូនតុលាការ<>ថា <តើ>លោកដឹងថាឯកសារ<>ដែលលោកអានហ្នឹងចេញគឺចេញពីមន្ទីរស-២១ ទេ គឺជាចម្លើយសារភាពទេ។

[១៥:០៥:០២]

**លោក វិចទ័រ កូប៉េ៖**

ជាការពិតហើយលោកចៅក្រម ឡាវែន៍ នេះគឺជាការឆ្លើយតបទៅនឹងការកត់សម្គាល់របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងចម្លើយរបស់សាក្សីរូបនេះ ដែលបានឆ្លើយម្តងហើយម្តងទៀត <ហើយគាត់

បញ្ជាក់គ្រប់ទម្រង់>ដែលខ្ញុំបានអានរួចមកហើយ។ ប៉ុន្តែខ្ញុំយល់ឃើញថាលោកចៅក្រមអាចសួរសាក្សីរូបនេះពេលនេះតែម្តងក៏បាន ឬក៏អាចសួរក្នុងថ្ងៃស្អែកក៏បាន <ពីព្រោះជាការពិតសាក្សីដែលនឹងចូលបំភ្លឺបន្ទាប់ ជាអ្នកបានផ្តល់សក្ខីកម្ម>នេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី កូប៉េ សូមឆ្លើយនឹងសំណួរខ្ញុំទៅបានហើយ ខ្ញុំគ្រាន់តែសួរលោកថាតើលោកឆ្លើយបាទ ឬមិនមែនទេ។ តើលោកដឹងដែរឬទេ ថាសាក្សី<ត្រូវបានគេ>អាន<ឲ្យស្តាប់នូវ>ចម្លើយសារភាពដែលចេញមកពីមន្ទីរស-២១<?>

**<លោក វ៉ិចទ័រ កូប៉េ៖>**

<ខ្ញុំមិនបានដឹងទេ។>

**<ចៅក្រម ហ្សង់ម៉ាក ឡាវែន៖>**

ដូច្នេះលោកអានឯកសារមួយដែលមិនដឹងថាខ្លឹមសារឯកសារហ្នឹងជាអ្វីផង ឬក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

មិនអ៊ីចឹងទេ លោកចៅក្រម។ ហាក់បីដូចជាមានភាពច្របូកច្របល់បន្តិចពាក់ព័ន្ធទៅនឹងអ្វីដែលសាក្សីបានបង្ហាញ។ ក៏ប៉ុន្តែដូចដែលខ្ញុំបានជម្រាបហើយ នៅក្នុងទំព័រដូចខាងក្រោមនេះ គឺ <003848184 (ស៊ីក) និងបន្តបន្ទាប់មកទៀត គាត់បញ្ជាក់ថា-->

**អ្នកបកប្រែ៖**

សូមម្តងទៀតលោកប្រធានញាប់ពេក។

**ប្រធានអង្គជំនុំ៖**

ម្តងទៀតៗឲ្យរង្វើលៗបន្តិច ដើម្បីអ្នកបកប្រែ បកប្រែទាន់ដោះស្រាយនេះឲ្យបានច្បាស់លាស់!

[១៥:០៦:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

តាមដែលខ្ញុំយល់នោះគឺ -- ខ្ញុំសូមរៀបឃ្លាឡើងវិញ។ <តាមខ្ញុំយល់>សក្ខីកម្មរបស់សាក្សីរូបនេះហ្នឹងគឺថាគាត់អះអាងថាមានផែនការធ្វើរដ្ឋប្រហារទម្លាក់<រដ្ឋាភិបាល>បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែគាត់ក៏ហាក់មិនច្បាស់ដែរពាក់ព័ន្ធទៅនឹងចម្លើយសារភាពនេះ ប៉ុន្តែគាត់មាននិយាយពីចំណុចនេះហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី អ្វីដែលមិនច្បាស់នោះ គឺរបៀបដែលលោកប្រើភស្តុតាងនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំខ្លាចតែខ្ញុំយល់សំណួរលោកចៅក្រមមិនច្បាស់ទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោក កូប៉េ ខ្ញុំគិតថាត្រូវតែស្មោះត្រង់ជាមួយអង្គជំនុំជម្រះ ព្រោះថានៅពេលដែលលោកប្រើប្រភេទឯកសារបែបនេះ លោកត្រូវតែបំភ្លឺថាតើប្រភពឯកសារនេះមកពីណា? <>

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកសារនេះអាចជាចម្លើយសារភាពមកពីស-២១ ប៉ុន្តែខ្ញុំមិនដឹងថា<>ខាងមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចម្លើយយ៉ាងណានោះទេ។ អ៊ីចឹងឯងបានជាខ្ញុំ<ដាក់ក្នុងបរិបទធំជាង ហើយហ្នឹងជាមូលហេតុដែលខ្ញុំនិយាយ>ថាសាក្សី<នេះ> គាត់បានបញ្ជាក់ទៅនឹងសំណួរនេះហើយ <ហើយគាត់និយាយលើមូលដ្ឋានដូចគ្នា។> តែខ្ញុំក៏មិនច្បាស់ដែរ ក្រែងលោខ្ញុំអានមិនចំកន្លែងវា។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមអន្តរជាតិការពារក្តីលោក ខៀវ សំផន បន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សីយើងបន្តទៀត។ លោកបានអានទំព័រទី១នៃឯកសារដែលខ្ញុំបញ្ជូនឲ្យនេះហើយ គឺចម្លើយរបស់សាក្សី 2-TCW-817 ខ្ញុំសូមកុំឲ្យ<លោកនិយាយ>ឈ្មោះ<របស់គាត់ ប៉ុន្តែគ្រាន់តែ>បញ្ជាក់ប្រាប់ថា លោកហ្នឹងនៅក-១៧ <ជាមួយមនុស្សម្នាក់នេះ>នៅពេលដែលលោកជាប់ឃុំខ្លួននៅទីនោះ។ តើលោកអាចបញ្ជាក់ពីចំណុចនេះបានទេ?

[១៥:០៩:២០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ចាន់ ទូយ៖**

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបលោកតុលាការជ្រាបស្រាប់ហើយព្រឹកមិញ ថាគេឃុំខ្ញុំនៅ ក-១៧ នៅមន្ទីរតំបន់គេហ្នឹង។ មានប្រសាសន៍ត្រង់ហ្នឹងដដែលពីព្រឹកមិញ។

**ស៖** ខ្ញុំគ្រាន់សុំឲ្យលោកបញ្ជាក់ថា <>លោកនៅជាប់ឃុំជាមួយ<មនុស្សម្នាក់នេះ គឺមនុស្សម្នាក់ដែលលោកអានឈ្មោះគាត់>នៅ<>លើទំព័រដែលខ្ញុំដាក់ជូនឲ្យលោកអានអម្បាញ់មិញនេះ<>។

**ឆ៖** បាទ ពេលដែលជាប់ឃុំនុ៎ង កន្លែង តាលន *(ឮមិនច្បាស់)* អាហ្នឹងជាប់ជាមួយ -- ជាប់ឃុំជាមួយខ្ញុំដែរបាទ។

**ស៖** ឥឡូវ ខ្ញុំសូមឲ្យលោកតទល់ជាមួយនឹងចម្លើយរបស់សាក្សីហ្នឹង ដើម្បីឲ្យលោកនឹកឃើញអំពីអ្វីដែលលោកបាននិយាយ។ <ពីខាងដើមនេះ> ខ្ញុំសួរលោកថា <-- ដោយ>មិនបានឃើញអ្នកទោសនៅជាន់លើនោះ <ខ្ញុំសួរលោកថា>តើលោកដឹងថា ពួកគាត់ហ្នឹងជាអ្នកណានោះទេ? លោកឆ្លើយថាអត់<ដឹង>ទេ។ មុននឹង<ឃើញថា តើចម្លើយរបស់សាក្សីនេះអាច>រំឭកការចងចាំរបស់លោក<ទេនោះ> ខ្ញុំសូមដកស្រង់ចំណុចមួយដែលជាផ្នែកមួយនៃចម្លើយរបស់លោក ដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/7823, ERN ជាភាសាបារាំងគឺ 00632716, ERN ជាភាសាអង់គ្លេសគឺ 00645468 <ខ្ញុំប្រហែលជាចាប់ផ្ដើមអាននៅទំព័រដើមនេះមួយទំព័រ គឺទំព័រ ៦៧ ជាភាសាអង់គ្លេស>, ជាភាសាខ្មែរ គឺ 00231430 ទៅដល់<ទំព័របន្ទាប់>។ នៅពេលនោះ អ្នកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាចោទសំណួរទៅលោកទាក់ទងទៅនឹង<>ក-១៧។ ហើយគេសួរលោកថា "ថាតើលោកដឹងថា អ្នកណាខ្លះដែលគេចាប់ខ្លួន <និងឃុំខ្លួនក្នុងពេល>ដំណាលគ្នាជាមួយលោក?"

[១៥:១២:១៣]

សំណួរដូចតទៅនេះ៖ "តើហេតុអីបានលោកដឹងថា គេចាប់ខ្លួនគាត់ ហើយឃុំខ្លួននៅទីនោះដែរ?" –ខ្ញុំឃើញថា សរសេររបៀបសរសេរនេះមិនសូវល្អ ការបកប្រែហ្នឹងអត់សូវល្អ ព្រោះថាត្រូវយោងទៅអ្វីដែលនិយាយខាងលើ ដើម្បីឲ្យដឹង– ក៏ប៉ុន្តែលោកឆ្លើយថា៖ "គេនិយាយប្រាប់ខ្ញុំពីគាត់ ហើយគេគឺជាអ្នកដែលចាប់ខ្លួនមនុស្ស គឺយោធាដែលនិយាយប្រាប់ខ្ញុំពីរឿងគាត់នេះ។ គាត់និយាយថា អ្នកណា អ្នកណីនៅទីនោះជាដើម។ គឺយោធាតូចៗមិនដឹងអ្វីទាល់តែសោះ គឺពួកគេមកនិយាយលេងធម្មតា គឺដូចរបៀបកូនក្មេង គាត់មកនិយាយលេងជាមួយខ្ញុំ ហើយជូនកាលគាត់ឲ្យបារីខ្ញុំមួយដើមទៀតផង។" សំណួរបន្ទាប់ទៀត ដែលគេសួរទៅលោក៖ "តើក្មេងៗដែលនៅម្ដុំភ្នំក្រោលហ្នឹង ដែលមកនិយាយជាមួយលោកនុ៎ង?

លោកឆ្លើយដូចតទៅនេះ៖ "ទាក់ទងទៅនឹងក្មេងៗទាំងអស់នេះ មិនមែនជាក្មេងដែលនៅក្រៅគុកនោះទេ គឺជាកូនរបស់អ្នកដែលនៅក្នុងគុកហ្នឹង ហើយទ្វារបើកចំហដើម្បីឲ្យពួកគេចេញទៅបន្ទោរបង់នៅខាងក្រៅបាន ហើយអ៊ីចឹងពួកគេដឹងថា អ្នកណាជាអ្នកណា ហើយក្មេងៗទាំងហ្នឹងដឹង ស្គាល់ថា អ្នកទោសហ្នឹងជាអ្នកណាអ្នកណី។" បន្ទាប់មកទៀត មានសំណួរមួយទៀតសួរទៅលោក៖ "តើអ្នកប្រាប់លោកនុំងមិនមែនជាកូនយោធាដែលចាប់ដែលចាប់មនុស្សទេ ឬក៏យ៉ាងណា? លោកឆ្លើយដូចតទៅនេះ "គឺជាកូនអ្នកទោសទេ។ គឺជាកូនក្មេងតូចៗអ៊ីចឹងដែលស្គាល់ពូ អ៊ំ ហើយគាត់និយាយថា គាត់បានជួបអ្នកនេះអ្នកនោះ។ ក្មេងៗទាំងអស់នុំង គាត់និយាយអ៊ីចឹង។" សូមបញ្ចប់ការដកស្រង់។

[១៥:១៤:១៥]

ដូច្នេះ ក្រោយពីអានចម្លើយរបស់លោក ដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំចង់សួរលោកថា តើលោកមានចាំដែរឬទេថា លោកបានព័ត៌មានអំពីអ្នកដែលលោកមិនបានស្គាល់នោះ មិនបានឃើញនោះ ក៏ប៉ុន្តែលោកអាចដឹងថា អ្នកនុំងជាអ្នកណាតាមរយៈក្មេងៗដែលប្រាប់លោកនោះ ដែលគេនិយាយថា អូ៎! ឃើញពូនេះ អ៊ំនោះអីជាដើម។ តើពេលដែលខ្ញុំអានឲ្យលោកស្តាប់នេះ ធ្វើឲ្យលោកនឹកឃើញទេ?

**ឆ៖** បាទ នៅសំណួរអ៊ីចឹង ខ្ញុំក៏សូមជម្រាបប្រាប់ដែរ ដូចខ្ញុំបាននិយាយពីព្រឹកមិញក៏អ៊ីចឹងដែរ វាដូចជាភ្លេចការចងចាំផងមិនដឹងខ្ញុំតាំងពីរបួសក្បាលមកនេះ ហើយក៏ភ្លេចមុនហ្នឹងទៀតក៏មិនដឹង ដូចបាននិយាយ ឬក៏មិនបាននិយាយកាលនោះ ដូចជាវាភ្លេចភ្លាំង មិនបានចាប់អារម្មណ៍ និយាយការពិតទៅគឺមិនបានចាប់អារម្មណ៍រឿងក្តី រឿងអីហ្នឹងផង។ បាទ ខ្ញុំសូមជម្រាបបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ដូច្នេះ ខ្ញុំនឹងមើល ថាតើខ្ញុំអាចធ្វើឲ្យលោកនឹកឃើញដែរឬក៏អត់ជាមួយនឹងចម្លើយរបស់បុគ្គលដែលលោកបានឆ្លើយអម្បាញ់មិញថា គាត់ជាប់ឃុំឃាំងជាមួយលោកដែរ ក្នុងមួយរយៈពេលមួយខែហ្នឹង គឺឯកសារ E3/7695, ERNជាភាសាបារាំងគឺ 00274816, ជាភាសាខ្មែរ 00236716, ERN ជាភាសាអង់គ្លេសគឺ 00239486 ទៅដល់ 7។ គេចោទសំណួរថា តើការចាប់ខ្លួនបុគ្គលរូបនោះ ធ្វើទៅយ៉ាងម៉េចដែរ? ហើយគាត់និយាយអំពីទ្រង់ទ្រាយនៃមន្ទីរក-១៧ ហ្នឹងគាត់និយាយដូចតទៅនេះ៖ "មន្ទីរក-១៧ គឺជាមន្ទីររបស់ ឡេង ហើយមានពីរជាន់ នៅជាន់ផ្ទាល់ដីចាក់បេតុង ហើយជាន់ទី២នោះ មានរនាបក្តារទេ ជញ្ជាំងក៏ក្តារដែរ ហើយដំបូលសង្ក័សី។" សូមបញ្ចប់ការដកស្រង់។ តើការពិពណ៌នានេះត្រឹមត្រូវដែរឬទេ បើតាមការចងចាំរបស់លោកនោះ?

[១៥:១៧:១៤]

**ឆ៖** បាទ កន្លែងឃុំឃាំងនោះ មិនមែនក្ដាររនាប ក្ដារអីទេ ជញ្ជាំងនោះ ជញ្ជាំងក្ដារ ប៉ុនក្រាលស៊ីម៉ង់ត៍ ក្រោមកន្លែងចងពួកខ្ញុំជាន់ទី -- ជាន់ក្រោមគេ។ ប៉ុនជាន់ខាងលើៗ ខ្ញុំអត់បានឡើងមើលទេ។

**ស៖** ហ្នឹងហ្នឹងបន្តិចហ្នឹង គាត់និយាយបន្តទៀត សូមដកស្រង់ពាក្យពេចន៍របស់គាត់ "អ្នកដែលជាប់ឃុំរស់នៅជាន់លើ បើតាមខ្ញុំឮការពិភាក្សារបស់គាត់ហ្នឹង គឺពួកគាត់ប្រហែលជា បួន ប្រាំនាក់។ ដូចជា ស៊ុន ថាន់, សាន់ ថន, ថា, កែម ចាន់, វ៉ា ជាអនុលេខាស្រុកកោះញែក។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ តាមរយៈចម្លើយរបស់គាត់សាក្សីនេះ បានប្រាប់ថា គាត់អាចស្ដាប់ឮអំពីការជជែកគ្នានៅជាន់លើ តើធ្វើឲ្យលោកនឹកឃើញទេ ឈ្មោះដែលខ្ញុំអានអម្បាញ់មិញនេះ ធ្វើឲ្យលោកនឹកឃើញឡើងវិញទេ ហើយបើតាមការពិភាក្សារបស់លោក ការជជែកលេងជាមួយក្មេងៗនោះ តើមនុស្សទាំង បួន ប្រាំនាក់នេះ ដែលសាក្សីរូបហ្នឹងគាត់ថាគាត់ស្ដាប់ឮអ្នកទោស បួន ប្រាំនាក់ហ្នឹងនិយាយគ្នានៅខាងលើ។ អ៊ីចឹងខ្ញុំសួរថា តើចំនួន បួន ប្រាំនាក់ហ្នឹងត្រឹមត្រូវទេ បើតាមការចងចាំរបស់លោក?

**ឆ៖** កាលហ្នឹង ខ្ញុំក៏មិនអាចថាពិតដែរ មិនដឹងជាពីណាជជែកពីណា រឿងស្អី ដឹងការពិតហ្នឹង។ ដូចថានិយាយអំពីរឿងក្មេង អាហ្នឹងមានតែក្មេងវារត់លេងទៅក្រៅ ក្មេងតូចៗហ្នឹង ដូចសំណួរមិញហ្នឹង អាហ្នឹងខ្ញុំដឹងអាហ្នឹង។ ប៉ុន្តែប្រហែលជាដឹងពីណាឈ្មោះអីៗ ពិតប្រាកដនោះ អត់ដឹងទេ។

[១៥:១៩:៤១]

**ស៖** ប៉ុន្តែឈ្មោះដូច សុថន, ថា, កែម ចាន់, វ៉ា ដែលជាអនុលេខាស្រុកកោះញែកនេះ លោកនឹកឃើញពួកគាត់ទេ ស្គាល់ពួកគាត់ទេ?

**ឆ៖** បាទ ឈ្មោះហ្នឹងស្គាល់ ឈ្មោះហ្នឹង ប៉ុន្តែមិនដឹងគេចាប់ដាក់លើ ដាក់អីណាទៅណាទៅណើ វាបាត់មុខពួកគេទាំងអស់ហ្នឹងហើយ បានគេចាប់ពួកខ្ញុំបន្តបន្ទាប់នោះ។

**ស៖** មានចំណុចមួយទៀត ជាចំណុចចុងក្រោយរបស់ខ្ញុំគឺ ចំនួនអ្នកទោសដែលនៅជាន់ផ្ទាល់ដីនៃមន្ទីរក-១៧ ហ្នឹង។ លោកបាននិយាយថា មានចំនួន៨០នាក់ ហើយសាក្សីរូបនេះដដែលហ្នឹង លេខ ERN ដដែល គាត់និយាយថា មានអ្នកទោសប្រហែលជា៤០នាក់ទេ នៅជាន់ផ្ទាល់ដី។ អ៊ីចឹងបើតាមការចងចាំរបស់គាត់នោះ គាត់ថាមានតែ៤០ នាក់ទេ វាខុសពីលោក ដែលនិយាយថាមាន៨០នាក់។ អ៊ីចឹង ខ្ញុំសួរលោកថាលោកនឹកឃើញវិញទេថា ចំនួនមនុស្សហ្នឹង <ពិតជា> ៨០ នាក់?

**ឆ៖** បើខ្ញុំនិយាយជាក់ស្ដែងតែម្ដង ខ្ញុំឃើញកាលគេចងតម្រៀបគ្នាហ្នឹងខ្ញុំរាប់មើលក្នុងចិត្ត ដឹង

ថា ៨០ នាក់ហ្នឹង ៨០ជាងទៀត ជាងមិនដឹងប៉ុន្មានទេ ជាង ទាំងប្រុសទាំងស្រី។ មិនមែនដូចសំណួរនោះទេ។

**ស៖** បាទ ខ្ញុំសង្កត់ធ្ងន់លើចំណុចនេះ ពីព្រោះថានៅពេលដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/7823, ERN ជាភាសាបារាំងគឺ 00632715, ERN ជាភាសាអង់គ្លេសគឺ 00645467, ជាភាសាខ្មែរគឺ <00231430>។ សំណួរ គឺសួរទៅលោកដូចតទៅនេះ៖ "បាទ ឥឡូវយើងនិយាយអំពីបន្ទប់ឃុំខ្លួននៅខាងក្រោម ដែលលោកជាប់ឃុំវិញម្តង បើតាមការប៉ាន់ប្រមាណរបស់លោកនោះ តើក្នុងម្តងនោះ គេអាចឃុំខ្លួនមនុស្សបានប៉ុន្មាននាក់?" ចម្លើយរបស់លោកឆ្លើយដូចតទៅ៖ "នៅជាន់ផ្ទាល់ដី មានលើសពី៥០នាក់។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងនៅក្នុងចម្លើយរបស់លោកដែលលោកឆ្លើយទៅបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា លោកហាក់ដូចជានិយាយថា ជាង៥០នាក់ទេ វាខុសពី ៨០នាក់។ អ៊ីចឹងតើចម្លើយរបស់លោកដែលលោកបានឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ធ្វើឱ្យលោកនឹកឃើញវិញទេ?

**ឆ៖** បាទ ត្រង់ចំណុចហ្នឹង ដូចជាភ្លេចភ្លាំងខ្លះដែរ។ បាទ សូមជម្រាបត្រង់។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសួរចប់ហើយ ហើយលោកមេធាវី គង់ សំអុន គាត់អត់មានសំណួរដែរទេលោកប្រធាន។

[១៥:២៣:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះ អរគុណលោក ចាន់ ទូយ។ សវនាការស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃនេះបានដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ ហើយសូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនលោក ចាន់ ទូយ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅ បានហើយ។

ហើយសវនាការនៅថ្ងៃនេះ គឺដល់ពេលឈប់សម្រាកហើយ ដោយមូលហេតុថា សាក្សីបម្រុងដែលបានប្រកាសព្រឹកមិញនេះ គឺទើបតែធ្វើដំណើរមកដល់កន្លែងស្នាក់នៅ នៅឯទីក្រុងភ្នំពេញឯណោះ មិនអាចមកដល់ អ.វ.ត.ក នេះបាននៅរសៀលនេះទេ។ ហើយដូច្នេះអង្គជំនុំជម្រះ ប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ទី១១ ខែមីនា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-817 ពាក់ព័ន្ធនឹងអង្គហេតុបានចោទប្រកាន់មន្ទីរសន្តិសុខភ្នំក្រោល។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.កវិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:២៥ នាទី)*